ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដា ស្តីពីការលើកកម្ពស់សុខភាពសិក្សា នៅក្រមិតបឋមសិក្សាក្នុងខេត្តស្វាយរៀង

Status of implementation of standard operating principles
On the promotion of academic health
At primary School in Svay Rieng province

**ដោយ**/By

**វ៉ា សុភ័ក្រ្តា / VA SOPHEAKTRA**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល**
**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០**
**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០២១ - ២០២៣**

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដា ស្តីពីការលើកកម្ពស់សុខភាពសិក្សា នៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង

Status of implementation of standard operating principles
On the promotion of academic health
At primary School in Svay Rieng province

ដោយ/By

**វ៉ា សុភ័ក្ត្រា / VA SOPHEAKTRA**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល**
**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០**

**ឯកទេសៈ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០២១ - ២០២៣**

**គ្រូដឹកនាំបង្គោលៈ បណ្ឌិត ម៉ម ចាន់សៀន** **គ្រូដឹកនាំរងៈ លោក ចាប រតនា**

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទឈ្មោះ **វ៉ា សុផ័ក្ត្រា** សូមបញ្ជាក់ថាសារណាស្រាវជ្រាវដែលមានចំណងជើង "**ស្ថានភាពនៃការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដា ស្តីពីការលើកកម្ពស់សុខភាពសិក្សា នៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង**"

សម្រាប់បំពេញលក្ខខណ្ឌបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំជំនាន់ទី១០ នៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះមិនទាន់ត្រូវបានគេយកមកប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬនៅសាកលវិទ្យាល័យណាមួយឡើយ ហើយក៏ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារ ណាមួយត្រូវបានយកមកប្រើប្រាស់ក្នុងការស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារឡើយ។

សារណាស្រាវជ្រាវខាងលើនេះ ពិតជាស្រាវជ្រាវដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន ។

ថ្ងៃ សុក្រ ១១រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០២៣

**ហត្ថលេខាបេក្ខជន**

**វ៉ា សុផ័ក្ត្រា**

# សេចក្តីបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ

**បណ្ឌិត ម៉ម ចាន់សៀន** ជាគ្រូដឹកនាំបង្គោល

**លោក ចាប រតនា** ជាគ្រូដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **ទ៉ា សុភ័ក្ត្រា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ពិតជាបានសរសេរ និក្ខេបបទស្រាវជ្រាវលើប្រធានបទ៖ "**ស្ថានភាពនៃការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដា ស្តីពីការលើកកម្ពស់សុខភាពសិក្សា នៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង**" ពិតប្រាកដមែន។

ថ្ងៃ សុក្រ ១១រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០២៣



...............................................

**បណ្ឌិត ម៉ម ចាន់សៀន**

អនុប្រធានដេប៉ាតឺម៉ង់ គ្រប់គ្រង និងផែនការ

នៃវិទ្យាស្ថានជាតិអប់រំ



...............................................

**លោក ចាប រតនា**

អនុប្រធានដេប៉ាតឺម៉ង់ គ្រប់គ្រង និងផែនការ

នៃវិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ៣៤៧៣ **អយក.ឧទន**

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា ២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំដូរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ក្រសួង អយក | ប្រធាន |
| ២-ឯកឧត្តម | អ៊ុង បូរាត | ក្រសួង អយក | អនុប្រធាន |
| ៣-ឯកឧត្តម | លាង សេងហាក់ | ក្រសួង អយក | សមាជិក |
| ៤-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរ.ភ្នំពេញ | សមាជិក |
| ៧-លោកបណ្ឌិត | នូវ រ៉ាំ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈូក ច័ន្ទធាយា | នាយកដ្ឋានបវ. | សមាជិក |
| ១២-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ១២រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរ.ហិ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ ៤៥០១ អយក.ខ៩ន

(**ការសម្រាប់**)

## លិខិតឧទ្ទេសនាម
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំដូរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២. លោកស្រីបណ្ឌិត បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | អនុប្រធាន |
| ៣. លោកបណ្ឌិត កាន់ ពុទ្ធី | នា.បឋមសិក្សា អយក. | សមាជិក |
| ៤. លោក ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. លោកស្រី សាំង សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦. លោកបណ្ឌិត មាយ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៧. លោកបណ្ឌិត អៃ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ៨. ឯកឧត្តមបណ្ឌិត ប៊ិច សៀង | វិ.បច្ចេកវិទ្យាកំពង់ឈើទាល | សមាជិក |
| ៩.លោកបណ្ឌិត លី គឹមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១០.លោក ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១.លោក លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២. លោកបណ្ឌិត អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣. លោកស្រី នូ ចន្នី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤. លោកស្រី បណ្ឌិត ឡឹយ សុខគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥. លោកបណ្ឌិត អ៊ឹម គឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦. លោកបណ្ឌិត ទី សុផល | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧. លោកបណ្ឌិត គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨. លោកបណ្ឌិត សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩. លោកបណ្ឌិត ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០. លោកបណ្ឌិត សឿង សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១. លោក ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | |
|---|---|---|
| ២២. លោកបណ្ឌិត សោកទ្រា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣. លោក ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤. លោក ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក និងលោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិត នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- អគ្គនាយកដ្ឋានរ.ហិ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទឈ្មោះ **ទ៉ា សុភ័ក្រ្តា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំជំនាន់ទី ១០ នៃវិទ្យាស្ថានជាតិអប់រំ ឯកទេសគ្រប់គ្រងអប់រំ ។

***<u>សូមថ្លែងអំណរគុណជាអនេកប្បការជូនចំពោះ៖</u>***

-លោកឪពុក **ហួត ថន្លា** និងអ្នកម្តាយ **សេក អូន** ដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់រូបខ្ញុំបាទ ព្រមទាំងផ្តល់នូវការជំរុញបូន្មានល្អៗ និងបានបញ្ជូនខ្ញុំឱ្យចូលរៀនតាំងពីថ្នាក់បឋមសិក្សា រហូតដល់ថ្នាក់ ឧត្តមសិក្សាដោយមិនគិតពីការនឿយហត់ និងតស៊ូគ្រប់ឧបសគ្គដើម្បីកូនទទួលបាននូវអនាគតរុងរឿង។

-ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** ជានាយកវិទ្យាស្ថានជាតិអប់រំ ដែលជានិច្ចកាលឯកឧត្តមបណ្ឌិតលោកតែងតែឆ្លៀតពេលដ៏មានតម្លៃរបស់លោកក្នុងការផ្តល់គំនិតការណែនាំ និងផ្តល់ទាំងកម្លាំងចិត្ត កម្លាំងកាយ បញ្ញាស្មារតី សម្ភារ បច្ចេកទេសវិធីសាស្រ្តផ្សេងៗ មិនតែប៉ុណ្ណោះ លោកបានជួយផ្តល់ជាឯកសារផ្សេងៗទាក់ទងនឹងប្រធានបទ ព្រមទាំងជួយបង្ហាញទិសដៅនៃការស្រាវជ្រាវប្រកប ដោយគតិបណ្ឌិតដល់រូបខ្ញុំរហូតដល់ការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យជាស្ថាពរ។

-ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកបណ្ឌិត **ម៉ម ចាន់សៀន** ជាសាស្រ្តាចារ្យដឹកនាំ ដែលជានិច្ចកាលលោក តែងតែឆ្លៀតពេលដ៏មានតម្លៃរបស់លោកក្នុងការផ្តល់គំនិតការណែនាំ និងផ្តល់ទាំងកម្លាំងចិត្ត កម្លាំងកាយ បញ្ញាស្មារតី សម្ភារ បច្ចេកទេស វិធីសាស្រ្តផ្សេងៗ មិនតែប៉ុណ្ណោះលោកបានជួយផ្តល់ជាឯកសារផ្សេងៗទាក់ទងនឹងប្រធានបទព្រមទាំងជួយបង្ហាញទិសដៅនៃការស្រាវជ្រាវប្រកបដោយគតិបណ្ឌិតដល់រូបខ្ញុំ រហូតដល់ការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យជាស្ថាពរ។

-ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក **ចាប រតនា** ជាសាស្រ្តាចារ្យដឹកនាំរង ដែលលោកតែងតែឆ្លៀតពេលដ៏មានតម្លៃរបស់លោកក្នុងការផ្តល់គំនិតការណែនាំ និងផ្តល់វិធីសាស្រ្តផ្សេងៗ មិនតែប៉ុណ្ណោះ លោកបានជួយប្រាប់ពីប្រភពដើម្បីស្វែងរកឯកសារផ្សេងៗទាក់ទងនឹងប្រធានបទ ព្រមទាំងជួយបង្ហាញទិសដៅនៃការស្រាវជ្រាវប្រកបដោយគតិបណ្ឌិតដល់រូបខ្ញុំហូតដល់ការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យជាស្ថាពរ។

-ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តម លោក លោកស្រី ដែលជាថ្នាក់ដឹកនាំ និងជាមន្ត្រីរាជការទាំងអស់ នៃវិទ្យាស្ថានជាតិអប់រំដែលបានផ្តល់ទីតាំង និងបានសម្របសម្រួលដល់ដំណើរការនៃការបណ្តុះបណ្តាលក្នុងវគ្គនេះប្រកបដោយជោគជ័យគួរជាទីមោទនៈ។

-ខ្ញុំសូមថ្លែងអំណរគុណចំពោះ លោក លោកស្រី សាស្ត្រាចារ្យ នៃវិទ្យាស្ថានជាតិអប់រំទាំងអស់ដែលបានខិតខំអស់ពីកម្លាំងកាយចិត្ត សម្ភារ ក្នុងការផ្តល់ពុទ្ធិ ចំណេះធ្វើ ឥរិយាបថ ពិសេសផ្តល់ជាទ្រឹស្តីបទពិសោធន៍ល្អដែលទាំងនេះជាចំណេះដឹងមួយដ៏សំខាន់ និងចាំបាច់បំផុតសម្រាប់អនុវត្ត ព្រមទាំងឆ្លុះបញ្ចាំងពីការអនុវត្តការងារបច្ចុប្បន្ន ។

-ខ្ញុំសូមអំណរគុណចំពោះលោកនាយក នាយករង លោកគ្រូ អ្នកគ្រូ នៅកម្រិតបឋមសិក្សាទាំងអស់ក្នុងខេត្តស្វាយរៀង ដែលបានផ្តល់ព័ត៌មានយ៉ាងលម្អិត និងគ្រប់ជ្រុងជ្រោយចំពោះការសម្ភាសន៍យកព័ត៌មានមកសរសេរក្នុងនិក្ខេបបទនេះ រហូតបានបញ្ចប់ជាស្ថាពរ។

ជាទីបញ្ចប់នេះ ខ្ញុំបាទសូមគោរពជូនពរ និងប្រសិទ្ធិពរ លោកអ្នកមានគុណទាំងពីរ ឯកឧត្តមលោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងឯកឧត្តមលោកជំទាវ លោកលោកស្រី ឯកឧត្តមបណ្ឌិត សាស្ត្រាចារ្យទាំងអស់ នៃវិទ្យាស្ថានជាតិអប់រំ សូមឱ្យជួបប្រទះនៃសេចក្តីសុខគ្រប់ប្រការ មានសុខភាពល្អ សម្រេចជោគជ័យគ្រប់ភារកិច្ច និងទទួលបាននូវពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

*សូមអរគុណ!!!*

# មូលន័យសង្ខេប


សុខភាពរបស់អ្នកសិក្សា គឺជាកត្តាដ៏សំខាន់មួយដែលរួមចំណែកដល់ការធានាបាននូវការសិក្សា ប្រកបដោយ គុណភាពនិងបង្កើនអត្រាបញ្ចប់ការសិក្សាសុខភាព និងអាហារូបត្ថម្ភជួយបង្កើនកម្រិតវៃឆ្លាតរបស់កុមារ ក៏ដូចជាការចូលរួមយ៉ាងសកម្មក្នុងសកម្មភាពរៀន ជាពិសេស ជួយបង្កើនអត្រាគង់វង្សរបស់សិស្សក្នុងការសិក្សា ដើម្បីសម្រេចចក្ខុវិស័យ ក្នុងការប្រែក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងទៅជាប្រទេស ដែលមានប្រាក់ចំណូលខ្ពស់ក្នុងឆ្នាំ ២០៥០ ព្រះរាជាណាចក្រកម្ពុជាត្រូវការចាំបាច់នូវធនធានមនុស្ស ប្រកបដោយគុណភាពនិងផលិតភាពការងារខ្ពស់ ដែលសំដៅលើធនធានមនុស្សដែលប្រកបដោយ វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងសុខភាពរឹងមាំ ។ នៅក្នុងដំណើរវិវត្តនៃការងារសុខភាពសិក្សា ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឱ្យអនុវត្តកម្មវិធីជាច្រើនមានដូចជា មុខវិជ្ជាអប់រំសុខភាពដាច់ដោយឡែក រយៈពេល ១ ម៉ោងក្នុង១សប្តាហ៍ ពីថ្នាក់ទី១ដល់ទី១២ គោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមាស្តីពីទឹកស្អាត និងអនាម័យនៅតាមគ្រឹះស្ថានសិក្សា គោលការណ៍ណែនាំស្តីពីការវាស់គំហើញនៅតាមគ្រឹះស្ថានសិក្សា សេវាសង្គ្រោះបឋម បន្ទប់សុខភាព ការពិនិត្យសុខភាព និងកាយសម្បទា គោលការណ៍ណែនាំស្តីពីសុវត្ថិភាពចំណីអាហារ អាហារូបត្ថម្ភ និងចំណីអាហារប្រកបដោយសុខភាពនៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅ គោលការណ៍ប្រតិបត្តិស្តីពីការសង្គ្រោះសុខភាពផ្លូវចិត្តបឋមនៅតាមគ្រឹះស្ថានសិក្សា ព្រមទាំងគោលការណ៍ប្រតិបត្តិស្តង់ដាសម្រាប់ដំណើរការគ្រឹះស្ថានសិក្សាប្រកបដោយសុវត្ថិភាព ។

ដើម្បីឆ្លើយតបនឹងបញ្ហានេះ នាយកដ្ឋានសុខភាពសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការសុខភាពពិភពលោក និងដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ទាំងស្ថាប័នជាតិ អន្តរជាតិទ្វេភាគី ពហុភាគី និងសង្គមស៊ីវិល បានផ្តួចផ្តើមអភិវឌ្ឍ "គោលការណែនាំប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅ"នេះឡើង។

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងពីរគឺៈ (១) ឈ្វេងយល់ពីស្ថានភាពបច្ចុប្បន្ននៃការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សានៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង (២) លើកជាយុទ្ធសាស្ត្រដើម្បីពង្រឹងការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សាឱ្យមានប្រសិទ្ធភាព ។ ស្រាវជ្រាវសម្រេចជ្រើសរើសសាលាសំណាកដោយបែងចែកជាពីរក្រុមគឺៈ (១)សាលានៅទីប្រជុំជន (២)សាលានៅទីជនបទ សរុបទិន្នន័យសាលាសំណាកក្នុងទីប្រជុំជនមានចំនួន ៨សាលា និងទីជនបទមានចំនួន ៨សាលា ទិន្នន័យសាលាសំណាកជាទម្រង់ Microsoft Excel រួចយកមក Random ដោយប្រើរូបមន្ត=Rand( )យកតម្លៃពិន្ទុណាដែលខ្ពស់ជាងគេ នោះជាសាលាសំណាកដែលបានចាប់យកសំណាក ដំណើរការជ្រើសរើសសំណាកដំបូងអ្នកស្រាវជ្រាវជ្រើសរើសសាលានៅទីប្រជុំជន១សាលា ក្នុងទីរួមស្រុកនីមួយៗដោយស្វ័យប្រវត្តិ លើកលែងតែក្រុងស្វាយរៀងមានសាលាទីប្រជុំជនចំនួន១៤សាលា និងក្រុងបាវិតមានចំនួន៣សាលា អ្នកស្រាវជ្រាវប្រើវិធី Random ដើម្បីចាប់យកសាលាសំណាកនេះ។ ការចុះប្រមូលទិន្នន័យអ្នកស្រាវជ្រាវបានធ្វើការសម្ភាសន៍ជាមួយគណៈគ្រប់គ្រងចំនួន១៨សាលា ហើយការបំពេញកម្រងសំណួរដោយគ្រូ និងសិស្ស អ្នកស្រាវជ្រាវជ្រើសចំនួនតាមសមាមាត្រក្នុងទ្រឹស្តីរបស់លោក Carrol Yamane ដែលមានកម្រិតលំអៀង 0.0៥ (មើលតារាងទី១) ។ នៅទីប្រជុំជនមានគ្រូចំនួន៩៥ នាក់ និងគ្រូនៅទីជនបទចំនួន៤៧ នាក់ធ្វើការបំពេញកម្រងសំណួរ ចំណែកសិស្សទីប្រជុំជនចំនួន២៦៤នាក់ និងសិស្សនៅទីជនបទចំនួន១១២នាក់ ចំពោះការប្រមូលទិន្នន័យសិស្សផងដែរអ្នកស្រាវជ្រាវសម្រេចជ្រើសរើសក្នុងចំណោមសិស្សថ្នាក់ទី៤ ទី៥ និងទី៦ ដោយវិធីចាប់យកដោយចៃដន្យដើម្បីកុំឱ្យមានភាពលម្អៀង។

លទ្ធផលការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកម្ពស់សុខភាពសិក្សាបានបង្ហាញថានៅទីប្រជុំជនស្តង់ដាទី១ៈ អនុវត្តបាន ៥៦.0៥% និងទីជនបទ ៤៩.២៩% ស្តង់ដាទី២ៈ ៣៦.៩១% ៣0.៤៤% ស្តង់ដាទី៣ៈ ទីប្រជុំជន៤៧.៩៤% ៤២.៣៣% ស្តង់ដាទី៤ៈ ៧៥.១៧% ៧៦.៥៨% ស្តង់ដាទី៥ៈ ទីប្រជុំជន ៧៥.៩២% ទីជនបទ ៧៣.៧១% ស្តង់ដាទី៦ៈ ទីប្រជុំជន ៩.0៨% ទី

ជនបទ ១.១៧% ស្តង់ដាទី៧៖ ទីជនបទ ១៦.៨៣% ទីជនបទ 0.00% ស្តង់ដាទី៨៖ ទីប្រជុំជន ៨២.៥0% ទីជនបទ ៦៥.៨៣% ស្តង់ដាទី៩៖ ទីប្រជុំជន ១៦.៥0% ទីជនបទ 0.00% ។

ជារួមតាមរយៈលទ្ធផលទិន្នន័យខាងលើបង្ហាញឱ្យឃើញថា លទ្ធផលដែលអនុវត្តស្តង់ដាសុខភាពសិក្សារវាងទីប្រជុំជន និងទីជនបទបានក្នុងកម្រិតទាបដូចគ្នាលើស្តង់ដាទី២ ស្តង់ដាទី៣ ស្តង់ដាទី៦ ស្តង់ដាទី៧ និងស្តង់ដាទី៩ ចំណែកស្តង់ដាទី១អនុវត្តបានកម្រិតមធ្យម និងស្តង់ដាទី៤ ទី៥ ទី៨ បានអនុវត្តលើមធ្យម តែនៅជាចំណុចមួយដែលតម្រូវឱ្យមានការកែលម្អបន្ទាន់នៅឆ្នាំសិក្សាៗក្រោយទៀត។

# Abstract

The health of students is an important factor that contributes to ensuring quality education and increasing graduation rates. Health and nutrition help increase children's intelligence level, as well as actively participate in learning activities, especially Increase student survival rates to achieve the vision of becoming a high middle-income in 2030 and a high-income 2050. In the development of health education, the Ministry of Education, Youth and Sports has implemented a number of programs, such as separate health education for one hour per week from grades 1 to 12, guidelines for applying minimum conditions on clean water and Institutional hygiene Institutional vision measurement guidelines First aid services Health rooms Health and fitness examinations Safety guidelines Nutrition, Nutrition and Health Food in General Education Institutions, Principles of Primary Mental Health Relief in Institutions, as well as Standards of Practice for Safe Institutions.

In results of the implementation of the standard practice on the promotion of health education show that in urban standards 1: 56.05% and in rural areas 49.29% , Standard 2: 36.91% 30.44% 3: Urban 47.94% 42.33% , Standard 4: 75.17% 76.58% , Standard 5: Urban 75.92% Rural 73.71% , Standard 6: Urban 9 .08% Rural 1.17% , Standard 7: Rural 16.83% Rural 0.00% , Standard 8: Urban 82.50% Rural 65.83% , Standard 9: Urban 16.50% Rural 0.00%.

Together with the above results, it shows that the results that implement the quality of education in urban and rural areas are at the lowest level in standard 2$^{nd}$ 3$^{rd}$ 6$^{th}$ 7$^{th}$ and 9$^{th}$ but standard 1$^{st}$ in intermediate levels and 4$^{th}$ 5$^{th}$ 8$^{th}$ above intermediate level. It is also school make sure try commitment and strong implementation than this a point that requires immediate improvement in the next school year.

# មាតិកា


សេចក្តីប្រកាសអះអាងរបស់បេក្ខជន ....... i

សេចក្តីបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ ....... ii

លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ ....... iii

សេចក្តីថ្លែងអំណរគុណ ....... vii

មូលន័យសង្ខេប ....... ix

Abstract ....... xii

ជំពូក១៖ ....... 1

សេចក្តីផ្តើម ....... 1

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ....... 1

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ....... 15

១.៣ គោលបំណងនៃការស្រាវជ្រាវ ....... 16

១.៤ សំណួរស្រាវជ្រាវ ....... 17

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ....... 17

១.៦ ដែនកំណត់នៃការស្រាវជ្រាវ ....... 18

១.៦.១ វិសាលភាពនៃការស្រាវជ្រាវ ....... 18

១.៦.២ ដែនកំណត់នៃការស្រាវជ្រាវ ....... 18

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ....... 18

ជំពូក២៖ ....... 20

រំលឹកទ្រឹស្តី ....... 20

២.១ ពាក្យគន្លឹះ ....... 20

២.២ ស្តង់ដាលើកកម្ពស់សុខភាពសិក្សា ....... 21

២.២.១ ស្តង់ដាទី១៖ ការអភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការ ....... 21

២.២.២ ស្តង់ដាទី២៖ ការលើកកម្ពស់សុខភាពចាំបាច់ដល់គ្រូបង្រៀន និងសិស្ស ..........22
២.២.៣ ស្តង់ដាទី៣៖ ការលើកកម្ពស់ការផ្តល់អាហារូបត្ថម្ភ ..........24
២.២.៤ ស្តង់ដាទី៤៖ ការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ..........26
២.២.៥ ស្តង់ដាទី៥៖ ការលើកកម្ពស់បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាបន្ន ជាសុខភាព និងមេត្រីភាព ..........28
២.២.៦ ស្តង់ដាទី៦៖ ការលើកកម្ពស់សន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងសាលា ..........28
២.២.៧ ស្តង់ដាទី៧៖ ការលើកកម្ពស់ការអប់រំសុខភាព ..........30
២.២.៨ ស្តង់ដាទី៨៖ ការលើកកម្ពស់ការអនុវត្តបំណិនសុខភាព ..........31
២.២.៩ ស្តង់ដាទី៩៖ ការលើកកម្ពស់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងអភិវឌ្ឍ កម្មវិធីសុខភាពសិក្សា ..........33
**ជំពូក៣៖** ..........35
**វិធីសាស្ត្រស្រាវជ្រាវ** ..........35
**៣.១ គម្រោងវិភាគ** ..........35
**៣.២ ការប្រមូលទិន្នន័យ** ..........36
**៣.៣. ឧបករណ៍ស្រាវជ្រាវ** ..........36
**៣.៤. ការជ្រើសរើសភាគសំណាក** ..........37
**៣.៥. ការវិភាគទិន្នន័យ** ..........38
**៣.៦. ក្រមសីលធម៌នៃអ្នកស្រាវជ្រាវ** ..........39
**ជំពូក៤៖** ..........40
**លទ្ធផលស្រាវជ្រាវ និងការពិភាក្សា** ..........40
**៤.១.ទិន្នន័យទូទៅមុនប្រមូលទិន្នន័យ** ..........40
៤.១.១.ព័ត៌មានទូទៅរបស់សាលាសំណាក ..........40
៤.១.២.ព័ត៌មានទូទៅពីអ្នកចូលរួមផ្តល់ទិន្នន័យសម្ភាសន៍ និងបំពេញកម្រងសំណួរ ..........41

**៤.២ ឧបករណ៍ប្រមូលទិន្នន័យ** ........ 42
៤.២.១ កម្រងសំណួរ ........ 42
៤.២.២ កម្រងសំណួរសម្ភាសន៍នាយក ........ 42
៤.២.៣ កម្រងសំណួរបំពេញដោយគ្រូ និងសិស្ស ........ 43
**៤.៣ លទ្ធផលនៃការអនុវត្តតាមស្តង់ដា** ........ 43
៤.៣.១ ការអនុវត្តស្តង់ដាទី១៖ ការអភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ ........ 43
៤.៣.២ ការអនុវត្តស្តង់ដាទី២៖ ការលើកកម្ពស់សុខភាពចាំបាច់ដល់គ្រូបង្រៀននិងសិស្ស ........ 45
៤.៣.៣ ការអនុវត្តស្តង់ដាទី៣៖ ការលើកកម្ពស់ការផ្តល់អាហារូបត្ថម្ភ ........ 46
៤.៣.៤ ការអនុវត្តស្តង់ដាទី៤៖ ការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ........ 48
៤.៣.៥ ការអនុវត្តស្តង់ដាទី៥៖ ការលើកកម្ពស់បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាបន្ន ជាសុខភាព និងមេត្រីភាព ........ 50
៤.៣.៦ ការអនុវត្តស្តង់ទី៦៖ ការលើកកម្ពស់សន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងសាលា ........ 52
៤.៣.៧ ការអនុវត្តស្តង់ទី៧៖ ការលើកកម្ពស់ការអប់រំសុខភាព ........ 54
៤.៣.៨ ការអនុវត្តស្តង់ទី៨៖ ការលើកកម្ពស់ការអនុវត្តបំណិនសុខភាព ........ 55
៤.៣.៩ ការអនុវត្តស្តង់ទី៩៖ ការលើកកម្ពស់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍកម្មវិធីសុខភាពសិក្សា ........ 57
**៤.៤ ការពិភាក្សា** ........ 58
**ជំពូក៥៖** ........ 65
**សេចក្តីសន្និដ្ឋាន និងសំណូមពរ** ........ 65
**៥.១.សេចក្តីសន្និដ្ឋាន** ........ 65
**៥.២.សំណូមពរ** ........ 65
**ឯកសារយោង** ........ 69

**ឧបសម្ព័ន្ធទី១** ........ 72
**លិខិតបង្គាប់ការរបស់គណៈកម្មការការពារនិក្ខេបបទ** ........ 72
**ឧបសម្ព័ន្ធទី២** ........ 79
**លិខិតចាត់តាំងគ្រូដឹកនាំគោល និងគ្រូដឹកនាំរង សម្រាប់ការសរសេរ និក្ខេបបទ** 79
**ឧបសម្ព័ន្ធទី៣** ........ 81
**លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា** ........ 81
**ឧបសម្ព័ន្ធទី៤ កម្រងសំណួរ** ........ 83

# ជំពូក១

# សេចក្ដីផ្ដើម

# ជំពូក១៖
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

សុខភាពរបស់អ្នកសិក្សា គឺជាកត្តាដ៏សំខាន់មួយដែលរួមចំណែកដល់ការធានាបាននូវការសិក្សា ប្រកបដោយ គុណភាពនិងបង្កើនអត្រាបញ្ចប់ការសិក្សា សុខភាព និងអាហារូបត្ថម្ភជួយបង្កើនកម្រិតវៃឆ្លាតរបស់កុមារ ក៏ដូចជាការចូលរួមយ៉ាងសកម្មក្នុងសកម្មភាពរៀន ជាពិសេស ជួយបង្កើនអត្រាគង់វង្សរបស់សិស្សក្នុងការសិក្សា ។ ផ្ទុយទៅវិញ កង្វះអាហារូបត្ថម្ភនិងបញ្ហាសុខភាពបានក្លាយជាឧបសគ្គ ចម្បងមួយរារាំងកុមារមិនឱ្យទទួលបាននូវការសិក្សាល្អប្រសើរនៅក្នុងអំឡុងសិក្សា ដោយមើលឃើញពីសារៈសំខាន់និងផលប៉ះពាល់ទាំងនេះ ប្រទេសជាច្រើននៅលើសាកលលោកបានផ្តោតការយកចិត្តទុកដាក់ដល់ការលើកកម្ពស់សុខភាពសិក្សាតាមរយៈការបង្កើតជាគោលនយោបាយ និងយុទ្ធសាស្រ្តជាតិ សំដៅធ្វើយ៉ាងណាបង្កើនកិច្ចសហការ និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។ មិនខុសពីបរិបទសាកល រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានយល់ច្បាស់អំពីសារៈសំខាន់ និងផលប៉ះពាល់នៃសុខភាពសិក្សាលើការអភិវឌ្ឍធនធានមនុស្សនិងសេដ្ឋកិច្ច ដើម្បីសម្រេចចក្ខុវិស័យក្នុងការប្រែក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងទៅជាបទេស ដែលមានប្រាក់ចំណូលខ្ពស់ក្នុងឆ្នាំ២០៥០ ព្រះរាជាណាចក្រកម្ពុជាត្រូវការចាំបាច់នូវធនធានមនុស្ស ប្រកបដោយគុណភាពនិងផលិតភាពការងារខ្ពស់ ដែលសំដៅលើធនធានមនុស្សដែលប្រកបដោយ វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងសុខភាពរឹងមាំ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការលើកកម្ពស់សុខភាពសិក្សា ដោយបានរៀបចំជាសំណុំយុទ្ធសាស្រ្តនិងសកម្មភាពអន្តរកម្មរវាងគ្រឹះស្ថានសិក្សា និងសេវាកម្មសុខភាពនានា និងលើកកម្ពស់ការអប់រំសុខភាពបង្ការជំងឺ ផ្តល់សេវាសុខភាពចាំបាច់ លើកកម្ពស់អនាម័យ បរិស្ថាន និងផ្គត់ផ្គង់ទឹកស្អាតដល់បុគ្គលិកអប់រំ និងអ្នកសិក្សា ជាដំណាក់កាលៗ ។ រាជរដ្ឋាភិបាលតាមរយៈក្រសួងអប់រំ យុវជន និងកីឡា ដែលជាសេនាធិការ បានយកចិត្តទុកដាក់ផ្តល់សេវាអប់រំដល់កុមារនិងបានរៀបចំឱ្យមានវិធានការទប់ស្កាត់

រាល់អំពើហិង្សានៅតាមសាលារៀន សំដៅគាំពារកុមារឱ្យមានសុខភាពល្អទាំងផ្លូវកាយនិងផ្លូវចិត្ត មានសុវត្ថិភាពនៅក្នុងសាលារៀន គ្រួសារ និងសង្គម ដោយមានការជួយគាំទ្រពីគ្រប់ភាគីអ្នកពាក់ព័ន្ធ។ ចាប់តាំងពីឆ្នាំ២០០៦មក ក្រសួងអប់រំ យុវជន និងកីឡា បានពង្រឹងការយល់ដឹងអំពីបញ្ហាសុខភាព លើកកម្ពស់សុខភាពអ្នកសិក្សានិងបុគ្គលិកអប់រំ និងកៀរគរឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការលើកកម្ពស់និងទទួលបានសេវាអប់រំសុខភាពប្រកបដោយសមធម៌ (**រាជរដ្ឋាភិបាលកម្ពុជា, ២០១៩**) ។

ការលើកកម្ពស់សុខភាពសិក្សា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ស្តីពីការអប់រំនៅកម្ពុជា "គុណភាព សមធម៌ បរិយាបន្ន សម្រាប់អប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ និងការសិក្សាពេញមួយជីវិត ដើម្បីបង្កើនប្រសិទ្ធភាព គុណភាព ផលិតភាព ការងារ ស្របតាមយុគសម័យបច្ចេកទេស ឌីជីថល ក្នុងការបង្កើនសេដ្ឋកិច្ច និងសុខុដុម ជីវិតបុគ្គល និងសង្គម" បុគ្គលិកអប់រំ និងអ្នកសិក្សាត្រូវមានសុខភាពល្អ នឹងចូលរួមយ៉ាងសកម្មក្នុងសកម្មភាពរៀននិងបង្រៀន ជាពិសេសជួយបង្កើនអត្រាគង់វង្ស និងបង្កើនភាពវៃឆ្លាតរបស់អ្នកសិក្សា ផ្ទុយទៅវិញ បើសុខភាពមានបញ្ហានឹងក្លាយជាឧបសគ្គចម្បងមួយរារាំងការទទួលបាននូវការសិក្សាល្អប្រសើរនៅក្នុងអំឡុងពេលសិក្សា ប្រការនេះបានបង្ហាញកាន់តែច្បាស់ក្នុងអំឡុងពេលការរាតត្បាតសកលនៃជំងឺកូវីដ-១៩ (**ក្រសួងអប់រំ យុវជន និងកីឡា [អ.យ.ក], ២០២២**) ។

ការអនុវត្តកម្មវិធីសុខភាពសិក្សានៅកម្ពុជាមានការវិវត្តជាជំហានៗ ស្របទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នៅមុំទី១ស្តីពីការអភិវឌ្ឍធនធានមនុស្ស និងមុំទី៣ស្តីពីការលើកកម្ពស់សេវាសុខភាពសាធារណៈនិងអាហារូបត្ថម្ភ ក្នុងគោលបំណង អភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព បង្កើនផលិតភាពការងារខ្ពស់ សុខភាពរឹងមាំ និងកំណើនសេដ្ឋកិច្ចឆ្ពោះទៅសម្រេចចក្ខុវិស័យប្រែក្លាយកម្ពុជាជាប្រទេសមានចំណូល មធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការលើកកម្ពស់សុខភាពសិក្សាដោយបានដាក់ចេញនូវគោលនយោបាយជាតិស្តីពីសុខភាពសិក្សា សំណុំយុទ្ធសាស្ត្រ និងសកម្មភាពអន្តរកម្មរវាងគ្រឹះស្ថានសិក្សា និងសេវាកម្មសុខភាពនានា តាមរយៈការផ្តល់ សេវាអប់រំសុខ

ភាព ការបង្ការជំងឺ ការបង្កើតបន្ទប់សុខភាព សេវាពិនិត្យសុខភាពនិងកាយសម្បទា សេវាសង្គ្រោះបឋម សេវាអាហារូបត្ថម្ភ សុវត្ថិភាពចំណីអាហារ និងអាហារប្រកប ដោយសុខភាព សេវាលើកកម្ពស់ អនាម័យបរិស្ថាន និងការផ្គត់ផ្គង់ទឹកស្អាតជាដើម។ ទោះបីមានគោលនយោបាយ គោលការណ៍ណែនាំ និងកម្មវិធីអន្តរាគមន៍ខាងលើនេះក៏ដោយ ក៏ការលើកកម្ពស់សុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សាមិនទាន់បានអនុវត្តគ្រប់ជ្រុងជ្រោយពេញលេញស្របទៅនឹងសេចក្តីត្រូវការនៅឡើយ។ ឆ្លើយតបនឹងបញ្ហាខាងលើនេះនាយកដ្ឋានសុខភាពសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការសុខភាពពិភពលោកបានផ្តួចផ្តើមបង្កើត "គោលការណ៍ណែនាំប្រតិបត្តិស្តង់ដា ស្តីពីការលើកកម្ពស់សុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សាចំណោះទូទៅ" នេះឡើងដើម្បីជាមគ្គុទេសក៍សម្រាប់អនុវត្តទាំងកម្រិតជាតិរហូតដល់គ្រឹះស្ថានសិក្សា។

នៅក្នុងដំណើរវិវត្តនៃការងារសុខភាពសិក្សា ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឱ្យអនុវត្តកម្មវិធីជាច្រើនមានដូចជា មុខវិជ្ជាអប់រំសុខភាពដាច់ដោយឡែក រយៈពេល ១ម៉ោងក្នុង១សប្តាហ៍ពីថ្នាក់ទី១ដល់ទី១២ គោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមា ស្តីពីទឹកស្អាតនិងអនាម័យនៅតាមគ្រឹះស្ថានសិក្សា គោលការណ៍ណែនាំស្តីពីការវាស់គំ ហើញនៅតាមគ្រឹះស្ថានសិក្សា សេវាសង្គ្រោះបឋម បន្ទប់សុខភាព ការពិនិត្យសុខភាព និងកាយសម្បទា គោលការណ៍ណែនាំស្តីពីសុវត្ថិភាពចំណីអាហារ អាហារូបត្ថម្ភនិងចំណី អាហារប្រកបដោយសុខភាពនៅតាមគ្រឹះស្ថានសិក្សាចំណោះទូទៅ គោលការណ៍ប្រតិបត្តិស្តីពីការសង្គ្រោះសុខភាពផ្លូវចិត្តបឋមនៅតាមគ្រឹះស្ថានសិក្សា ព្រមទាំងគោលការណ៍ ប្រតិបត្តិស្តង់ដាសម្រាប់ដំណើរការគ្រឹះស្ថានសិក្សាប្រកបដោយសុវត្ថិភាព ក្នុងបរិបទជំងឺកូ វីដ-១៩ ជាដើម ។ ទន្ទឹមនឹងនេះ ដោយសារគ្រឹះស្ថានសិក្សានីមួយៗមានស្ថានភាពខុសៗគ្នាទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ធនធានមនុស្ស និងមធ្យោបាយគាំទ្រផ្សេងៗ ធ្វើឱ្យការអនុវត្ត សកម្មភាពជាក់ស្តែងនៃការងារសុខភាពសិក្សា នៅកម្រិតគ្រឹះស្ថានសិក្សាមានភាពមិនដូចគ្នាឡើយ។ ដើម្បីឆ្លើយតបនឹងបញ្ហានេះ នាយកដ្ឋានសុខភាពសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការសុខភាពពិភពលោក និងដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ទាំងស្ថាប័នជាតិ អន្តរជាតិទ្វេភាគី ពហុភាគី និងសង្គមស៊ីវិល

បានផ្តួចផ្តើមអភិវឌ្ឍ "គោលការណែនាំប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅ"នេះឡើង។

នៅក្នុងដំណាក់កាលកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំយុទ្ធសាស្ត្រស្តីពីការបើកដំណើរការគ្រឹះស្ថានសិក្សាឡើងវិញ ដោយឈរលើអភិក្រមពីរគឺ ១.ការបើកតាមដំណាក់កាលសម្រាប់គ្រឹះស្ថានសិក្សាណាដែលអាចអនុវត្ត «ស្តង់ដា សុវត្ថិភាពសុខភាព» និង ២.ការបន្តការសិក្សាតាមបែបចម្រុះ ដោយគួបផ្សំការសិក្សាក្នុងថ្នាក់រៀន និងការសិក្សាពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិកនិងតាមបែបប្រពៃណីរួមទាំងការធ្វើស្វ័យសិក្សា(សម្រាប់សិស្សនៅទីជនបទ)។ គោលការណ៍ប្រតិបត្តិស្តង់ដាសម្រាប់ដំណើរការសាលារៀនឡើងវិញក្នុងបរិបទកូវីដ-១៩ ដែលបានរៀបចំឡើង មានវត្ថុបំណងណែនាំអំពីវិធាននានា រួមទាំងវិធានការសុខាភិបាលដើម្បីគ្រឹះស្ថានសិក្សាអាចរៀបចំ និងត្រៀមលក្ខណៈដំណើរការការបង្រៀននិងរៀនឡើងវិញ ក៏ដូចជាការបន្តអភិវឌ្ឍគ្រឹះស្ថានសិក្សានីមួយៗឱ្យមាននិរន្តរភាព ធានាបាននូវសុវត្ថិភាព សុខភាពសម្រាប់បុគ្គលិកសិក្សា គ្រូបង្រៀន និងសិស្សានុសិស្សក្នុងបរិបទកូវីដ១៩ និងទៅអនាគត។ ក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការគ្រប់គ្រង បង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ដើម្បីធានាសុវត្ថិភាព និងសុខុមាលភាពរបស់ សិស្សានុសិស្ស និងបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់។ ចាប់តាំងពីរកឃើញករណីការឆ្លងជំងឺកូវីដ១៩ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវវិធានការជាច្រើន ដូចជាចេញសេចក្តីជូនដំណឹង និងសេចក្តីណែនាំជាច្រើន ដែលពាក់ព័ន្ធនឹង ១.វិធានការសុខភាព ដោយអនុលោមទៅតាមសេចក្តីណែនាំ និងវិធានការបច្ចេកទេសចាំបាច់ របស់អង្គការសុខភាពពិភពលោក និងក្រសួងសុខាភិបាល ២.ការរៀបចំរដ្ឋបាលឱជីថល ៣. ការលើកកម្ពស់ វិធានការគម្លាតសុវត្ថិភាព និង៤. ការរៀបចំប្រព័ន្ធអប់រំអេឡិចត្រូនិក និងការផ្តល់សេវារៀនពីចម្ងាយ **(អ.យ.ក, ២០២០)** ។

ការអប់រំសុខភាព ត្រូវបានអនុវត្តជាយូរមកហើយ តាមរយៈការបញ្ជ្រាបទៅក្នុងមុខវិជ្ជាពាក់ព័ន្ធនានា។ ដោយយល់ពីភាពចាំបាច់នៃការបង្រៀនមុខវិជ្ជាអប់រំសុខភាព ទើបនៅចុងឆ្នាំ២០១៥ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ ឱ្យប្រើប្រាស់ម៉ោងដោយឡែក សម្រាប់មុខវិជ្ជាអប់រំសុខភាពក្នុង

កម្មវិធីសិក្សាជាតិ ។ ប្រទេសជាច្រើននៅសកលលោក បានទទួលស្គាល់ថាសុខភាព ជាកត្តាសំខាន់និងចាំបាច់ដែលមិនអាចខ្វះបានទាំងសុខភាពផ្លូវចិត្ត និងសុខភាព ផ្លូវកាយក្នុងជីវភាពរស់នៅប្រចាំថ្ងៃដើម្បីធ្វើឱ្យជីវិតរស់នៅកាន់តែប្រសើរឡើង។ បច្ចុប្បន្នសកលលោកមានការអភិវឌ្ឍ ទាំងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងស្មារតីមនុស្សជាតិ ប្រទេសជាច្រើនបានទទួលស្គាល់ថាអភិក្រម ឬបាតុភូតនៃសង្គមបានផ្តោតទៅគម្រោងកម្មវិធីសិក្សាថ្មីដែលមានលក្ខណៈទន់ភ្លន់ ។ ទស្សនៈវិជ្ជាអប់រំថ្មីមានទំនោរកំណត់បញ្ចូលលទ្ធផល សិក្សាជាគោលបំណងចម្បងក្នុងការអភិវឌ្ឍកម្មវិធីសិក្សាថ្មី។ បញ្ញត្តិនៃកម្មវិធីសិក្សាបានធ្វើឱ្យមានការផ្លាស់ប្តូរ ទស្សនៈ គោលគំនិត គរុកោសល្យ និងវិធីសាស្ត្របង្រៀនឱ្យសិស្សរៀនតាមបែបរិះរកគឺបង្រៀនសិស្ស ឱ្យចេះរៀនដោយខ្លួនឯង ដោយយកសកម្មភាពសិស្សជាគោល (សិស្សមជ្ឈមណ្ឌល) ពីការផ្ទេរពុទ្ធិមកជាការស្ថាបនាពុទ្ធិដោយខ្លួនឯងនិង អភិវឌ្ឍបំណិន សមត្ថភាពសិស្សដើម្បីឱ្យពួកគេស្រឡាញ់ការសិក្សាពេញមួយជីវិត ព្រមទាំងធានានូវគុណភាពអប់រំ សម្រាប់ទាំងអស់គ្នាក្រសួងអប់រំ យុវជននិងកីឡាបានដាក់បញ្ចូលមុខវិជ្ជាអប់រំសុខភាពទៅក្នុងកម្មវិធីសិក្សា ជាតិមានសារសំខាន់ក្នុងការផ្តល់ឱ្យសិស្ស គ្រូនូវចំណេះដឹង ជំនាញនិងឥរិយាបថត្រឹមត្រូវចាំចាច់សម្រាប់ការថែទាំសុខភាពសិស្ស គ្រូ តាមរយៈការអនុវត្តក្បួនអនាម័យ និងបរិស្ថានស្អាតដើម្បីកាត់បន្ថយជំងឺឆ្លង ជំងឺមិនឆ្លង និងលើកកម្ពស់ការរស់នៅប្រកបដោយសុខភាព **(អ.យ.ក, ២០១៨)**។

ក្នុងប្រទេសកម្ពុជា មានសាលារៀនទូទាំងប្រទេសចំនួន ៥៨.៧% គ្មានទឹកប្រើប្រាស់ ៣៦.០០% គ្មានបង្គន់អនាម័យ ក្នុងនោះបឋមសិក្សា៥៧.៧% គ្មានទឹកប្រើប្រាស់ និង២២.៥% គ្មានបង្គន់អនាម័យ រីឯនៅមធ្យមសិក្សាបឋមភូមិ ៦៩.៦% គ្មានទឹកប្រើប្រាស់ និង ៤០.៤% គ្មានបង្គន់អនាម័យ និងនៅមធ្យមសិក្សាទុតិយភូមិ ៣៧.២% គ្មានទឹកប្រើប្រាស់ និង ១២.៩% គ្មានបង្គន់អនាម័យ ទាំងនេះធ្វើឱ្យប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់សុខភាពរបស់សិស្ស និងបុគ្គលិកអប់រំ ជាដើមចមនៃការធ្លាក់ចុះនូវលទ្ធផលសិក្សារបស់សិស្ស និងការបង្រៀនរបស់គ្រូ **(អ.យ.ក, ២០២១-២០២២)** ។

ក្នុងទិសដៅលើកកម្ពស់សុវត្ថិភាព និងសុខុមាលភាពរបស់អ្នកសិក្សា និងបុគ្គលិកអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីណែនាំជាបន្តបន្ទាប់ដូចជា សេចក្តីណែនាំលេខ ៣៦៧៣ អ

យក.សណន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការលើកកម្ពស់សុខភាព អនាម័យ និង សុវត្ថិភាពចំណីអាហារតាមសាលារៀន និងសេចក្តីណែនាំលេខ ១៨ អយក.សណន ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការលើកកម្ពស់សុវត្ថិភាពចំណីអាហារនិងអាហារប្រកបដោយសុខភាព នៅតាមគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន ។ ទោះជាយ៉ាងនេះក៏ដោយ ក្រសួងសង្កេតឃើញថា សិស្សានុសិស្សនៅតាមគ្រឹះស្ថានសិក្សាមួយចំនួន មានអាការៈពុលចំណីអាហារ ទន់ដៃទន់ជើង និងឈានទៅដួលសន្លប់។ តាមរបាយការណ៍របស់មន្ត្រីសុខាភិបាលបានឱ្យដឹងថា មូលហេតុនៃអាការៈខាងលើនេះ បណ្តាលមកពីការទទួលទានចំណីអាហារមិនមានសុវត្ថិភាព និងសុខុមាលភាព ការបរិភោគគ្មានតុល្យភាព ការគេងមិនគ្រប់គ្រាន់ បរិស្ថានសិក្សាខ្វះអនាម័យ ការខ្វះចន្លោះ ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យការលក់ដូរចំណីអាហារ និងការចាត់វិធានការអនុវត្តដែលមិនទាន់បានល្អប្រសើរនៅតាមគ្រឹះស្ថានសិក្សា។ ដើម្បីពង្រឹងការ អនុវត្តសេចក្តីណែនាំនានា ដែលបានដាក់ចេញកន្លងមក ពាក់ព័ន្ធនឹង ការលើកកម្ពស់សុវត្ថិភាព និងសុខុមាលភាពចំណីអាហារ អនាម័យ និងបរិស្ថានសិក្សានៅតាម គ្រឹះស្ថានសិក្សា ប្រកបដោយប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំបន្ថែមដូចខាងក្រោម ៖

ក- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ និងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាមានភារកិច្ច៖

ក.១- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវធ្វើការណែនាំលម្អិតបន្តដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សាក្រោមឱវាទ ក្នុងការពង្រឹងការអនុវត្តឱ្យបានហ្មត់ចត់នូវការលើកកម្ពស់ សុវត្ថិភាពនិងសុខុមាលភាពចំណី អាហារត្រូវជំរុញមន្ត្រីទទួលបន្ទុកការងារសុខភាពសិក្សា ក្នុងការពង្រឹងការគ្រប់គ្រង ការសម្រប សម្រួល ការអប់រំផ្សព្វផ្សាយ ការលើកកម្ពស់សុវត្ថិភាព និងសុខុមាលភាពចំណីអាហារ ដោយសហការជាមួយអ្នកពាក់ព័ន្ធត្រូវចាត់តាំងមន្ត្រីធ្វើការពិនិត្យតាមដានជាទៀងទាត់និងធ្វើរបាយការណ៍បូកសរុបលទ្ធផល ការអនុវត្តការលើកកម្ពស់សុវត្ថិភាព និងសុខុមាលភាពចំណីអាហារទៀងរាល់ឆមាស និងឆ្នាំសិក្សានីមួយៗ រួចផ្ញើជូននាយកដ្ឋានសុខភាពសិក្សា

នៃក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំសហការជាមួយអ្នកពាក់ព័ន្ធក្នុងការចុះអន្តរាគមន៍បន្ទាន់ដល់គ្រឹះស្ថានសិក្សាករណីមានពុលចំណីអាហារ ឬហានិភ័យសុខភាពផ្សេងទៀត **(អ.យ.ក,២០១៣)** ។

ឯកសារទស្សនាទានសុខភាពសិក្សាក្នុងបរិបទថ្មី បានបរិយាថាសុខភាពសិក្សាជាសុំណុំសកម្មភាពផ្សេងៗ សម្រាប់លើកកម្ពស់សុខភាពសិក្សាដែលជាសេចក្តីត្រូវការជាមូលដ្ឋាននៃផ្លូវកាយ ផ្លូវចិត្ត និងសង្គមអ្នកសិក្សា និងបុគ្គលិកអប់រំ ដោយផ្តោតចំបងជាសំណុំដូចជា៖ ការអភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការ ការលើកកម្ពស់សុខភាពចាំបាច់ដល់អ្នកសិក្សា និងបុគ្គលិកអប់រំ ការលើកកម្ពស់ផ្តល់អាហារូបត្ថម្ភ ការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ការលើកកម្ពស់បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាបន្ន ផាសុកភាព និងមេត្រីភាព ការលើកកម្ពស់សន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងគ្រឹះស្ថានសិក្សា ការលើកកម្ពស់ក្នុងការអប់រំសុខភាព ការលើកកម្ពស់ការអនុវត្តបំណិនសុខភាព និងការលើកកម្ពស់នៃការចូលរួមគ្រប់ភាគីពាក់ព័ន្ធ **(អ.យ.ក, ២០២៣)** ។

គម្រោងលើកកម្ពស់សេវាកម្ម សុខភាពសាលារៀនរបស់អង្គារខេប បានអនុវត្តកាលពីឆ្នាំ ២០១៣ ដោយអនុវត្តនូវវិធីសាស្ត្រ ដែលលើកកម្ពស់ការអភិវឌ្ឍអ្នកពាក់ព័ន្ធ ក្រុមប្រឹក្សាកុមារនៅវិទ្យាល័យហ៊ុនសែនស្គន់ បានចាប់ធ្វើសកម្មភាពរងមួយនៃការផ្តួចផ្តើមគំនិត ដើម្បីបង្កើតកន្លែងដែលគេអាចជួបប្រជុំគ្នា (សហព័ន្ធសិស្ស) និងគាំពារសិស្សឈឺនៅក្នុងសាលារៀន។ មានសិស្សជាច្រើននាក់មកពីទីឆ្ងាយធ្វើដំណើរដោយជិះកង់ពីផ្ទះរបស់ពួកគេមកសាលារៀន។ សិស្សជាច្រើនគឺជាកូនគ្រួសារក្រីក្រមានអាហារបរិភោគមិនគ្រប់គ្រាន់។ បន្ទាប់ពីពួកគេខំប្រឹងដោយប្រើកម្លាំងមួយចំនួនមានសុខភាពមិនល្អជួនកាលចុះខ្សោយកម្លាំង និងត្រូវការឈប់សម្រាក។ ដោយសារគ្មានការផ្គត់ផ្គង់ពីសាលារៀនចំពោះតម្រូវការទាំងនេះ ដែលជារឿយៗ គេត្រូវដេកក្នុងថ្នាក់រៀន ឬអង្គុយនៅបរិវេណក្រៅថ្នាក់។ ក្រុមប្រឹក្សាកុមារបានជួបម្ចាស់ជំនួយ ដែលបានសម្រេចចិត្តជួយគេដោះស្រាយតម្រូវការនេះរបស់សិស្ស។ ការទំនាក់ទំនងទាំងនេះហើយបានឈានដល់ការសាងសង់គ្លីនិកសុខភាព ដែលមានការផ្គត់ផ្គង់គ្រប់គ្រាន់នៅវិទ្យាល័យស្គន់ មានគិលានុបដ្ឋាយិកាពេញម៉ោងផ្តល់ដោយការិយាល័យសុខាបាល។ សកម្មភាពនេះគឺជាឧទាហរណ៍ មួយនៃការផ្តល់អំណាចឱ្យអ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍន៍ដោយមានសិស្សជាអ្នកផ្តួចផ្តើម

គំនិតទាំងស្រុង។ បន្ទប់សង្គ្រោះបឋមមួយបានចាប់ផ្តើមដំណើរការនៅខែកញ្ញា ឆ្នាំ២០១៣ នៅក្នុងវិទ្យាល័យ ហ៊ុន សែនស្គន់ ក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម។ នេះជាសមិទ្ធិផលលេចធ្លោមួយ ដែលបានបង្ហាញឱ្យឃើញការសម្រេចបានថ្មីមួយនៃកម្មវិធីសាលាកុមារមេត្រី ព្រោះកម្មវិធីនេះបានផ្តួចផ្តើមឡើងទាំងស្រុងដោយក្រុមប្រឹក្សាកុមារ។ ក្នុងន័យនេះវាបានឆ្លុះបញ្ចាំងឱ្យឃើញពីគំរូនៃទង្វើប្រកបដោយភាពម្ចាស់ការរបស់សាលារៀន និងសេចក្តីក្លាហានក្នុងការច្នៃប្រឌិតថ្មីៗ។ ក្នុងឆ្នាំសិក្សា២០១៤-២០១៥ បន្ទប់សង្គ្រោះបឋមរបស់សាលាបានផ្តល់សេវាសុខភាពជូនសិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងបុគ្គលិកសាលាសរុបប្រមាណ៧៥៨នាក់ (KAPE, 2013) ។

ការលើកកម្ពស់សុខភាពក្នុងសាលារៀន គឺជួយដោះស្រាយបញ្ហាការលូតលាស់នៃរាងកាយរបស់កុមារ ទាំងនេះមានដូចជា អគារមានផាសុកភាព មានខ្យល់ចេញចូល និងមានពន្លឺគ្រប់គ្រាន់ មានទឹកស្អាត មានបង្គន់អនាម័យ កន្លែងបោកគក់ ទីលានលេងកីឡា សួនច្បារសម្រាប់កុមារ មានម្លប់ដើមឈើ ការកែច្នៃធនធានដែលអាចកើតឡើងវិញ និងការចោលកាកសំណល់ សំរាមឱ្យបានត្រឹមត្រូវ ទ្រឹស្តីបានបរិយាយថាប្រសិនបើបរិយាកាសរាងកាយសមស្របសម្រាប់កុមារ នោះលក្ខខណ្ឌសម្រាប់សុខភាពត្រូវបានបង្កើតឡើងដែរ ដែលនឹងកាត់បន្ថយហានិភ័យនៃការរងរបួស និងជំងឺជាដើម ។ មានភ័ស្តុតាងដ៏ទូលំទូលាយដែលបង្ហាញថាបរិយាកាសរាងកាយមិនសមរម្យនឹងរួមចំណែកដល់សុខភាពមិនល្អ សាលារៀនដែលផ្តល់កន្លែងរីករាយ និងសន្តិភាពវានឹងបង្កើតឱ្យសិស្សជាមួយនិងលទ្ធផលសុខភាព និងការអប់រំបានប្រសើរឡើង បរិយាកាសនៅក្នុងសង្គម យុទ្ធសាស្ត្របំបាត់អំពើហិង្សាផ្លូវកាយ និងពាក្យសំដីអសីលធម៌ ជាកត្តាកំណត់អាកប្បកិរិយាសុខភាពល្អរបស់សិស្សក្នុងវ័យកុមារ រហូតដល់ពេញវ័យ (L. H. St Lege, 1999) ។

គ្រូបឋមសិក្សាត្រូវការយល់ដឹងអំពីសុខភាពរបស់អ្នកសិក្សាសំខាន់ៗមានបីចំណុចគឺ៖ ចំណេះដឹងពីទ្រឹស្តីនៃសុខភាព (ចំណេះដឹងអំពីសុខភាព អំពីជំងឺ អំពីទម្លាប់ដែលបង្កគ្រោះថ្នាក់) ទម្លាប់រស់នៅប្រចាំថ្ងៃ (របៀបរស់នៅដែលមានសុខភាពល្អ សុខភាពផ្លូវកាយ សុខភាពផ្លូវចិត្ត សមត្ថភាពក្នុងការផ្តល់ការគាំទ្រ ប្រយុទ្ធប្រឆាំងនឹងទម្លាប់ដែលបង្កគ្រោះថ្នាក់) និងរបៀបរស់នៅដែលមាន

សុខភាពល្អ (ការផ្សព្វផ្សាយ ដែលផ្តោតលើការអប់រំយុវជន និងការចែករំលែកបទពិសោធន៍) ។ ការស្វែងរកការអភិវឌ្ឍអក្ខរកម្មសុខភាពរបស់គ្រូបឋមសិក្សាគឺជាការចាំបាច់ ហើយគួរតែបង្កើនគុណវុឌ្ឍិឱ្យទាន់តាមកម្មវិធីសិក្សាដែលបានរៀបចំឡើងក្នុងគោលបំណងជួយអភិវឌ្ឍសមត្ថភាពចំណេះដឹងផ្នែកសុខភាព។ សាលាផ្តោតជាទម្លាប់នៃការយកចិត្តទុកដាក់លើសុខភាព បុគ្គលិកអប់រំចាំបាច់ក្នុងការអប់រំសិស្សឱ្យរស់នៅមានសុខភាពល្អ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមផ្នែកសុខភាព លោកគ្រូ អ្នកគ្រូ និងសហគមន៍ទាំងមូល ត្រូវតែដើរតួយ៉ាងសំខាន់ដោយចាប់ផ្តើមពីខ្លួនឯងមានទម្លាប់រស់នៅល្អប្រដោយផាសុកភាព ។ គ្រូបង្រៀនមានជំនាញ និងបទពិសោធន៍របៀបរស់នៅដែលមានសុខភាពល្អផ្ទាល់ខ្លួន នឹងការផ្សព្វផ្សាយរបៀបរស់នៅដែលមានសុខភាពល្អ អាចរួមចំណែកដល់ការបង្រៀនសិស្សឱ្យរស់នៅប្រកបដោយសុខភាពល្អ បង្កើនចំណេះដឹងផ្នែកសុខភាពដល់ពួកគេ (Lamanauskas, V., & Augienė D, 2019)។

នៅក្នុងប្រទេសឥណ្ឌូណេស៊ី អត្រាប្រេវ៉ាឡង់នៃធ្មេញ caries ចំពោះកុមារគឺខ្ពស់ណាស់ ស្ថានភាពសុខភាពមាត់ធ្មេញក្នុងឥណ្ឌូណេស៊ី បានបង្ហាញថា ក្មេងអាយុ១២ឆ្នាំកុមារមាន DMFT ជាមធ្យម ២.២២ កម្រិតនៃជំងឺពុកធ្មេញនេះគឺមិនអាចប្រែប្រួលបានទេបើធៀបនឹងកម្រិតក្នុងប្រទេសជាច្រើននៅអឺរ៉ុបខាងលិច លើសពីនេះវាអាចត្រូវបានគេរំពឹងទុកកម្រិតនៃជំងឺពុកធ្មេញក្នុងប្រទេសឥណ្ឌូនេស៊ីនឹងកើនឡើងនៅក្រោមសម្ពាធការផ្លាស់ប្តូរទម្រង់របបអាហារ និងការប្រើប្រាស់ស្ករកើនឡើង។ ការរឹតបន្តឹងការប្រើប្រាស់ស្ករដើម្បីគ្រប់គ្រងជំងឺពុកធ្មេញត្រូវបានអនុវត្តនៅតាមសាលារៀនជាប្រចាំ ។ ការអប់រំសុខភាពតាមសាលារៀនជាផ្នែករួមបញ្ចូលគ្នានៃកម្មវិធីសិក្សាបឋមសិក្សា អាស្រ័យហេតុនេះ អគ្គនាយកដ្ឋានសុខភាពមាត់ធ្មេញរបស់ក្រសួងសុខភាព សហការជាមួយ អង្គការ WHO បានចាប់ផ្តើមកម្មវិធី OHE=Oral health education ដែលមានមូលដ្ឋាននៅសាលាបឋមសិក្សានៅខែវិច្ឆិកា ឆ្នាំ១៩៩៥។ គោលបំណងសំខាន់នៃកម្មវិធីគឺដើម្បីបង្កើនសមាមាត្រនៃសិស្សសាលាប៉ះពាល់ និង OHE ដែលមានមូលដ្ឋាននៅសាលាតាមរយៈការចូលរួមរបស់បុគ្គលិកផ្នែកសុខភាព កម្មវិធីនេះត្រូវបានត្រួតពិនិត្យវគ្គដុសធ្មេញប្រចាំសប្តាហ៍នៅក្នុងសាលារៀន (Sri Wendari A. Hartono and Soertini E. Lambri

Bandung, Indonesia Wim H. van Palenstein Helderman Nijmegen, The Netherlands, 2022)។

ការញ៉ាំអាហារពេលព្រឹកផ្តល់ថាមពលដល់ខួរក្បាល និងបង្កើនការរៀនសូត្រ ឥទ្ធិពលនៃការខ្វះជាតិគ្លុយកូសគឺអាចកត់សម្គាល់បានដោយការធ្លាក់ចុះនៃកម្រិតជាតិស្ករក្នុងឈាមក្នុងកម្រិតមួយដែលត្រូវបានបន្តយ៉ាងឆាប់រហ័សដោយការរំខានដល់មុខងារខួរក្បាល គម្លាត ប្រហែល ១០ ទៅ ១២ ម៉ោងរវាងអាហារពេលព្រឹក និងអាហារពេលល្ងាច បណ្តាលឱ្យកម្រិតជាតិស្ករក្នុងឈាមទាប និងការខកខានអាហារពេលព្រឹកជាទម្លាប់អាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់សមត្ថភាពយល់ដឹង។ ការថយចុះបន្តិចម្តងៗនៃកម្រិតអាំងស៊ុយលីន និងគ្លុយកូសអាចបណ្តាលឱ្យស្រ្តេស ដែលរំខានដល់ទិដ្ឋភាពផ្សេងៗនៃមុខងារនៃការយល់ដឹង ការយកចិត្តទុកដាក់ និងការចងចាំ ការសិក្សាបានសន្នត់ថា ទម្លាប់នៃការទទួលទានអាហារពេលព្រឹក និងការផ្តល់អាហារូបត្ថម្ភគ្រប់គ្រាន់ដល់កុមារជាប្រចាំ វាជះឥទ្ធិពលជាវិជ្ជមានដល់ការផ្តោតអារម្មណ៍ ការចងចាំ ការអនុវត្តការនៃសិក្សារបស់សិស្ស (NS Gajre, S Fernandez, N Balakrishna and S Vazir, 2008)។

នៅក្នុងសាលាបង្រៀនបើកបរបានបង្ហាញយ៉ាងច្បាស់ថាក្នុងសាលាមានវគ្គអប់រំដល់អ្នកបើកបរមិនមានប្រសិទ្ធភាពក្នុងការកាត់បន្ថយអត្រាគ្រោះថ្នាក់ក្នុងចំណោម សិស្សបញ្ចប់ការសិក្សានៃវគ្គសិក្សានេះទេ។ បន្ថែមពីលើនេះ សិស្សទាំងនេះត្រូវបានអនុញ្ញាតឱ្យទទួលបានប័ណ្ណបើកបរនៅមុនគ្រប់អាយុបើកបរ ការគ្រោះថ្នាក់ក្នុងវ័យជំទង់ និងអត្រាស្លាប់បានកើនឡើង (EDWARD E. BARTLETT, DRPH, 1981)។

នៅទីក្រុងសៀងហៃ សាលារៀនត្រូវបានគ្រប់គ្រងដោយការិយាល័យអប់រំ នៃរដ្ឋបាលក្រុង/ស្រុក គម្រោងបង្ការគ្រោះថ្នាក់ជាច្រើនប្រភេទ បានដាក់ចេញក្នុងសហគមន៍ ហើយសាលារៀនធ្វើកិច្ចសហប្រតិបត្តិការណ៍ជាមួយសហគមន៍ កម្មវិធីអប់រំសុខភាពតាមសហគមន៍បានបង្ហាញពីឥទ្ធិពលយ៉ាងសំខាន់ក្នុងការធ្វើអោយប្រសើរឡើងនូវជំនឿសុខភាពរបស់សិស្ស គុណសម្បត្តិនៃកិច្ចសហប្រតិបត្តិការនេះគឺ៖ (១) សហគមន៍បានសម្របសម្រួលពីគ្រប់សមាសភាព ដូចជា នាយកដ្ឋាន

ចរាចរណ៍, នាយកដ្ឋានពន្លត់អគ្គីភ័យ និងមន្ទីរសុខាភិបាល, កិច្ចសហប្រតិបត្តិការជួយសម្រួលសហគមន៍ដើម្បីបញ្ជាក់ពីប្រភេទជាក់លាក់នៃការគ្រោះថ្នាក់ និងកត្តាហានិភ័យ និងផ្តល់ការគាំទ្រផ្នែកបច្ចេកវិទ្យាដល់សាលារៀនក្នុងការអនុវត្តកម្មវិធីការពារការគ្រោះថ្នាក់ ២) ជាមួយជំនួយរបស់គណៈកម្មាធិការលំនៅដ្ឋាន, សហគមន៍អាចទទួលបានការគាំទ្រពីគ្រួសារ ៣) សហគមន៍មានមូលនិធិពិសេស និងអាចផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់គម្រោង ៤) សហគមន៍អាចផ្តល់វេទិកាចាំបាច់សម្រាប់អន្តរាគមន៍ ៥) សិស្សអាចផ្សព្វផ្សាយចំណេះដឹង និងជំនាញអំពីការការពារការគ្រោះថ្នាក់ដល់គ្រួសារ និងសហគមន៍ (Zhi-Juan Cao1† , Yue Chen2† and Shu-Mei Wang1 *†, 2014)។

នាយកដ្ឋានសុខភាពចក្រភពអង់គ្លេស បញ្ជាក់ថាគិលានុបដ្ឋាយិកាសាលាមានតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួល និងអន្តរាគមន៍លើសុខភាពសាធារណៈសម្រាប់កុមារដែលមានអាយុចូលរៀន គិលានុបដ្ឋាយិកាសាលានៅប្រទេសអង់គ្លេសគឺជាគិលានុបដ្ឋាយិកាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលមានគុណវុឌ្ឍិឯកទេសសុខភាពសាធារណៈ លើសពីនេះទៀតគិលានុបដ្ឋាយិកាជាជំនួយការ ដែលបានបណ្តុះបណ្តាលយ៉ាងពេញលេញ និងត្រឹមត្រូវដើម្បីអនុវត្តជាជំនួយ និងជាសមាជិកសំខាន់នៃក្រុមថែទាំសាលា (Beverley A. Hoekstra, Vicki L. Young, Charlotte V. Eley, Meredith K. D. Hawking and Cliodna A. M. McNulty*, 2016) ។

សុខភាពសិស្ស គឺជាកត្តាចម្បងដែលជះឥទ្ធិពលសមិទ្ធិផលការសិក្សារបស់ពួកគេ និងការចូលរួមនៅសាលា តាមការសិក្សាស្រាវជ្រាវមានសាលាគំរូបបីប្រភេទគឺ សាលារៀននៅក្នុងទីក្រុង សាលានៅទីជនបទដែលមានកម្មវិធី "អាហារនៅសាលា" និងសាលារៀននៅជនបទដែលគ្មានកម្មវិធី "អាហារនៅសាលា" ។ ការស្រាវជ្រាវសាលាបឋមសិក្សាក្នុងប្រទេសកម្ពុជា សិស្សសាលានៅទីក្រុងមានកម្ពស់ខ្ពស់ និងទម្ងន់ធ្ងន់ជាងសិស្សសាលានៅទីជនបទ ទាំងសាលាមានកម្មវិធី "អាហារនៅសាលា" និងសាលាគ្មានកម្មវិធី "អាហារនៅសាលា" សិស្សសាលានៅទីជនបទក្នុងសាលាគ្មានកម្មវិធី "អាហារនៅសាលា" គឺខ្លី និងស្រាលបំផុត ការសេចក្តីសន្និដ្ឋានកម្មវិធីអាហារនៅសាលារៀនមានឥទ្ធិពលវិជ្ជមានទៅលើការលូតលាស់របស់កុមារ ។ សាលានៅជនបទដែលគ្មានកម្មវិធី "អាហារក្នុងសាលារៀន" គួរតែ

ត្រូវបានពង្រីកដល់សាលាបឋមសិក្សានៅតាមជនបទ ក្នុងការលើកកម្ពស់កំណើនកុមារ និងបញ្ហាសុខភាពកុមារ ដើម្បីជាការលើកទឹកចិត្តឱ្យពួកគេចូលរៀនក្នុងសាលា (Chansean Mam, 2021)។

នៅប្រទេសហ្គាណា ដាក់ចេញឱ្យអនុវត្តនូវកម្មវិធីគ្រប់គ្រងជំងឺគ្រុនចាញ់ថ្នាក់ជាតិផ្តោតសំខាន់លើស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោមប្រាំឆ្នាំ ដោយសារជំងឺគ្រុនចាញ់នាំឱ្យកើតមានកាន់តែច្រើន ផលវិបាកធ្ងន់ធ្ងរនៅក្នុងក្រុមនេះ ។ សកម្មភាពសំខាន់ៗរបស់កម្មវិធីគ្រប់គ្រងជំងឺគ្រុនចាញ់នៅប្រទេសហ្គាណាមានមូលដ្ឋាន និងអនុវត្តនៅកម្រិតមណ្ឌលសុខភាព ពោលគឺការផ្តល់ការព្យាបាល ការបង្ការ ការចែកចាយមុង និងការកាពារ ថ្នាំសំលាប់សត្វល្អិត ដល់ស្ត្រីមានផ្ទៃពោះអំឡុងពេលមានផ្ទៃពោះ និងការចែកចាយចំពោះស្ត្រីដែលមានកូនតូចអំឡុងពេលចាក់ថ្នាំបង្ការ ព្រមទាំងកុមារដែលដល់អាយុចូលរៀនក៏ត្រូវបានកំណត់គោលដៅផងដែរសម្រាប់ការគ្រប់គ្រងជំងឺគ្រុនចាញ់នៅក្នុងប្រទេស។ នៅពេលដែលកុមារកាន់ជាច្រើនចូលរៀន រដ្ឋាភិបាលកាន់តែទទួលស្គាល់សារៈសំខាន់នៃសុខភាពកុមារសម្រាប់សមិទ្ធិផល។ ផលប៉ះពាល់មិនត្រឹមតែលើកុមារប៉ុណ្ណោះទេ ប៉ុន្តែក៏មានចំពោះមនុស្សពេញវ័យក្នុងសហគមន៍ផងដែរ ក្នុងការកែលម្អចំណេះដឹងអំពីបុព្វហេតុ និងការការពារការបង្ករោគ ការអនុវត្តការដាក់ឱ្យដេកក្នុងមុងដើម្បីកាត់បន្ថយការកើតជម្ងឺគ្រុនចាញ់។ ថ្មីៗនេះការអន្តរាគមន៍អប់រំសុខភាពតាមសាលារៀន សម្រាប់ការគ្រប់គ្រងជំងឺគ្រុនចាញ់ត្រូវបានធ្វើឡើង គ្រូបង្រៀនបានប្រើវិធីសាស្ត្រប្រកបដោយភាពច្នៃប្រឌិត តាមរយៈការផ្សព្វផ្សាយព័ត៌មានអំពីជំងឺគ្រុនចាញ់ទាំងក្នុងសាលារហូតដល់សហគមន៍ ដែលមានវិធីសាស្ត្រភាពខុសគ្នាគឺ ការចេញព្រឹត្តិបត្រព័ត៌មាន ការដាក់ក្នុងវិក្កយបត្រ និងការរៀបចំព្រឹត្តិការណ៍តាមភូមិ (Irene Ayi1, Daisuke Nonaka2,3, Josiah K Adjovu4, Shigeki Hanafusa5, Masamine Jimba2, Kwabena M Bosompem1, Tetsuya Mizoue3, Tsutomu Takeuchi6, Daniel A Boakye1 and Jun Kobayashi*, 2010)។

ការកែលម្អសុខភាពផ្លូវចិត្ត និងសុខុមាលភាពរបស់មនុស្សត្រូវបានគេកំណត់ថាជាបញ្ហាសុខភាពសាធារណៈដ៏សំខាន់បំផុតមួយក្នុងសម័យបច្ចុប្បន្ន (Kieling et al., 2011; Knifton & Quinn, 2013) ។ ការបង្កើនភស្តុតាងគាំទ្រដល់ផលប៉ះពាល់យ៉ាងសំខាន់នៃសុខភាពផ្លូវចិត្ត និងសុខុមាលភាពលើ

អារម្មណ៍ សង្គម សេដ្ឋកិច្ច គុណភាពនៃជីវិត សុខភាពរាងកាយ និងលទ្ធផលផលិតភាព (Herrman, Saxena, & Moodie, 2005; World Health Organization, 2001) ។

កង្វះអាហារូបត្ថម្ភចំពោះកុមារ មានផលវិបាកធ្ងន់ធ្ងរនិងយូរអង្វែងសម្រាប់សុខភាពប្រជាពលរដ្ឋកម្ពុជា និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការលូតលាស់មិនគ្រប់គ្រាន់ក្នុងរយៈពេលពីរបីឆ្នាំដំបូងនៃជីវិត មិនត្រឹមតែប៉ះពាល់ដល់សុខភាពកុមារ និងមរណភាព កុមារប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងនាំឱ្យមានផលមិនល្អចំពោះសុខភាព និងផលវិបាកសេដ្ឋកិច្ចសម្រាប់បុគ្គលពេញមួយជីវិត វាក៏ធ្វើឲ្យប៉ះពាល់ផងដែរដល់ការអភិវឌ្ឍរបស់ប្រទេសកម្ពុជា ដោយធ្វើឱ្យបាត់បង់ប្រជាពលរដ្ឋដែលមានសុខភាពល្អ និងមានការអភិវឌ្ឍសតិបញ្ញាសម្រាប់មនុស្ស ជំនាន់ក្រោយទៀតផង។ កម្ពុជាគឺជាប្រទេសទី២៨ ក្នុងពិភពលោក ក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំដែលមានបញ្ហាកង្វះអាហាដែលមានអត្រាប្រេវ៉ាឡង់ខ្ពស់បំផុតនៃកុមារដែល មានកម្ពស់ទាប (ក្រោះក្រិន) ចំនួន៤០%។ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាក៏បានបង្ហាញដែរថា កុមារប្រមាណ ២៨% មានទម្ងន់ក្រោមស្តង់ដារ។ នេះគឺជាភ័ស្តុតាងដ៏ រឹងមាំមួយដែលបង្ហាញថាស្ថានភាពអាហារូបត្ថម្ភរបស់កុមារមិនមានភាពប្រសើរឡើយ ចាប់តាំងពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១០ ភាគរយនៃកុមារដែលស្គមស្គាំងខ្លាំងគួរឲ្យបារម្ភ បានឡើងហួសកម្រិតកំណត់ដែលត្រូវប្រកាសអាសន្ននៃចំណាត់ថ្នាក់អន្តរជាតិដែលកើនពី ៨,៤% ដល់ ១០,៩%។ ជាលទ្ធផលប្រទេសកម្ពុជាបច្ចុប្បន្នស្ថិតក្នុងចំណោម ប្រទេសទាំង ៤០ ក្នុងពិភពលោក ដែលមានស្ថានភាពធ្ងន់ធ្ងរជាងគេបំផុតសម្រាប់ កុមារដែលមានភាពស្គមស្គាំង ដែលស្ថានភាពកង្វះអាហារូបត្ថម្ភនេះពាក់ព័ន្ធដល់ការស្លាប់របស់កុមារប្រមាណជា ៦.៤០០នាក់ ក្នុងមួយឆ្នាំ **(ក្រសួងសុខាភិបាល, ២០១៤-២០២០)** ។

ទោះបីជាមានការរីកចម្រើនឆ្ពោះទៅរកការបញ្ចប់ភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភក៏ដោយក៏មនុស្សជាង៨២០លាននាក់ នៅតែខ្វះអាហារូបត្ថម្ភនៅទូទាំងពិភពលោក(Ralph Root haert ,Hosea Mpogole, Danny Hunter, Justus Ochieng, and Dyness Kejo, 2021) ។ កម្មវិធីស្បៀងអាហារពិភពលោកបានប៉ាន់ប្រមាណថា យ៉ាងហោចណាស់មានកុមារអាយុចូលសាលាបឋម

សិក្សាចំនួន ៦៦លាននាក់ ដែលចូលរៀននៅទូទាំងប្រទេសកំពុងអភិវឌ្ឍន៍ដែលស្រេកឃ្លានដោយមាន ២៣ លាននាក់នៅក្នុងទ្វីបអាហ្វ្រិកតែមួយ (WFP, 2015)។

នៅប្រទេសតង់ហ្សានី កម្មវិធីផ្តល់អាហារដល់សាលាដែលដាំផុះនៅផ្ទះដោយជោគជ័យត្រូវបានធ្វើមូលដ្ឋានីយកម្មនៅក្នុងនៅក្នុងស្រុក Arumeru និង Babati ។ សាលារៀនស្ទើរតែទាំងអស់នៅក្នុងស្រុក Arumeru និង Babati មានទម្រង់មួយចំនួននៃកម្មវិធីផ្តល់អាហារដល់សាលា។ នៅក្នុងស្រុក Arumeru សាលាបឋមសិក្សាសាធារណៈចំនួន ១៥២ ក្នុងចំណោម ១៦២ មានកម្មវិធីផ្តល់អាហារ និង សាលារៀនចំនួន៥២ ក្នុងចំណោម១៤៣ នៅក្នុងស្រុក Babati កំពុងដំណើរការការផ្តល់អាហារដល់សាលារៀន ខណៈដែលសាលាដែលនៅសល់នៅតែជួបការលំបាកក្នុងការប្រមូលវិភាគទានពីឪពុកម្តាយ។ កម្មវិធីផ្តល់អាហារដល់សាលារដ្ឋត្រូវបានសម្របសម្រួល និងដំណើរការដោយមាតាបិតា តាមរយៈគណៈកម្មការដែលបានបង្កើតឡើង សមាជិកនៃគណៈកម្មការអាហារសម្រាប់សាលាត្រូវបានតែងតាំងនៅក្នុងកិច្ចប្រជុំរបស់មាតាបិតាសិស្ស។ តួនាទី និងទំនួលខុសត្រូវរបស់គណៈកម្មការអាហារសាលារួមមានៈ ការបង្កើនការរួមចំណែកពីមាតាបិតា ទាំងក្នុងន័យរូបិយវត្ថុ ឬជាលក្ខណៈប្រភេទការទិញអាហារ។ គណៈកម្មការកម្មវិធីផ្តល់អាហារដល់សាលារៀនបង្កើតឡើងដោយមានសមាសភាពនាយកសាលា លោកគ្រូ អ្នកគ្រូ មាតាបិតាសិស្ស និងអាជ្ញាធររដ្ឋាភិបាលក្នុងតំបន់ ។ គណៈកម្មការអាហារសាលាមួយចំនួនបានដំណើរការគណនីធនាគារសម្រាប់មូលនិធិដែលបានរៃអង្គាសសម្រាប់កម្មវិធីផ្តល់អាហារដល់សាលារៀន។ ជាលទ្ធផលការអនុវត្តនេះត្រូវបានបង្កើតឡើងដោយផ្អែកលើភាពវិជ្ជមាន ជាតុផ្សំសំខាន់ៗចំនួនបួន៖ ភាពជាអ្នកដឹកនាំ និងការយល់ដឹងជាសាធារណៈ ទម្រង់ប្រតិបត្តិការ ការរួមចំណែកពីឪពុកម្តាយ និងភាពសម្បូរបែបនៃអាហារ និងអាហារូបត្ថម្ភ គំរូការផ្តល់អាហារដល់សាលាដែលដាំផុះតាមផ្ទះផ្តល់យន្តការដើម្បីកែលម្អភាពចម្រុះនៃអាហារ ។

នៅសហរដ្ឋអាមេរិក លំហាត់ប្រាណទៀងទាត់អាចកាត់បន្ថយហានិភ័យនៃការវិវត្តនៃជំងឺរ៉ាំរ៉ៃក្នុងចំណោមមនុស្សពេញវ័យ ១.ជំងឺសរសៃឈាមបេះដូង ២.មហារីក ៣. ជំងឺទឹកនោមផ្អែម ការចូលរួមជាទៀងទាត់ក្នុងសកម្មភាពរាងកាយនៅក្មេង រួមចំណែកដល់ការលូតលាស់ឆ្អឹង និងសាច់ដុំដែល

មានសុខភាពល្អ កាត់បន្ថយអារម្មណ៍ធ្លាក់ទឹកចិត្ត និងការថប់បារម្ភ និងលើកកម្ពស់សុខុមាលភាពផ្លូវចិត្ត។ លើសពីនេះ ការហាត់ប្រាណទៀងទាត់កាត់បន្ថយហានិភ័យសម្រាប់ការកើនឡើងនៃការលើសទម្ងន់ក្នុងចំណោមយុវជន។ ក្នុងឆ្នាំ២០០៤ ១៨.៨% នៃក្មេងអាយុពី ៦ ទៅ ១១ ឆ្នាំ និង ១៧.៤% នៃក្មេងអាយុពី ១២ ទៅ ១៩ ឆ្នាំត្រូវបានគេចាត់ទុកថាធាត់ ។ គោលការណ៍ណែនាំស្តីពីរបបអាហាររបស់សហរដ្ឋអាមេរិកសម្រាប់ជនជាតិអាមេរិកបានផ្តល់អនុសាសន៍ថាមនុស្សវ័យក្មេង (អាយុ ៦-១៩ ឆ្នាំ) របាយការណ៍ស្តីពីតុល្យភាពបានផ្តល់អនុសាសន៍ថា សិស្សត្រូវបានផ្តល់ឱកាសឱ្យចូលរួមក្នុងសកម្មភាពរាងកាយយ៉ាងហោចណាស់ ៦០ នាទីក្នុងអំឡុងពេលថ្ងៃសិក្សា (SARAH M. LEE, PhDa CHARLENE R. BURGESON, MAb JANET E. FULTON, PhDc CHRISTINE G. SPAIN, MA, 2006)។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

រាជរដ្ឋាភិបាលកម្ពុជាកំពុងតែយកចិត្តទុកដាក់យ៉ាងខ្លាំងលើការលើកកម្ពស់សុខភាពសិក្សា ដែលមានក្រសួងអប់រំ យុវជន និងកីឡាជាសេនាធិការ បានដាក់ចេញឱ្យអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការអនុវត្តសុខភាពសិក្សានៅតាមសាលាគ្រឹះស្ថានចំណេះទូទៅសាធារណៈ និងឯកជន ឱ្យអ្នកសិក្សា និងអ្នកអប់រំទទួលបានចំណេះដឹងជាមូលដ្ឋានស្តីពីសុខភាពដើម្បីអាចយកទៅអនុវត្តក្នុងជីវភាពរស់នៅប្រចាំថ្ងៃ លើកស្ទួយសេដ្ឋកិច្ចគ្រួសារ ក៏ដូចជាសង្គមជាតិផងដែរ។ សាលារៀននៅទូទាំងប្រទេសទទួលបានសេចក្តីណែនាំស្តីពីសុខភាពសិក្សារួចហើយ យកទៅអនុវត្តឈរលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនទៅតាមស្ថានភាពរៀងៗខ្លួន ដោយចាប់ផ្តើមពីការធ្វើផែនការ ការកៀរគរសប្បុរសជនចូលរួមឧបត្ថម្ភ ការផ្សព្វផ្សាយស្តីពីការថែរក្សាសុខភាព អនាម័យ រស់នៅស្អាត ហូបស្អាតក្នុងសាលារៀន និងសហគមន៍។ លោកគ្រូ អ្នកគ្រូទទួលបានវគ្គអប់រំបំប៉ន ឬវគ្គសិក្ខាសាលាផ្សេងៗដើម្បីទទួលបានចំណេះដឹងថ្មីៗស្តីពីសុខភាពសិក្សា រួចយកទៅបង្ហាត់បង្រៀនសិស្សឱ្យពួកគេមានចំណេះដឹងជាមូលដ្ឋានស្តីពីសុខភាព និងការអនាម័យ ដើម្បីធ្វើការអភិវឌ្ឍចំណេះដឹង បំណិន ឥរិយាបទបានល្អ (អ.យ.ក, ២០២២)។

ផ្អែកទៅលើសូចនាករស្ថិតិអប់រំឆ្នាំ២០២១-២០២២ សាលារៀននៅកម្រិតបឋមសិក្សាមួយចំនួនមិនទាន់យកទៅអនុវត្ត និងមិនទាន់បានអនុវត្តល្អនៅឡើយទេ សាលាមួយចំនួនខ្វះបង្គន់អនាម័យ កន្លែងលាងដៃ ប្រភពទឹកស្អាតសម្រាប់សិស្សបរិភោគ ហើយសិស្សនៅមានបញ្ហាផ្នែកសុខភាព ពាងកាយស្គមស្គាំង មិនសូវលូតកម្ពស់ ។ នាយកសាលា គ្រូបង្រៀនមិនបានទប់ស្កាត់ការលក់ចំណីអាហារដែលក្រសួងអប់រំហាមប្រាមមិនឱ្យលក់ក្នុងសាលា មិនឱ្យសិស្សបរិភោគ សហគមន៍ អាណាព្យាបាលសិស្សមិនបានអប់រំណែនាំឱ្យពួកគេការពារពីមេរោគ ការសម្អាត ការអនាម័យ ដែលអាចបង្ករគ្រោះថ្នាក់ជម្ងឺផ្សេងៗ ។

តាមរយៈការអានរបាយការណ៍ប្រចាំខែនីមួយៗរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង និងតាមរយៈការជជែកពិភាក្សាជាមួយបុគ្គលិកការិយាល័យសុខភាពសិក្សា មិនទាន់មានរបាយការណ៍ណាមួយថាមានការអនុវត្តផ្នែកសុខភាពសិក្សាបានល្អនៅឡើយទេ ហើយមកដល់ពេលនេះក្រសួងអប់រំ យុវជន និងកីឡាបានចេញសេចក្តីណែនាំផ្នែកសុខភាពសិក្សាផ្សេងៗ ជាពិសេសគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សា ក៏នៅមិនទាន់មានការត្រួតពិនិត្យតាមដាន និងការវាយតម្លៃអ្វីមួយនោះដែរ ។

ដោយមើលឃើញពីបញ្ហាដូចដែលបានរៀបរាប់ខាងលើនេះហើយ ទើបអ្នកស្រាវជ្រាវសម្រេចចិត្តជ្រើសយកប្រធានបទនេះមកធ្វើការសិក្សាស្រាវជ្រាវក្នុងគោលបំណងដូចការរៀបរាប់ខាងក្រោមស្រាប់ ។

### ១.៣ គោលបំណងនៃការស្រាវជ្រាវ

- ឈ្វេងយល់ពីស្ថានភាពបច្ចុប្បន្ននៃការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សានៅកម្រិតបឋមសិក្សា
- ឈ្វេងយល់ពីស្ថានភាពនៃការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សានៅកម្រិតបឋមសិក្សារវាងទីប្រជុំជន និងទីជនបទ

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងវត្ថុបំណងស្រាវជ្រាវទាំងខាងលើនេះ សំណួរស្រាវជ្រាវត្រូវបានចោទសួរដូចខាងក្រោម៖

- តើស្ថានភាពបច្ចុប្បន្ននៃការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សាតាមសាលានៅកម្រិតបឋមសិក្សាមានលក្ខណៈដូចម្តេច?
- តើការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សា រវាងបឋមសិក្សានៅប្រជុំជន និងបឋមសិក្សានៅជនបទមានលក្ខណៈខុសគ្នាដូចម្តេចខ្លះ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវពីប្រធានបទ ស្ថានភាពនៃការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដា ស្តីពីការលើកកម្ពស់សុខភាពសិក្សា នៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀងពិតជាមានសារៈសំខាន់ណាស់ ព្រោះធ្វើឱ្យគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូបានដឹងពីស្ថានភាពនៃការអនុវត្តកម្មវិធីសុខភាព ដឹងពីវិធីសាស្ត្រអប់រំសុខភាពដល់សិស្ស សហគមន៍ ដឹងពីស្ថានភាពសុខភាពរបស់សិស្សងាយស្រួលក្នុងការកែលម្អការអនុវត្តផ្នែកសុខភាពសិក្សា ដែលធ្វើឱ្យមានអភិវឌ្ឍសាលារៀនផងដែរ មិនត្រឹមតែប៉ុណ្ណោះវាបានជួយដល់សហគមន៍ អង្គការ ម្ចាស់ជំនួយ សប្បុរសជននានា ជាពិសេសក្រសួងអប់រំ យុវជន និងកីឡាបានមើលឃើញពីស្ថានភាពនៃការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សាទៅតាមសាលារៀននីមួយៗ ងាយស្រួលក្នុងការអភិវឌ្ឍកម្មវិធីសិក្សា កំណែទម្រង់សុខភាពសិក្សា បង្ការ អន្តរាគមន៍ដើម្បីដោះស្រាយបញ្ហានានាដែលកើតមានឡើងពីស្ថានភាពសុខភាពសិក្សា និងធ្វើឱ្យការអនុវត្តផ្នែកសុខភាពស្របតាមចក្ខុវិស័យក្រសួងអប់រំ ពិសេសដើម្បីសម្រេចចក្ខុវិស័យផែនការជាតិឆ្នាំ២០៣០ និង២០៥០ មួយវិញទៀតប្រធានបទនេះមានសារៈសំខាន់សម្រាប់ជាឯកសារជំនួយស្មារតីដល់អ្នកសិក្សាស្រាវជ្រាវក្រោយៗទៀតផងដែរ ។

## ១.៦ ដែនកំណត់នៃការស្រាវជ្រាវ

### ១.៦.១ វិសាលភាពនៃការស្រាវជ្រាវ

វិសាលភាពនៃការសិក្សាស្រាវជ្រាវគឺគ្របដណ្តប់លើសាលាបឋមសិក្សានានានៅក្នុងខេត្តស្វាយរៀង លើប្រធានបទស្ថានភាពការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សានៅកម្រិតបឋមសិក្សា ដែលគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ ជាអ្នកអនុវត្ត និងការសង្កេតមើលបរិស្ថានសិក្សាក្នុងសាលា មើលបង្គន់អនាម័យ មើលកន្លែងលាងដៃ ប្រភពទឹកស្អាតសម្រាប់សិស្សបរិភោគ ឡដុតសម្រាម ល. ។ ការស្រាវជ្រាវផងដែរនឹងធ្វើការសម្ភាសន៍ជាមួយគណៈគ្រប់គ្រងសាលា ការបំពេញកម្រងសំណួរដោយគ្រូ និងសិស្ស។

### ១.៦.២ ដែនកំណត់នៃការស្រាវជ្រាវ

ដោយអាស្រ័យលើពេលវេលា និងធនធានមានកំណត់ អ្នកស្រាវជ្រាវមិនអាចធ្វើការសិក្សាស្រាវជ្រាវបានគ្រប់សាលានៅកម្រិតបឋមសិក្សាទាំងអស់ក្នុងខេត្តស្វាយរៀងបាននោះទេ ដូចនេះអ្នកស្រាវជ្រាវប្រើវិធីចាប់យកសាលាសំណាកដោយ Random ក្នុងមួយក្រុង/ស្រុកចំនួន២សាលាដែលតំណាងឱ្យសាលាក្នុងក្រុង/ស្រុកនីមួយៗ អាស្រ័យហេតុនេះនៅខេត្តស្វាយរៀងមាន៨ ក្រុង/ស្រុក ហេតុនេះទូទាំងខេត្តស្វាយរៀង អ្នកស្រាវជ្រាវបានកំណត់ជ្រើសយកសាលាសំណាកគោលដៅចំនួន១៦សាលាតែប៉ុណ្ណោះ រីឯការប្រមូលទិន្នន័យអ្នកស្រាវជ្រាវកំណត់យកការសម្ភាសន៍គណៈគ្រប់គ្រង ចំពោះគ្រូ និងសិស្សគឺធ្វើការបំពេញកម្រងសំណួរ ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកជាប្រាំជំពូកដូចខាងក្រោម៖

ជំពូក១៖ សេចក្តីផ្តើមរួមមានលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់នៃ ការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

ជំពូក២៖ រំឭកទ្រឹស្ដី ពិនិត្យមើលឯកសារជាតិ និងអន្តរជាតិ និងការសិក្សានាពេលបច្ចុប្បន្ន ដែលបានកំពុងអនុវត្តនៅសាលារៀនកម្រិតបឋមសិក្សាក្នុងប្រទេសកម្ពុជា ដើម្បីស្វែងយល់ពីស្ថានភាព ការនៃសាលាបានអនុវត្ត ឬពុំបានអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាស្ដីពីការលើកកម្ពស់សុខភាព សិក្សា និងការដែលសាលាបានអនុវត្តជាក់ស្តែងក្នុងកម្រិតណានោះ ថាតើត្រូវតាមសេចក្តីណែនាំរបស់ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញឱ្យអនុវត្តតាមដែរឬទេ។

ជំពូក៣៖ រៀបរាប់អំពី វិធីសាស្ត្រស្រាវជ្រាវដែលអ្នកស្រាវជ្រាវបានយកមកប្រើប្រាស់ក្នុងការ សិក្សាស្រាវជ្រាវនេះ។ នៅក្នុងជំពូកនេះអ្នកស្រាវជ្រាវបង្ហាញពីរបៀបនៃការប្រមូលសំណាក ការប្រមូល ព័ត៌មាន ការប្រើប្រាស់ឧបករណ៍ស្ថិតិ ការប្រើរូបមន្តសម្រាប់គណនា និងការជ្រើសរើសវិធីសាស្ត្រ ប្រមូលទិន្នន័យ។

ជំពូក៤៖ លទ្ធផល និងការពិភាក្សា ក្នុងផ្នែកនេះអ្នកស្រាវជ្រាវលើកឡើងពីលក្ខណៈជាក់ស្តែង ដែលខ្លួនបានធ្វើការសិក្សាស្រាវជ្រាវ ហើយត្រូវឆ្លើយតបទៅនឹងចំណុចដែលចោទសួរនៅក្នុងសំណួរ ស្រាវជ្រាវ។ ការបកស្រាយ ត្រូវបកស្រាយយ៉ាងលម្អិតទៅលើគោលបំណងនៃការស្រាវជ្រាវ ដោយ យោងទៅលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ ឬខ្លឹមសារដែលមានក្នុងកម្រងសំណួរ ។

ជំពូក៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ ជំពូកនេះអ្នកស្រាវជ្រាវត្រូវ ធ្វើការសង្ខេបការសិក្សា ស្រាវជ្រាវ រួចទាញជាសេចក្តីសន្និដ្ឋានលើចំណុចដែលបានវិភាគ និងផ្តល់យោបល់ឬសំណូមពរទៅលើ ចំណុចដែលត្រូវកែលម្អ ។

# ជំពូក២

# រំលឹកទ្រឹស្តី

# ជំពូក២៖

# រំលឹកទ្រឹស្តី

ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍ "គោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សា សម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅ" ក្នុងគោលបំណងជំរុញការអនុវត្តកម្មវិធីសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សាស្របតាមគោលនយោបាយជាតិស្តីពីសុខភាពសិក្សា ជាពិសេសដើម្បីជាមគ្គុទ្ទេសក៍សម្រាប់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា និងអ្នកពាក់ព័ន្ធសិក្សាស្វែងយល់យកទៅអនុវត្តជាជំហានៗប្រកបដោយភាពច្នៃប្រឌិត ឱ្យក្លាយជាកន្លែងប្រកបដោយសុខភាព សុវត្ថិភាព និងផាសុកភាពសម្រាប់អ្នកសិក្សា និងអ្នកអប់រំ។

## ២.១ ពាក្យគន្លឹះ

- អនុវត្ត (កិ) ដោយសំដៅលើ ប្រព្រឹត្តតាម, ធ្វើតាម, យល់ព្រម,យល់ព្រមតាម ។

  ឧទាហរណ៍៖ ដើម្បីឱ្យក្លាយជាមនុស្សល្អ ត្រូវតែអនុវត្តនូវសេចក្តីល្អ។
- គោលការណ៍ (ន) ទ្រឹស្តីដែលចេញប្រើជាគោល សម្រាប់អនុវត្តកិច្ចការឲ្យត្រូវតាមបែបផែន
- ប្រតិបត្តិ (ន) មានន័យថា ការប្រព្រឹត្ត, កាន់, ធ្វើតាម, ច្រើននិយាយថា សេចក្តីបដិបត្តិ, ការប្រតិបត្តិ ដកស្រង់ពីវចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត
- ស្តង់ដា (ន) មានននយ័ថា អ្វីដែលធ្វើទៅតាមលក្ខណៈក្បួនខ្នាតបច្ចេកទេសត្រឹមត្រូវ មានការទទួលស្គាល់ដឹងលឺជាសកល។
- លើកកម្ពស់ (ន) ជំរុញ គាំទ្រ ឬលើកទឹកចិត្តអ្វីមួយ
- សុខភាពសិក្សា ជាសុំណុំសកម្មភាពផ្សេងៗ សម្រាប់លើកម្ពស់សុខភាពនៅតាមគ្រឹះស្ថានសិក្សាដែលជាសេចក្តីត្រូវការជាមូលដ្ឋាននៃផ្លូវកាយ ផ្លូវចិត្ត និងសង្គមរបស់អ្នកសិក្សានិងអ្នកអប់រំ (អ.យ.ក, ២០២៣, សន្និបាតអប់រំ)

## ២.២ ស្តង់ដាលើកកម្ពស់សុខភាពសិក្សា

### ២.២.១ ស្តង់ដាទី១៖ ការអភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការ

លោកបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញវិធានការបង្កើតគណៈកម្មការសុវត្ថិភាពសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា គណៈកម្មការសុខភាពសិក្សាគឺជាយន្តការមួយសម្រាប់សម្របសម្រួលដឹកនាំការងារសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា ដើម្បីធានាសុខភាព សុវត្ថិភាព និង សុខុមាលភាពដល់អ្នកសិក្សានិងបុគ្គលិកអប់រំ គណៈកម្មការសុខភាពសិក្សាបង្កើតឡើងដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន វិស័យឯកជន បុព្វជិតសាសនា សហគមន៍ និងអ្នកអាណាព្យាបាលជាដើម គណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សាត្រូវបង្កើតឡើងចេញពីគំនិតផ្តួចផ្តើមរបស់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាមី តាមរយៈកិច្ចប្រជុំពិភាក្សាជាមួយភាគី ពាក់ព័ន្ធដូចជា មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក អាជ្ញាធរ ដែនដី ក្រុមប្រឹក្សាឃុំ សង្កាត់ វត្តអារាម វិហារសាសនា សប្បុរសជន មាតាបិតាសិស្ស និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីទទួលការគាំទ្រនិងកំណត់លើសមាសភាពនិងតួនាទីនិងភារកិច្ចដែលត្រូវធ្វើ

គណៈកម្មការសុខភាពសិក្សារួមមាន ប្រធាន០១រូប និងអនុប្រធានតាមការចាំបាច់ ព្រមទាំងសមាជិកមួយចំនួនអាស្រ័យលើទំហំការងារ និងតម្រូវការជាក់ស្តែងរបស់គ្រឹះស្ថានសិក្សាសាមី គណៈកម្មការសុខភាពសិក្សា ត្រូវមាននីត្យានុកូលត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ច

គណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថាននីមួយៗត្រូវបង្កើត "ក្រមប្រតិបត្តិស្តីពីសុខភាពសិក្សាស្តីពីសុខភាពសិក្សាសម្រាប់ដាក់ឱ្យអនុវត្តចំពោះមនុស្សគ្រប់រូបដែលបំពេញការងារនៅ តាមគ្រឹះស្ថានសិក្សារបស់ខ្លួនស្របតាមគោលបំណង គោលដៅ ក្រមប្រតិបត្តិនេះអាចបិទផ្សាយនៅក្នុងបរិវេណគ្រឹះស្ថានសិក្សា ដើម្បីឱ្យអ្នកសិក្សា បុគ្គលិកអប់រំ និងអ្នកពាក់ព័ន្ធ នានា ពេលចូលដល់គ្រឹះស្ថានសិក្សាត្រូវអនុវត្តតាមក្នុងគោលដៅធានាឱ្យបាននូវសុវត្ថិភាព របៀបរៀបរយ មានបរិស្ថានល្អ អនាម័យស្អាត បរិយាកាសល្អ មេត្រីភាព ផាសុកភាព។ ការគោរពនិងអនុវត្តតាមក្រមប្រតិបត្តិស្តីពីសុខភាព

សិក្សា ដោយយោងតាមការណែនាំរបស់ ក្រសួងសុខាភិបាល ឬក្រសួងអប់រំ យុវជន និងកីឡា គឺជាការជួយខ្លួនឯងឱ្យមានសុវត្ថិភាព សេចក្តីថ្លៃថ្នូរ ក៏ដូចជាចូលរួមចំណែកក្នុងការលើកតម្លៃនៃគ្រឹះស្ថានសិក្សាផងដែរ ( https://www.kampucheathmey.com/local-news/266404, 2022 ) ។

ក្នុងទិសដៅលើកកម្ពស់សុវត្ថិភាព និងសុខុមាលភាពរបស់អ្នកសិក្សា និងបុគ្គលិកអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីណែនាំជាបន្តបន្ទាប់នូវសេចក្តីណែនាំលេខ ៣៦៧៣ អយក.សណន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការលើកកម្ពស់សុខភាព អនាម័យ និង សុវត្ថិភាពចំណីអាហារតាមសាលារៀន និងសេចក្តីណែនាំលេខ ១៨ អយក.សណន ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការលើកកម្ពស់សុវត្ថិភាពចំណីអាហារនិងអាហារប្រកបដោយសុខភាព នៅតាមគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន ទោះជាយ៉ាងនេះក៏ដោយ ក្រសួងសង្កេតឃើញថា សិស្សានុសិស្សនៅតាមគ្រឹះស្ថានសិក្សាមួយចំនួន មានអាការៈពុលចំណីអាហារ ទន់ដៃទន់ជើង និងឈានទៅដួលសន្លប់។ តាមរបាយការណ៍របស់មន្ត្រីសុខាភិបាលបានឱ្យដឹងថា មូលហេតុនៃ អាការៈខាងលើនេះ បណ្តាលមកពីការទទួលទានចំណីអាហារមិនមានសុវត្ថិភាព និងសុខុមាលភាព ការបរិភោគគ្មានតុល្យភាព ការគេងមិនគ្រប់គ្រាន់ បរិស្ថានសិក្សាខ្វះអនាម័យ ការខ្វះចន្លោះ ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យការលក់ដូរចំណីអាហារ និងការចាត់វិធានការអនុវត្តដែលមិន ទាន់បានល្អប្រសើរនៅតាមគ្រឹះស្ថានសិក្សា (**អ.យ.ក, ២០១៣**)

## ២.២.២ ស្តង់ដាទី២៖ ការលើកកម្ពស់សុខភាពចាំបាច់ដល់គ្រូបង្រៀន និងសិស្ស

បន្ទប់សុខភាពនៅតាមគ្រឹះស្ថានសិក្សា ជាកន្លែងសម្រាប់អ្នកសិក្សានិងបុគ្គលិក អប់រំមកទទួលសេវាថែទាំសុខភាពបឋម ដោយមានមុខងារជួយសម្រួលឬសង្គ្រោះបឋម នូវបញ្ហាសុខភាព កាត់បន្ថយការឈឺចាប់ ដែលបានកើតឡើងនៅក្នុងគ្រឹះស្ថានសិក្សាមុនឈានទៅរកសេវាពិនិត្យព្យាបាលនៅតាមមន្ទីរពេទ្យឬមណ្ឌលសុខភាព។ បន្ទប់សុខភាពក៏ជាកន្លែងផ្តល់ប្រឹក្សាសុខភាពផ្លូវកាយ ផ្លូវចិត្ត សុខភាពបន្តពូជនិងសុខភាពផ្លូវភេទផងដែរ។ បន្ទប់សុខភាពនៅតាមគ្រឹះស្ថានសិក្សាត្រូវមានគណៈកម្មការ

គ្រប់គ្រង ដឹកនាំ មានទីតាំងបន្ទប់នៅជាន់ផ្ទាល់ដី មានសម្ភារៈបម្រើការងាររដ្ឋបាល សម្ភារៈអប់រំសុខភាព និងថ្នាំព្យាបាល ។

ការពិនិត្យសុខភាពអ្នកសិក្សាធ្វើឡើងតាមកាលកំណត់ ដើម្បីដឹងពីស្ថានភាព សុខភាពនិងអាចកាត់បន្ថយនូវគ្រោះថ្នាក់ធ្ងន់ធ្ងរឬពិការភាព ហើយផ្តល់ប្រឹក្សានៃការថែទាំសុខភាព ឬស្វែងរកសេវាព្យាបាលទាន់ពេលវេលាតាមបច្ចេកទេសវេជ្ជសាស្ត្រត្រឹមត្រូវ។ គណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សានីមួយៗ ពិសេសមន្ត្រីទទួលបន្ទុកបន្ទប់សុខភាពត្រូវសហការជាមួយមន្ត្រីសុខាភិបាលដើម្បីផ្តល់សេវាពិនិត្យសុខភាពដោយធ្វើឡើងយ៉ាងហោចណាស់១ដងក្នុង១ឆ្នាំសិក្សា ដែលប្រព្រឹត្តទៅជារៀងរាល់ដើមឆ្នាំសិក្សានីមួយៗ ។ សៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាព ជាសម្ភារៈឧបទេសចាំបាច់ក្នុងការបង្រៀនមុខវិជ្ជាអប់រំសុខភាព។ ក្រៅពីសៀវភៅសិក្សាគោល គ្រឹះស្ថានសិក្សាអាចប្រើប្រាស់សៀវភៅ ឬឯកសារអប់រំផ្សព្វផ្សាយផ្សេងៗដែលចេញផ្សាយដោយក្រសួងអប់រំ យុវជន និងកីឡាដើម្បីយកមកបង្រៀនសិស្សឱ្យឆ្លើយតបទៅតាមស្ថានភាពសុខភាពរបស់អ្នកសិក្សាទាំងជំងឺឆ្លង ជំងឺមិនឆ្លង ការបង្ការគ្រោះថ្នាក់នានា ការអប់រំបង្ការគ្រឿងញៀនខុសច្បាប់។ ដើម្បីអនុវត្តសុខភាពសិក្សានៅសាលារៀនឱ្យមានប្រសិទ្ធភាព គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវណែនាំគ្រូទទួលបន្ទុកថ្នាក់បញ្ចូលម៉ោងអប់រំសុខភាពក្នុងផែនការប្រចាំឆ្នាំ កិច្ចតែងការ និងកាលវិភាគប្រចាំសប្តាហ៍

វ៉ាក់សាំងនិងថ្នាំបង្ការផ្សេងទៀត ជាឧបករណ៍ដ៏មានប្រសិទ្ធភាពក្នុងការបង្ការជំងឺ នានាដែលអាចបង្ការបាន។ បុគ្គលិកអប់រំ និងអ្នកសិក្សាអាចទៅទទួលវ៉ាក់សាំងនៅតាម មូលដ្ឋានសុខាភិបាលទូទាំងប្រទេស ឬតាមកាលកំណត់នៃការផ្តល់វ៉ាក់សាំងដែលជូនដំណឹងដោយអាជ្ញាធរមានសមត្ថកិច្ចនៅតាមមូលដ្ឋានរបស់ខ្លួន។ គ្រឹះស្ថានសិក្សានីមួយៗចាំបាច់ត្រូវសហការជាមួយមូលដ្ឋានសុខាភិបាលដែលនៅជិតក្នុងការជំរុញអ្នកសិក្សាទាំងអស់ឱ្យទទួលយកការផ្តល់ថ្នាំបង្ការជំងឺ វ៉ាក់សាំង និងថ្នាំបង្ការផ្សេងៗទៀតឱ្យបានគ្រប់ៗគ្នាស្របតាមកម្មវិធីជាតិផ្តល់ថ្នាំបង្ការនៃក្រសួងសុខាភិបាល ជាពិសេសសិស្សមត្តេយ្យសិក្សា និងបឋមសិក្សា។

### ២.២.៣ ស្តង់ដាទី៣៖ ការលើកកម្ពស់ការផ្តល់អាហារូបត្ថម្ភ

សាលារៀបចំឱ្យមានយន្តការលើកកម្ពស់សុវត្ថិភាពចំណីអាហារ និងអាហារប្រកបដោយសុខភាពដើម្បីធានាសុខភាព សុវត្ថិភាព និងសុខុមាលភាព ដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស សាលារៀននីមួយៗត្រូវយកចិត្តទុកដាក់បំប៉ន សមត្ថភាពដល់មន្ត្រីរបស់ខ្លួន ដើម្បីចូលរួមអនុវត្តការលើកកម្ពស់សុវត្ថិភាពចំណីអាហារ អាហារូបត្ថម្ភ និងអាហារប្រកបដោយសុខភាព ស្របតាមគោលការណ៍ណែនាំរបស់ ក្រសួងអប់រំ យុវជន និងកីឡា។ ការអនុវត្តយន្តការលើកកម្ពស់សុវត្ថិភាពចំណីអាហារ និងអាហារប្រកបដោយ សុខភាព ត្រូវមានការចូលរួមពីអ្នកពាក់ព័ន្ធដូចជាម្ចាស់អាហារដ្ឋាន អ្នកលក់ដូរចំណីអាហារ ឬអ្នកផ្តល់អាហារនៅតាមគ្រឹះស្ថាន សិក្សានីមួយៗ។ លើសពីនេះសាលាត្រូវសហការជាមួយអង្គភាព ស្ថាប័នពាក់ព័ន្ធជំនាញដើម្បីត្រួតពិនិត្យតាមដានពី សុវត្ថិភាពចំណីអាហារ និងអាហារូបត្ថម្ភនៅតាមអង្គភាព របស់ខ្លួនជាប់ជាប្រចាំ។ យោងៈ សេចក្តីណែនាំលេខ ១៨ អយក.សណន ចុះថ្ងៃព្រហស្បតិ៍ ១៣រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា អនាម័យនាំយកនូវសុខភាពល្អគ្រឹះស្ថានសិក្សានីមួយៗត្រូវយកចិត្តទុកដាក់សហការជាមួយអ្នកពាក់ព័ន្ធជាពិសេសអ្នកលក់ដូរនិងអ្នកផ្តល់ចំណីអាហារដើម្បីផ្តល់អាហារប្រកបដោយសុវត្ថិភាព និងអាហារូបត្ថម្ភដល់អ្នកសិក្សា និងហាមឃាត់ការលក់ ដូរចំណីអាហារដែលប៉ះពាល់ដល់សុខភាព ដោយធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ

-ចំណីអាហារហាមឃាត់ក្នុងសាលា

១-ចំណីអាហារគ្រប់ប្រភេទដែលហួសកំណត់កាលបរិច្ឆេទប្រើប្រាស់

២-គ្រឿងស្រវឹង និងផលិតផលថ្នាំជក់គ្រប់ប្រភេទ

៣-ចំណីអាហារដែលមិនមានប្រភពច្បាស់លាស់

៤-ភេសជ្ជៈប៉ូវកម្លាំង ភេសជ្ជៈផ្អែម ការហ្វេ ការ៉េម ទឹកស៊ីរ៉ូគ្រប់ប្រភេទ

៥-ស្ករសូឡា ស្ករគ្រាប់ និងស្ករកៅស៊ូគ្រប់ប្រភេទ

៦-ចាហួយគ្រប់ប្រភេទ នំដូណាត់ នំផ្អែម

សុខភាពសិស្ស គឺជាកត្តាចម្បងដែលជះឥទ្ធិពលសមិទ្ធិផលការសិក្សារបស់សិស្ស និងការចូលរួមនៅសាលា តាមការសិក្សាស្រាវជ្រាវមានសាលាគំរូបបីប្រភេទគឺ សាលារៀននៅក្នុងទីក្រុង សាលានៅទីជនបទដែលមានកម្មវិធី "អាហារនៅសាលា" និងសាលារៀននៅជនបទដែលគ្មានកម្មវិធី "អាហារនៅសាលា" ។ ការស្រាវជ្រាវសាលាបឋមសិក្សាក្នុងប្រទេសកម្ពុជា សិស្សសាលានៅទីក្រុងមានកម្ពស់ខ្ពស់ និងទម្ងន់ធ្ងន់ជាងសិស្សសាលានៅទីជនបទ ទាំងសាលាមានកម្មវិធី "អាហារនៅសាលា" និងសាលាគ្មានកម្មវិធី "អាហារនៅសាលា" សិស្សសាលានៅទីជនបទក្នុងសាលាគ្មានកម្មវិធី "អាហារនៅសាលា" គឺខ្លី និងស្រាលបំផុត ការសេចក្តីសន្និដ្ឋានកម្មវិធីអាហារនៅសាលារៀនមានឥទ្ធិពលវិជ្ជមានទៅលើការលូតលាស់របស់កុមារ ។ សាលានៅជនបទដែលគ្មានកម្មវិធី "អាហារក្នុងសាលារៀន" គួរតែត្រូវបានពង្រីកដល់សាលាបឋមសិក្សានៅតាមជនបទ ក្នុងការលើកកម្ពស់កំណើនកុមារ និងបញ្ហាសុខភាពកុមារ ដើម្បីជាការលើកទឹកចិត្តឱ្យពួកគេចូលរៀនក្នុងសាលា (Chansean Mam, 2021) ។

នៅសាលារៀនមានសួនបន្លែនិងសួនជីវៈចម្រុះដូចជា រោងបន្លែ ដំណាំ ការដាំដើមឈើពហុប្រយោជន៍តាមស្ថានភាពដីដើម្បីទទួលបានចំណេះដឹងបរិស្ថានស្អាត និងបង្ហាញពីភាពចម្រុះនៃប្រភេទបន្លែ ផ្លែឈើសម្រាប់បរិភោគ។ គ្រឹះស្ថានសិក្សាអាចរៀបចំសួនបន្លែតាមលទ្ធភាពផ្អែកលើទីតាំងភូមិសាស្ត្រ រដូវកាលនៃពូជដំណាំចម្រុះវិលជុំរយៈពេលខ្លីដូចជា ត្រកួន ស្ពៃ សណ្តែកកួរ ននោង ត្រឡាច ម្ទេស ត្រសក់ ស្ពៃក្តោប គ្រប់ ខាត់ណា ឆៃថាវ ជាដើម ព្រមទាំងអាចពិនិត្យលទ្ធភាព ចិញ្ចឹមត្រី ឬសត្វមួយចំនួនតាមបច្ចេកទេសកសិកម្ម។ គ្រឹះស្ថានសិក្សាត្រូវសហការជាមួយមន្ត្រីជំនាញកសិកម្ម ឬអ្នកពាក់ព័ន្ធនៅតាមមូលដ្ឋានរបស់ខ្លួនក្នុងការផ្តល់ប្រឹក្សាបច្ចេកទេសអំពីការដាំដុះនិងការចិញ្ចឹមសត្វស្របតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវដើម្បីទទួលបានលទ្ធផលខ្ពស់និងមានសុវត្ថិភាពក្នុងការទទួលទាន។

### ២.២.៤ ស្តង់ដាទី៤៖ ការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

ទឹកជាសារធាតុដែលមនុស្សគ្រប់រូបត្រូវការចាំបាច់ជារៀងរាល់ថ្ងៃដើម្បីទ្រទ្រង់ជីវិតរស់នៅប្រចាំថ្ងៃ។ ការទទួលទានទឹកមិនត្រឹមតែបំបាត់នូវការស្រេកទឹកទេ តែវាផ្តល់ផលប្រយោជន៍ជាច្រើនដល់សារពាង្គកាយរបស់មនុស្ស។ ទឹកអាចជួយឱ្យអ្នកមានអារម្មណ៍ល្អ ជំរុញឱ្យពោះវៀនមានចលនា កុំឱ្យទល់លាមក បណ្តេញជាតិពុលពីរាងកាយ កុំឱ្យមានបញ្ហាក្លិនមាត់ បង្កើនភាពឃ្លានអាហារ និងជួយទប់ស្កាត់ការឈឺក្បាល។ គ្រឹះស្ថានសិក្សាចាំបាច់ត្រូវមានទឹកស្អាតសម្រាប់ទទួលទានប្រចាំថ្ងៃឱ្យបានគ្រប់គ្រាន់ដើម្បីធានាសុខភាព សុវត្ថិភាព និងសុខុមាលភាពដល់អ្នកសិក្សានិងបុគ្គលិកអប់រំ។ ក្នុងដំណាក់កាលដំបូងៗ ... គ្រឹះស្ថានសិក្សាអាចចាប់ផ្តើមដោយឱ្យសិស្សយកទឹក ទទួលទានពីផ្ទះរបស់ខ្លួន ហើយបន្តិចម្តងៗគ្រឹះស្ថានសិក្សាអាចចាប់ផ្តើមមានធុងទឹកចម្រុះ ឬទឹកស្អាតបន្ថែមសម្រាប់តម្រូវការប្រចាំថ្ងៃ និងរហូតដល់តម្លើងបណ្តាញទឹកស្អាតសម្រាប់ទទួលទានពេញលេញ។ គ្រឹះស្ថានសិក្សាអាចលើកសំណើតបណ្តាញទឹកស្អាតសម្រាប់ទទួលទាន ឧបករណ៍ ស្តុកទឹកស្អាតសម្រាប់ទទួលទាននៅតាមគ្រឹះស្ថានសិក្សាពីឃុំ សង្កាត់ អ្នកផ្គត់ផ្គង់ទឹកឯកជន សប្បុរសជន និងអ្នកអាណាព្យាបាល ដោយផ្តើមពីលទ្ធភាពទទួលបានធុងចម្រះ ប្រព័ន្ធបន្សុទ្ធទឹកស្អាតឬទឹកសម្រាប់ទទួលទានធុងតូចធំតាមធនធានរបស់គ្រឹះស្ថានសិក្សានីមួយៗ ។ ក្នុងប្រទេសកម្ពុជាមានសាលារៀនទូទាំងប្រទេសចំនួន ៥៨.៧% គ្មានទឹកប្រើប្រាស់ ក្នុងនោះបឋមសិក្សា៥៧.៧% គ្មានទឹកប្រើប្រាស់ទាំងនេះធ្វើឱ្យប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់សុខភាពរបស់សិស្ស និងបុគ្គលិកអប់រំ ជាដើមចមនៃការធ្លាក់ចុះនូវលទ្ធផលសិក្សារបស់សិស្ស និងការបង្រៀនរបស់គ្រូ (**អ.យ.ក, ២០២១-២០២២**) ។

វត្តមានបង្គន់អនាម័យនិងបង្គន់នោមព្រមទាំងទឹកស្អាតតាមសាលារៀនគ្រប់គ្រាន់ នឹងជួយឱ្យសិស្សមានទំលាប់ល្អឈប់បន្ទោបង់ពាសវាលពាសកាល សាលារៀនមានអនាម័យ និងបរិស្ថានស្អាតទាក់ទាញសិស្សចូលរៀនកាន់តែច្រើននិងទៀងទាត់ លោកគ្រូ អ្នកគ្រូរីករាយនឹងឃើញសិស្សមានសុខភាពល្អ។ ការសាងសង់បង្គន់អនាម័យត្រូវធានាថាសិស្សគ្រប់រូបអាចប្រើប្រាស់បាន ពិសេសមានទឹកលាងត្រូវមានជម្រាលសម្រាប់សិស្សពិការកាយសម្បទា។ បង្គន់អនាម័យដែលសាងសង់រួច ត្រូវមាន

ដំណើរការល្អសម្រាប់សិស្សអាចចូលប្រើប្រាស់បានគ្រប់ម៉ោងសិក្សា សម្អាតយកមកពីប្រភពដែលបាន កែលម្អគ្រប់គ្រាន់ មានគន្លឹះទ្វារបិទពីក្នុង គ្មានប្រហោង ដែលអាចលួចមើលបាន និងមានបែងចែករវាង បង្គន់ស្រី និងប្រុសដាច់ដោយឡែកពីគ្នា។ សាលារៀនត្រូវមានបម្រុងសំឡីអនាម័យសម្រាប់សិស្សស្រី ប្រើប្រាស់ពេលត្រូវការបន្ទាន់ និងមានធុងសំរាមក្នុងបង្គន់អនាម័យស្រីនីមួយៗ។

គ្រឹះស្ថានសិក្សារៀបចំការទុកដាក់សំរាមឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ព្រោះបើទុក ដាក់មិនបានត្រឹមត្រូវ សំរាមនឹងក្លាយជាប្រភពចម្លងរោគដល់មនុស្សសត្វដែលនៅជុំវិញ ។ ដើម្បីអនុវត្ត ការងារនេះមានប្រសិទ្ធភាព គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវដឹកនាំៈ

- រៀបចំដាក់ធុងសំរាមក្នុងបរិវេណគ្រឹះស្ថានសិក្សាដោយមានការញែកកាកសំណល់/សំរាមត្រឹម ត្រូវតាមលក្ខណៈបច្ចេកទេសដូចជាសំណល់សរីរាង្គ សំណល់ផ្សេងៗ និងសំណល់កែច្នៃ និង ធានាថាគ្មានសំរាមនៅក្នុង បរិវេណគ្រឹះស្ថានសិក្សានិងបន្ទប់រៀន
- រៀបចំបង្កើតវេនសម្អាតបរិវេណសាលារៀន បន្ទប់រៀន បង្គន់អនាម័យ និង បរិក្ខារលាងសម្អាត ដៃដល់សិស្ស និងតាមដានដំណើរការសម្អាតជាប្រចាំ រៀបចំបង្កើតយុទ្ធនាការនានា សំដៅធ្វើ ឱ្យគ្រឹះស្ថានសិក្សាមានបរិស្ថានស្អាត និងមានសុវត្ថិភាព ដូចជាការដាក់ស្លាកសញ្ញា "កុំចោល សំរាមក្រៅធុងសំរាម" ឬ "ហាមយកថង់ប្លាស្ទិកឬចានស្នើរចូលក្នុងបរិវេណគ្រឹះស្ថានសិក្សា" ជា ដើម បរិក្ខារលាងសម្អាតដៃជាឧបករណ៍ចាំបាច់សម្រាប់អនុវត្តវិធានការអនាម័យផ្ទាល់ខ្លួនជា ប្រចាំ ដែលគ្រឹះស្ថានសិក្សាចាំបាច់ត្រូវរៀបចំតម្លើងតាមសមាមាត្រអ្នកសិក្សា និងបុគ្គលិកអប់រំ ដើម្បីឱ្យពួកគេមានលទ្ធភាពលាងសម្អាតដៃជាប្រចាំ ឬនៅពេលចាំបាច់គ្រប់វេនសិក្សា។បរិក្ខារ លាងសម្អាតដៃត្រូវរៀបចំតម្លើងនៅជិតបង្គន់អនាម័យ ជិតបន្ទប់រៀន ឬក្បែរអាហារដ្ឋាន តាម ជម្រើសផ្សេងៗអនុលោមតាមធនធានរបស់គ្រឹះស្ថានសិក្សា។ បរិក្ខារលាងសម្អាតដៃទាំងអស់ ត្រូវមានទឹក សាប៊ូព្រមទាំងមានភាពស្អាតជាប់ជាប្រចាំ។និងអាចប្រើប្រាស់បានសម្រាប់មនុស្ស គ្រប់រូប។

### ២.២.៥ ស្តង់ដាទី៥៖ ការលើកកម្ពស់បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាបន្ន ផាសុខភាព និងមេត្រីភាព

បរិស្ថានសិក្សាមានភាពចាំបាច់ណាស់ចំពោះអ្នកសិក្សា ដែលគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវយកចិត្តទុកដាក់ជាចម្បង ដោយត្រូវគិតពីសុវត្ថិភាព បរិយាបន្ន ផាសុកភាព និងមេត្រីភាព ដោយធ្វើយ៉ាងណាធ្វើឱ្យគ្រឹះស្ថានសិក្សាគ្មានកន្លែងដក់ទឹក ភក់ ជាំ គ្មាន សំរាម គ្មានសំបុកពីងពាង គ្មានផ្សែងបារី គ្មានការប្រើប្រាស់ផលិតផលប្លាស្ទិក។ល។ ផ្ទុយទៅវិញគ្រឹះស្ថានសិក្សា ត្រូវមានបំពាក់នូវស្លាកសញ្ញាសុវត្ថិភាពផ្សេងៗ មាន របងការពារកន្លែងមានហានិភ័យ មានកន្លែងជួបជុំពេលមានហានិភ័យ អគ្គីភ័យ គ្រោះទឹកជំនន់ មានបរិស្ថានស្អាតជាប់ជាប្រចាំ។ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវដឹកនាំចលនាស្អាតក្នុងចំណោមក្រុមប្រឹក្សាកុមារ យុវជន ពិសេសត្រូវមានយន្តការបោសសម្អាតបរិវេណគ្រឹះស្ថានសិក្សា បន្ទប់រៀន និងកន្លែងផ្សេងៗទៀតនៃគ្រឹះស្ថានសិក្សា ដើម្បីធានាថា បុគ្គលិកអប់រំនិងអ្នកសិក្សាមានសុវត្ថិភាព។

ការរៀបចំឱ្យមានសួនច្បារនៅក្នុងបរិវេណគ្រឹះស្ថានសិក្សាចាត់ទុកថា ជាកត្តាមួយសំខាន់បំផុតនៅក្នុងពេលបច្ចុប្បន្នក៏ដូចជាទៅអនាគត ព្រោះសួនច្បារបានក្លាយទៅជាចំណុចសំខាន់មួយដោយសារជាមុខជាមាត់របស់គ្រឹះស្ថានសិក្សា។ ទាំងជាការបំពេញបន្ថែមដល់ចំណីចក្ខុវិញ្ញាណនិងភាពរីករាយដល់មនុស្សគ្រប់រូបដែល បានចូលមកដល់ទីនេះព្រមទាំងទាក់ទាញសិស្សានុសិស្សរបស់យើងឱ្យចង់មកគ្រឹះស្ថានសិក្សាផងដែរ មានសួនច្បារអាចកាត់បន្ថយភាពតានតឹងចិត្តជួយបន្ធូរអារម្មណ៍នៅក្នុងខួរក្បាល។

### ២.២.៦ ស្តង់ដាទី៦៖ ការលើកកម្ពស់សន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងសាលា

ផ្អែកលើសន្និបាតអប់រំ របស់ក្រសួងអប់រំឆ្នាំ២០២៣ ស្តីពីឯកសារទស្សនាទានសុខភាពសិក្សាក្នុងបរិបទថ្មី ក្នុងចំណុច ២.៦ លើកឡើងពីការលើកកម្ពស់សន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងគ្រឹះស្ថានសិក្សា ការផ្តោតទៅលើរៀបចំវេនយាមទៅតាមច្រកចេញចូលគ្រប់ពេលម៉ោងសិក្សា ។

គ្រឹះស្ថានសិក្សាចាំបាច់ត្រូវចាត់តាំងឱ្យមានក្រុមទទួលបន្ទុកសន្តិសុខសណ្តាប់ធ្នាប់ របស់គ្រឹះស្ថានសិក្សាផ្ទាល់ ដឹកនាំដោយគណៈគ្រប់គ្រង និងមានសមាសភាពចូលរួមពី អាជ្ញាធរមូលដ្ឋាន កងកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាល កងកម្លាំងកងរាជអាវុធហត្ថ ប្រជាការ ពារមូលដ្ឋាន និងក្រុមយុវជនស្ម័គ្រចិត្ត ដែលមានតួនាទីភារកិច្ច និងការទទួលខុសត្រូវ ច្បាស់លាស់។ ក្រុមសន្តិសុខនិងសណ្តាប់ធ្នាប់ប្រចាំគ្រឹះស្ថានសិក្សា មានភារកិច្ចរក្សាសន្តិសុខនៅ តាមច្រកចេញ-ចូលគ្រឹះស្ថានសិក្សាជាប្រចាំ ដើម្បីត្រួតពិនិត្យនិងផ្តល់ព័ត៌មានពីសកម្មភាព អ្នកចេញ-ចូល។ ក្នុងករណីមានជនសង្ស័យធ្វើសកម្មភាពមិនប្រក្រតីក្នុងបរិវេណគ្រឹះស្ថានសិក្សា ត្រូវរាយការណ៍បន្ទាន់ជូនប្រធានក្រុមសន្តិសុខនិងសណ្តាប់ធ្នាប់ប្រចាំគ្រឹះស្ថានសិក្សា ដើម្បីមានវិធានការឆ្លើយតប។ គ្រឹះស្ថានសិក្សាអាចចាត់តាំងតំណាងក្រុមប្រឹក្សាកុមារ ក្រុមប្រឹក្សាយុវជន ដើម្បី ចូលរួមពង្រឹងសន្តិសុខ សណ្តាប់នៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួន ក្រៅពីការងារទាំងនេះ ក្រុមប្រឹក្សាកុមារឬក្រុមប្រឹក្សាយុវជនអាចចូលរួមជួយការងារចរាចរណ៍នៅមុខគ្រឹះស្ថានសិក្សា និងចូលរួមការអប់រំផ្សព្វផ្សាយពីការបង្ការអំពើអនាចារ ការជួញដូរ ការប្រើប្រាស់ គ្រឿងញៀនខុសច្បាប់ អំពើហិង្សា និងរាយការណ៍ពីសកម្មភាពក្មេងទំនើងជូនសមត្ថកិច្ចបានទាន់ពេលវេលាផងដែរ។

គ្រឹះស្ថានសិក្សានឹងចូលរួមអនុវត្តសកម្មភាពសំខាន់ៗ ដើម្បីជំរុញគ្រឹះស្ថានសិក្សាមានសុវត្ថិភាពគ្រប់ជ្រុងជ្រោយ សំដៅបង្កើនបរិយាកាសសិក្សាប្រកបដោយគុណភាព សុវត្ថិភាព សុខុមាលភាព និងមេត្រីភាព ព្រមទាំងកាត់បន្ថយហានិភ័យនៃគ្រោះថ្នាក់ទាំងអស់ជូនបុគ្គលិកអប់រំ និងអ្នកសិក្សាដូចខាងក្រោម៖

- បំពាក់សម្ភារៈសុវត្ថិភាព ប្រព័ន្ធបញ្ជូនដំណឹងពីគ្រោះធម្មជាតិ គ្រោះមហន្តរាយ និងអគ្គីភ័យ
- លេខទូរសព្ទទាន់ហេតុការនានា ដើម្បីស្នើកិច្ចអន្តរាគមន៍បន្ទាន់ណាមួយកើតឡើងនៅក្នុងគ្រឹះស្ថានសិក្សា

## ២.២.៧ ស្តង់ដាទី៧៖ ការលើកកម្ពស់ការអប់រំសុខភាព

ការអប់រំកាយនិងកីឡាជាធាតុសំខាន់នៃការអប់រំពេញមួយជីវិតនៅក្នុងប្រព័ន្ធអប់រំ ការអប់រំកាយនិងកីឡាជានាអភិវឌ្ឍនិងរក្សាការពារកម្លាំងកាយ បញ្ញា ស្មារតី និងសីលធម៌ របស់មនុស្ស។ ការរៀបចំឱ្យមានបរិស្ថានល្អ ខ្យល់អាកាសបរិសុទ្ធ មានឧទ្យានបៃតង និង ទីធ្លាសម្រាប់អនុវត្តអប់រំកាយនិងកីឡា ដើម្បីទ្រទ្រង់សុខភាពនិងសុខុមាលភាពប្រជាជន ទាំងផ្លូវកាយទាំងផ្លូវចិត្ត។ គ្រឹះស្ថានសិក្សាជាកន្លែងដែលសមស្របបំផុតសម្រាប់សិស្សានុ សិស្សអនុវត្តអប់រំកាយនិងកីឡា ដូច្នេះគ្រឹះស្ថានសិក្សាត្រូវរៀបចំឱ្យមានទីលានសម្រាប់ អនុវត្តអប់រំកាយ និងកីឡាដើម្បីឆ្លើយតបទៅតម្រូវការចាំបាច់របស់សិស្សានុសិស្ស និង បុគ្គលិកអប់រំផងដែរ។ ដើម្បីបង្កើតទីលានសម្រាប់អនុវត្តអប់រំកាយ និងកីឡាឱ្យសមស្របតាមគ្រឹះស្ថានសិក្សាលោកគ្រូ អ្នកគ្រូគួរគិតដល់ការរៀបចំក្រុមការងារដែលមានសមាសភាពចូលរួមពី គណៈកម្មការគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូអ្នកគ្រូ គ្រូអប់រំកាយនិងកីឡា និងអ្នក មានជំនាញផ្នែកកីឡា។ ក្រុមការងារប្រជុំពិនិត្យពីតម្រូវការទីលានសម្រាប់អនុវត្តអប់រំកាយ និងកីឡាធនធានសាលាដែលមាននិងកៀគរប្រភពធនធានផ្សេងៗទៀតដែលអាចរកបាន។

មុខវិជ្ជាអប់រំសុខភាព ត្រូវបានកំណត់ជាមុខវិជ្ជាមួយដែលមានចែងក្នុងក្របខណ្ឌ កម្មវិធីសិក្សាឆ្នាំ២០១៦ - ២០២៥ ដែលក្នុងនោះមាន១ម៉ោងក្នុង១សប្តាហ៍ពីថ្នាក់ទី១ ដល់ទី១២។ មុខវិជ្ជាអប់រំសុខភាពត្រូវបានរៀបចំជាកម្មវិធីសិក្សាលម្អិតនិងសៀវភៅសិក្សាគោលសម្រាប់គ្រូ សិស្ស ហើយដើម្បីឱ្យមុខវិជ្ជានេះយកទៅបង្រៀនបានត្រឹមត្រូវ ។

នៅសហរដ្ឋអាមេរិក លំហាត់ប្រាណទៀងទាត់អាចកាត់បន្ថយហានិភ័យនៃការវិវត្តនៃជំងឺរ៉ាំរ៉ៃក្នុងចំណោមមនុស្សពេញវ័យ ១.ជំងឺសរសៃឈាមបេះដូង ២.មហារីក ៣. ជំងឺទឹកនោមផ្អែម ការចូលរួមជាទៀងទាត់ក្នុងសកម្មភាពរាងកាយនៅក្មេង រួមចំណែកដល់ការលូតលាស់ឆ្អឹង និងសាច់ដុំដែលមានសុខភាពល្អ កាត់បន្ថយអារម្មណ៍ធ្លាក់ទឹកចិត្ត និងការថប់បារម្ភ និងលើកកម្ពស់សុខុមាលភាពផ្លូវចិត្ត។ លើសពីនេះ ការហាត់ប្រាណទៀងទាត់កាត់បន្ថយហានិភ័យសម្រាប់ការកើនឡើងនៃការលើសទម្ងន់ក្នុងចំណោមយុវជន។ ក្នុងឆ្នាំ ២០០៤ ១៨.៨% នៃក្មេងអាយុពី ៦ ទៅ ១១ ឆ្នាំ និង ១៧.៤% នៃ

ក្មេងអាយុពី ១២ ទៅ ១៩ ឆ្នាំត្រូវបានគេចាត់ទុកថាធាត់ ។ គោលការណ៍ណែនាំស្តីពីរបបអាហាររបស់សហរដ្ឋអាមេរិកសម្រាប់ជនជាតិអាមេរិកបានផ្តល់អនុសាសន៍ថាមនុស្សវ័យក្មេង (អាយុ ៦-១៩ ឆ្នាំ) របាយការណ៍ស្តីពីតុល្យភាពបានផ្តល់អនុសាសន៍ថា សិស្សត្រូវបានផ្តល់ឱកាសឱ្យចូលរួមក្នុងសកម្មភាពរាងកាយយ៉ាងហោចណាស់ ៦០ នាទីក្នុងអំឡុងពេលថ្ងៃសិក្សា (SARAH M. LEE, PhDa CHARLENE R. BURGESON, MAb JANET E. FULTON, PhDc CHRISTINE G. SPAIN, MA, 2006) ។

### ២.២.៨ ស្តង់ដាទី៨៖ ការលើកកម្ពស់ការអនុវត្តបំណិនសុខភាព

ការអនុវត្តវិធានការបង្ការជំងឺឆ្លងនិងជំងឺមិនឆ្លង ជាភារកិច្ចរបស់បុគ្គលិកអប់រំ និងអ្នកសិក្សានៅគ្រប់គ្រឹះស្ថានសិក្សា ក្នុងកាលៈទេសៈមួយចំនួនគ្រឹះស្ថានសិក្សាចាំបាច់ត្រូវអនុវត្តនូវវិធានការនានាយ៉ាងម៉ឺងម៉ាត់របស់ក្រសួងសុខាភិបាលឬក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបង្ការការពារអាយុជីវិតបុគ្គលិកអប់រំ និងអ្នកសិក្សាជាក់ស្តែងដូចជាការ បង្ការការរាតត្បាតនៃជំងឺកូវីដ-១៩ ជាដើម។

នៅក្នុងដំណាក់កាលកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំយុទ្ធសាស្ត្រស្តីពីការបើកដំណើរការគ្រឹះស្ថានសិក្សាឡើងវិញដោយឈរលើអភិក្រមពីរគឺ ១.ការបើកតាមដំណាក់កាលសម្រាប់គ្រឹះស្ថានសិក្សាណាដែលអាចអនុវត្ត «ស្តង់ដា សុវត្ថិភាពសុខភាព» និង ២. ការបន្តការសិក្សាតាមបែបចម្រុះ ដោយគួបផ្សំការសិក្សាក្នុងថ្នាក់រៀន និងការសិក្សា ពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិក និងតាមបែបប្រពៃណីរួមទាំងការធ្វើស្វ័យសិក្សា(សម្រាប់សិស្សនៅទីជនបទ)។ គោលការណ៍ប្រតិបត្តិស្តង់ដាសម្រាប់ដំណើរការសាលារៀនឡើងវិញក្នុងបរិបទកូវីដ-១៩ ដែលបានរៀបចំឡើង មានវត្ថុបំណងណែនាំអំពីវិធាននានា រួមទាំងវិធានការសុខាភិបាល ដើម្បីគ្រឹះស្ថានសិក្សាអាចរៀបចំ និងត្រៀមលក្ខណៈដំណើរការការបង្រៀននិងរៀនឡើងវិញ ក៏ដូចជាការបន្តអភិវឌ្ឍគ្រឹះស្ថានសិក្សានីមួយៗឱ្យមាននិរន្តរភាព ធានាបាននូវសុវត្ថិភាព សុខភាពសម្រាប់បុគ្គលិកសិក្សា គ្រូបង្រៀន និងសិស្សានុសិស្សក្នុងបរិបទ កូវីដ១៩ និងទៅអនាគត។ ក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការ គ្រប់គ្រង បង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ដើម្បីធានាសុវត្ថិភាព និងសុខុមាលភាពរបស់ សិស្សានុសិស្ស និងបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់។ ចាប់តាំង

ពីរកឃើញករណីការឆ្លងជំងឺកូវីដ១៩ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវវិធានការជាច្រើន ដូចជាចេញសេចក្តីជូនដំណឹង និងសេចក្តីណែនាំជាច្រើន ដែលពាក់ព័ន្ធនិង ១.វិធានការសុខភាព ដោយអនុលោមទៅតាមសេចក្តីណែនាំ និងវិធានការបច្ចេកទេសចាំបាច់ របស់អង្គការសុខភាពពិភពលោក និងក្រសួងសុខាភិបាល ២.ការរៀបចំរដ្ឋបាលឌីជីថល ៣. ការលើកកម្ពស់ វិធានការគម្លាតសុវត្ថិភាព និង៤. ការរៀបចំប្រព័ន្ធអប់រំអេឡិចត្រូនិក និងការផ្តល់សេវារៀនពីចម្ងាយ **(អ.យ.ក, ២០២០)** ។

ការផ្តល់ចំណេះដឹង បំណិន និងឥរិយាបទត្រឹមត្រូវ តាមរយៈមុខវិជ្ជាអប់រំសុខ ភាព និងប្រធានបទសុខភាពសាធារណៈថ្មីៗ គឺដើម្បីឱ្យសិស្សមានបំរុងប្រយ័ត្នក្នុងការ យកចិត្តដាក់ថែទាំ ការពារ និងបង្ការការឆ្លងជំងឺផ្សេងៗ។ ដើម្បីអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាពគណៈគ្រប់គ្រងត្រូវ៖

- រៀបចំសកម្មភាពដុសសម្អាតធ្មេញនិងលាងសម្អាតដៃតាមកាលវិភាគ ដោយយកច្រាសដុសធ្មេញ និងថ្នាំដុសធ្មេញមកសាលាជាប្រចាំ ដើម្បីអនុវត្តឱ្យក្លាយ ជាទម្លាប់ សម្រាប់បឋមសិក្សា
- អប់រំសិស្សឱ្យអនុវត្តសកម្មភាពលាងសម្អាតដៃមុននិងក្រោយចាប់កាន់ចំណីអាហារ និងក្រោយពេលចេញពីបង្គន់
- រៀបចំសកម្មភាពអប់រំកាយនិងកីឡា ទៅតាមកាលវិភាគជាប្រចាំ
- អនុវត្តវិធានអនាម័យក្នុងការសម្អាតខ្លួនប្រាណ
- រៀបចំសកម្មភាពនានាដែលទាក់ទងនឹងការថែរក្សាបរិស្ថាន ដោយចេះបែងចែកនិងទុកដាក់សំរាមតាមប្រភេទនីមួយៗឱ្យបានត្រឹមត្រូវ។
- ការគ្រប់គ្រងការមករដូវ (MHM) ការប្រើប្រាស់សំពត់កំណាត់។
- គ្រឹះស្ថានសិក្សាបណ្តុះបណ្តាលវិធីសាស្ត្រសង្គ្រោះបឋមដល់លោកគ្រូ អ្នកគ្រូ អ្នកសិក្សាដោយសហការជាមួយមន្ត្រីសាខាកាកបាទក្រហមកម្ពុជាប្រចាំមូលដ្ឋាន ឬ មន្ត្រីសុខាភិបាលដែលនៅជិត ដើម្បីទទួលបានចំណេះដឹងនិងជំនាញសាមញ្ញៗក្នុងការជួយអន្តរាគមន៍សង្គ្រោះបន្ទាន់ពេលមានគ្រោះថ្នាក់កើតឡើងជាយថាហេតុនៅតាមគ្រឹះស្ថានសិក្សា។ ប្រធានបទសង្គ្រោះ

បឋមចាំបាច់មួយចំនួនដែលគ្រឹះស្ថានសិក្សាចាំបាច់ត្រូវបណ្ដុះបណ្ដាលដូចជា ការការពារអ្នករងគ្រោះ ការរុំរបួស ការលើកដាក់អ្នករងរបួសបាក់ឆ្អឹង ការសង្គ្រោះពេលស្លាក់ ពេលឈាមច្រមុះ ពេលរលាកភ្លើង ខ្យល់គ ការសង្គ្រោះពេលពស់ចឹក សត្វខាំ ឬទិច ការសង្គ្រោះពេលលង់ទឹក ការសង្គ្រោះពេលឆក់ខ្សែភ្លើង រន្ទះបាញ់ ការសង្គ្រោះ។ល

## ២.២.៩ ស្តង់ដាទី៩៖ ការលើកកម្ពស់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងអភិវឌ្ឍកម្មវិធីសុខភាពសិក្សា

សកម្មភាពនៃការលើកកម្ពស់សុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា មិនអាចកើតមានឡើយ ប្រសិនបើគ្មានការចូលរួមពីភាគីពាក់ព័ន្ធ។ គ្រឹះស្ថានសិក្សាត្រូវការចាំបាច់ នូវធនធានពីដៃគូពាក់ព័ន្ធ វិស័យឯកជន សប្បុរសជនសម្រាប់គាំទ្រសកម្មភាពសុខភាព សិក្សាប្រកបដោយនិរន្តរភាពតាមរយៈការបង្កើតជាយន្តការកៀរគរប្រភពធនធានដូចមានជាឧទាហរណ៍ខាងក្រោម៖

- រៀបចំការប្រជុំជាសាធារណៈជាមួយមាតាបិតា សប្បុរសជន វិស័យឯកជន និងអ្នកពាក់ព័ន្ធដទៃទៀត តាមពេលវេលាសមស្របដោយប្រាប់ពីតម្រូវការនិងសកម្មភាពការងារសុខភាពសិក្សាដែលគ្រឹះស្ថានសិក្សាត្រូវការប្រចាំឆ្នាំដោយស្នើឱ្យមានការចូលរួមវិភាគទាន
- បង្កើតឱ្យមានការធ្វើបុណ្យផ្កាសាមគ្គីឬហិបសង្គ្រោះដើម្បីយកមថវិកាមកអភិវឌ្ឍគ្រឹះស្ថានសិក្សា

នៅទីក្រុងសៀងហៃ សាលារៀនត្រូវបានគ្រប់គ្រងដោយការិយាល័យអប់រំ នៃរដ្ឋបាលក្រុង/ស្រុក គម្រោងបង្ការគ្រោះថ្នាក់ជាច្រើនប្រភេទ បានដាក់ចេញក្នុងសហគមន៍ ហើយសាលារៀនធ្វើកិច្ចសហប្រតិបត្តិការណ៍ជាមួយសហគមន៍ (Zhi-Juan Cao1† , Yue Chen2† and Shu-Mei Wang1*†, 2014) កម្មវិធីអប់រំសុខភាពតាមសហគមន៍បានបង្ហាញពីឥទ្ធិពលយ៉ាងសំខាន់ក្នុងការធ្វើអោយប្រសើរឡើងនូវជំនឿសុខភាពរបស់សិស្ស គុណសម្បត្តិនៃកិច្ចសហប្រតិបត្តិការនេះគឺ៖ (១) សហគមន៍បានសម្របសម្រួលពីគ្រប់សមាសភាព ដូចជា នាយកដ្ឋានចរាចរណ៍, នាយកដ្ឋានពន្លត់អគ្គីភ័យ និងមន្ទីរសុខាភិបាល, កិច្ចសហប្រតិបត្តិការជួយសម្រួលសហគមន៍ដើម្បីបញ្ជាក់ពីប្រភេទដាក់

លាក់នៃការគ្រោះថ្នាក់ និងកត្តាហានិភ័យ និងផ្តល់ការគាំទ្រផ្នែកបច្ចេកវិទ្យាដល់សាលារៀនក្នុងការអនុវត្តកម្មវិធីការពារការគ្រោះថ្នាក់ ២) ជាមួយជំនួយរបស់គណៈកម្មាធិការលំនៅដ្ឋាន, សហគមន៍អាចទទួលបានការគាំទ្រពីគ្រួសារ ៣) សហគមន៍មានមូលនិធិពិសេស និងអាចផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់គម្រោង ៤) សហគមន៍អាចផ្តល់វេទិកាចាំបាច់សម្រាប់អន្តរាគមន៍ ៥) សិស្សអាចផ្សព្វផ្សាយចំណេះដឹង និងជំនាញអំពីការការពារការគ្រោះថ្នាក់ដល់គ្រួសារ និងសហគមន៍ ។

# ជំពូក៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូក៣៖

# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ គម្រោងវិភាគ

ការស្រាវជ្រាវនេះរៀបចំឡើងដើម្បីសម្រេចវត្ថុបំណងពីរគឺ៖ ១. ឈ្វេងយល់ពីស្ថានភាពបច្ចុប្បន្ននៃការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដា ស្តីពីការលើកកម្ពស់សុខភាពសិក្សាតាមនៅកម្រិតបឋមសិក្សា ២. ឈ្វេងយល់ពីស្ថានភាពនៃការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដា ស្តីពីការលើកកម្ពស់សុខភាពសិក្សានៅកម្រិតបឋមសិក្សារវាងទីប្រជុំជន និងទីជនបទ។ ដើម្បីសម្រេចវត្ថុបំណងខាងលើអ្នកស្រាវជ្រាវបានកំណត់យកវិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យគឺ (១).ចំពោះនាយកអ្នកស្រាវជ្រាវប្រើកម្រងសំណួរទម្រង់បើកដើម្បីសម្ភាសន៍ស្វែងរកព័ត៌មានបែបគុណភាព និងមានភាពជាក់លាក់ (២).ចំពោះគ្រូ និងសិស្សអ្នកស្រាវជ្រាវបង្កើតកម្រងសំណួរទម្រង់បិទ និងបំពេញចម្លើយដោយគូសធីក ។ ការចុះប្រមូលទិន្នន័យអ្នកស្រាវជ្រាវធ្វើនៅបឋមសិក្សាក្នុងខេត្តស្វាយរៀង អ្នកស្រាវជ្រាវបែងចែកជាពីរផ្នែកគឺ៖ ទីប្រជុំជន និងទីជនបទ ហើយក្រុមគោលដៅសាលាសំណាកគឺសម្រាប់ ១ ក្រុង/ស្រុក ជ្រើសយកទីប្រជុំជន ១ សាលា និង សាលាទីជនបទ ១ សាលា ។ ដោយហេតុថាខេត្តស្វាយរៀងមាន ៨ ក្រុង/ស្រុក ដូចនេះការជ្រើសសាលាសំណាកទីប្រជុំជនសរុបចំនួន ៨ សាលា និងទីជនបទសរុបចំនួន ៨ សាលា ។ ការចុះប្រមូលទិន្នន័យអ្នកស្រាវជ្រាវបានធ្វើការសម្ភាសន៍ជាមួយគណៈគ្រប់គ្រងចំនួន ១៨ នាក់ ហើយការបំពេញកម្រងសំណួរដោយគ្រូនិងសិស្ស អ្នកស្រាវជ្រាវជ្រើសចំនួនសមាមាត្រតាមទ្រឹស្តីរបស់លោក Carrol Yamane ដែលមានកម្រិតលំអៀង 0.0៥ ។ សំណាកដែលបានជ្រើសនៅទីប្រជុំជនមានគ្រូចំនួន ៩៥ នាក់ សិស្សចំនួន ២៦៤ នាក់ និងទីជនបទមានគ្រូចំនួន ៤៧ នាក់ សិស្សចំនួន ១១២ នាក់ចូលរួមបំពេញកម្រងសំណួរគ្រប់ចំនួនតាមការគ្រោងទុក ។

## ៣.២ ការប្រមូលទិន្នន័យ

ក្រោយពីបានទទួលលិខិតអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា យោងតាមលិខិតលេខ ៤០៨២ អយក. វដអ ចុះថ្ងៃចន្ទ ៨រោច ខែបឋមសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតបរិញ្ញាបត្រជាន់ខ្ពស់ឯកទេសគ្រប់គ្រងអប់រំជំនាន់១០ ។ អ្នកស្រាវជ្រាវបានបោះពុម្ពលិខិតនេះ ១ច្បាប់ និងលិខិតប្រធានបទនិក្ខេបបទស្រាវជ្រាវដាក់ជូនការិយាល័យរដ្ឋបាលនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង បន្ទាប់មកប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀងបានចេញលិខិតបង្ហាញរឿងមួយច្បាប់ ចុះថ្ងៃចន្ទ១៤កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧។ បន្ទាប់ពីបង្កើតកម្រងសំណួររួចរាល់ដោយមានការពិនិត្យឯកភាពពីគ្រូដឹកនាំគោល និងគ្រូដឹកនាំរងរួច អ្នកស្រាវជ្រាវបានផលិតកម្រងសំណួរបឋមជា Hard copy ដើម្បីចុះប្រមូលទិន្នន័យសាកល្បងនៅសាលារៀនមួយ ដោយចាប់ផ្តើមដំបូងពេលព្រឹកជួបសម្ភាសន៍ជាមួយនាយក ០១ នាក់ ដើម្បីយកព័ត៌មានជាក់លាក់មួយ រួចមកពិនិត្យកែសម្រួលឃ្លាឃ្លោងអត្ថន័យក្នុងការសម្ភាសន៍ឱ្យបន្សុីនឹងការលើកដាក់សម្លេងក្នុងពេលសម្ភាសន៍ ព្រមទាំងស្វែងយល់ពីភាពពិតជាក់លាក់ក្នុងការប្រមូលទិន្នន័យនេះ បន្ទាប់មកអ្នកស្រាវជ្រាវចុះទៅសាលារៀនដដែលនាពេលរសៀលដោយជួបគ្រូ និងសិស្សជាក្រុមៗ ហើយបានពន្យល់ណែនាំពីរបៀបបំពេញកម្រងសំណួរនេះ រួចឱ្យគាត់ទៅបំពេញកម្រងសំណួរនៅកន្លែងរៀងខ្លួនវិញ ដោយមិនអនុញ្ញាតិឱ្យពិភាក្សាគ្នាឡើយ ។

## ៣.៣. ឧបករណ៍ស្រាវជ្រាវ

ដើម្បីប្រមូលទិន្នន័យបានជាក់លាក់ អ្នកសិក្សាស្រាវជ្រាវបានបង្កើតកម្រងសំណួរស្រាវជ្រាវចំនួន ៣ប្រភេទ ដើម្បីឆ្លើយតបនឹងវត្ថុបំណងនៃការស្រាវជ្រាវរួមមាន៖ ទី១ កម្រងសំណួរបំពេញដោយសិស្ស ទី២ កម្រងសំណួរដោយគ្រូបង្រៀន ទី៣ ទម្រង់សំណួរសម្ភាសន៍នាយកសាលា ។ កម្រងសំណួនីមួយៗ៖ អ្នកស្រាវជ្រាវបានរៀបចំជា២ផ្នែក៖ **ផ្នែកទី១** អំពីព័ត៌មានផ្ទាល់ខ្លួន **ផ្នែកទី២** ព័ត៌មានស្តីពីការអនុវត្តសុខភាពសិក្សាជាតារាងដែលមានសំណួរទៅតាមស្តង់ដានីមួយៗដូចជា៖ **ស្តង់ដាទី១** ការអភិវឌ្ឍក្របខណ្ឌ

ច្បាប់ និងយន្តការ **ស្តង់ដាទី២** ការលើកកម្ពស់សុខភាពចាំបាច់ដល់គ្រូបង្រៀន និងសិស្ស **ស្តង់ដាទី៣** ការលើកកម្ពស់ការផ្តល់អាហារូបត្ថម្ភ **ស្តង់ដាទី៤** ការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ **ស្តង់ដាទី៥** ការលើកកម្ពស់បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាបន្ន ផាសុខភាព និងមេត្រីភាព **ស្តង់ដាទី៦** ការលើកកម្ពស់សន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងសាលា **ស្តង់ដាទី៧** ការលើកកម្ពស់ការអប់រំសុខភាព **ស្តង់ដាទី៨** ការលើកកម្ពស់ការអនុវត្តបំណិនសុខភាព **ស្តង់ដាទី៩** ការលើកកម្ពស់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងអភិវឌ្ឍកម្មវិធីសុខភាពសិក្សា។

## ៣.៤. ការជ្រើសរើសគំរូតាង

ក្នុងឆ្នាំសិក្សា ២០២២-២០២៣នេះ សាលារៀនកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀងមានចំនួនសរុប ២៦២ សាលា មានគ្រូសរុបចំនួន២,១៣៩ នាក់ សិស្សសរុបចំនួន ៧៥,៣៤៧ នាក់ ។ អ្នកស្រាវជ្រាវសម្រេចជ្រើសសាលាសំណាកដោយបែងចែកជាពីរក្រុមគឺ៖ (១)សាលានៅទីប្រជុំជន (២) សាលានៅទីជនបទ អ្នកស្រាវជ្រាវប្រើទិន្នន័យឆ្នាំសិក្សា២០២២-២០២៣ គឺជាទិន្នន័យដែលបានមកពីការិយាល័យផែនការនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង ។ ទិន្នន័យសាលាសំណាកទីជនបទក្រុងស្វាយរៀង និងក្រុងបាវិតអ្នកស្រាវជ្រាវប្រើក្នុងទម្រង់ Microsoft Excel យកមក Random ដោយប្រើរូបមន្ត =Rand( ) យកតម្លៃពិន្ទុណាដែលខ្ពស់ជាងគេនោះជាសាលាសំណាកដែលបានចាប់យក។ ចំណែកទិន្នន័យសាលាសំណាកនៅទីប្រជុំជន១សាលាក្នុងទីរួមស្រុកនីមួយៗ អ្នកស្រាវជ្រាវជ្រើសដោយស្វ័យប្រវត្តិ សរុបមកទិន្នន័យសាលាសំណាកនៅទីប្រជុំជនមានចំនួន៨សាលា និងទីជនបទមានចំនួន៨សាលា ។

ការចុះប្រមូលទិន្នន័យអ្នកស្រាវជ្រាវបានធ្វើការសម្ភាសន៍ជាមួយគណៈគ្រប់គ្រងចំនួន១៨នាក់ ឯសំណាកគ្រូ និងសិស្ស អ្នកស្រាវជ្រាវជ្រើសចំនួនសមាមាត្រតាមទ្រឹស្តីរបស់លោក Carrol Yamane ដែលមានកម្រិតលំអៀង ០.០៥(មើលតារាង១) ។ ទីប្រជុំជន សំណាកបានជ្រើសរើស៖ មានគ្រូចំនួន ៩៥ នាក់ សិស្សចំនួន២៦៤នាក់ ឯទីជនបទមាន៖ គ្រូចំនួន៤៧នាក់ សិស្សចំនួន១១២នាក់ ចូលរួមធ្វើការបំពេញកម្រងសំណួរ ។ ចំពោះសំណាកសិស្ស អ្នកស្រាវជ្រាវបានជ្រើសក្នុងចំណោមសិស្សថ្នាក់ទី

៤ ទី៥ និងទី៦ ដោយវិធីចាប់យកដោយចៃដន្យដើម្បីកុំឱ្យមានភាពលម្អៀង។ អ្នកស្រាវជ្រាវមិនបានសិក្សាពីភេទ អាយុ ដាក់បញ្ចូលក្នុងកិច្ចស្រាវជ្រាវនេះទេ ព្រោះវាមិនបានជះឥទ្ធិពលដល់ការស្រាវជ្រាវឡើយ តែអ្នកសិក្សាស្រាវជ្រាវបានជ្រើសយកសំណាកសិស្សផ្នែកបឋមសិក្សាកម្រិតខ្ពស់មកបំពេញកម្រងសំណួរ ព្រោះពួកគេអាចមានសមត្ថភាពអាន និងអាចបំពេញកម្រងសំណួរបានល្អជាងសិស្សនៅបឋមសិក្សាកម្រិតទាប ហើយសិស្សសំណាកទាំងអស់ចូលរួមបំពេញកម្រងសំណួរគ្រប់ចំនួនតាមការគ្រោងទុក ។

**តារាង១៖ ទិន្នន័យភាគសំណាក**

| ទី | ចំនួនបុគ្គលិកអប់រំទាំងអស់ | | | ចំនួនសំណាកដែលបានជ្រើសរើស | | |
|---|---|---|---|---|---|---|
| | នាយក/នាយិកា | គ្រូ | សិស្ស | នាយក/នាយិកា | គ្រូ | សិស្ស |
| ប្រជុំជន | 8 | 147 | 4356 | 8 | 95 | 264 |
| ជនបទ | 8 | 172 | 1857 | 8 | 47 | 112 |
| **សរុប** | **16** | **219** | **6213** | **16** | **142** | **376** |

## ៣.៥. ការវិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រវិភាគទិន្នន័យតាមបែបបរិមាណវិស័យ ទិន្នន័យបែបបរិមាណវិស័យដែលប្រមូលពីនាយក គ្រូ សិស្ស និងទៅតាមប្រភេទតំបន់នៃភាគសំណាកនីមួយៗ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវសំយោគបញ្ចូលគ្នាដោយផ្តោតសំខាន់ទៅលើស្តង់ដាបានការ។ ដើម្បីឆ្លើយតបនឹងចំណុចនេះ អ្នកសិក្សាស្រាវជ្រាវប្រើកម្មវិធី Microsoft Excel សង់តារាង រួចគណនារកប្រេកង់ (Frequency) ហើយវិភាគលទ្ធផលនៃការស្រាវជ្រាវក្នុងគោលបំណងដើម្បីទាញបាននូវអនុសាសន៍ពីលទ្ធផលនៃការស្រាវជ្រាវ និងការសន្និដ្ឋាននៃការសិក្សាស្រាវជ្រាវនេះ។

តារាង២៖ ការកំណត់កម្រិតអនុវត្ត Scale

| ល.រ | ចំនួនឆ្លើយបាន (%) | វាយតម្លៃការអនុវត្ត |
|---|---|---|
| ១ | ចន្លោះពី 95.00 ដល់ 100 | ល្អណាស់ |
| ២ | ចន្លោះពី 80.00 ដល់ 94.00 | ល្អ |
| ៣ | ចន្លោះពី 64.00 ដល់ 79.00 | បង្គួរ |
| ៤ | ចន្លោះពី 50.00 ដល់ 64.00 | មធ្យម |
| ៥ | ចន្លោះពី 0.00 ដល់ 49.00 | ទាប |

## ៣.៦. ក្រមសីលធម៌នៃអ្នកស្រាវជ្រាវ

ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវ ការប្រកាន់ខ្ជាប់នូវក្រមសីលធម៌ដើម្បីជានាប្រសិទ្ធភាពនៃការស្រាវជ្រាវក៏ដូចជាការបង្កើននូវប្រសិទ្ធភាពនៃការអនុវត្តភារកិច្ចរបស់គណៈគ្រប់គ្រងសាលា លោកគ្រូអ្នកគ្រូផងដែរ ការដែលព្រមព្រាងគ្នារវាងអ្នកដែលផ្តល់ចម្លើយ និងអ្នកដែលស្វែងរកព័ត៌មានច្បាស់លាស់ អាចយកមកប្រើការបានសម្រាប់ធ្វើការវិភាគឱ្យស៊ីជម្រៅ។ អត្តសញ្ញាណរបស់អ្នកផ្តល់ចម្លើយត្រូវបានរក្សាទុកជាការសំងាត់។ អ្នកស្រាវជ្រាវបាននាំយកនូវលិខិតសុំការអនុញ្ញាតទៅជាមួយ ហើយសុំការអនុញ្ញាតពីភាគីពាក់ព័ន្ធ ដោយចាប់ផ្តើមមុនពេលពួកគេបំពេញកម្រងសំណួរ និងផ្តល់បទសម្ភាសន៍។ ការធ្វើបែបនេះមានន័យថា អ្នកផ្តល់ចម្លើយយល់ពីគោលបំណងនៃការស្រាវជ្រាវជាមុន ហើយអ្នកសិក្សាស្រាវជ្រាវក៏រំពឹងថានឹងទទួលបានចម្លើយ ឬព័ត៌មានពិតប្រាកដ។ ការធ្វើដូចនេះធ្វើឱ្យអ្នកស្រាវជ្រាវមានទំនុកចិត្ត និងមានភស្តុតាងពិតបញ្ជាក់អំពីការចុះទៅប្រមូលទិន្នន័យរបស់ខ្លួនដោយស្របច្បាប់។

# ជំពូក៤

# លទ្ធផលស្រាវជ្រាវ និង

# ការពិភាក្សា

# ជំពូក៤៖
# លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

នៅក្នុងជំពូកនេះអ្នកស្រាវជ្រាវនឹងធ្វើការបកស្រាយបង្ហាញ និងការវិភាគទិន្នន័យដែលបានមកពីលទ្ធផលនៃការសម្ភាសន៍ និងការបំពេញកម្រងសំណួរ ព្រមទាំងទិន្នន័យដែលបានមកពីការពិនិត្យរកមើលឱ្យឃើញភស្តុតាងដើម្បីឱ្យអ្នកស្រាវជ្រាវដឹងពីស្ថានភាពនៃអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សានៅតាមសាលាដែលបានជ្រើសរើសយកសំណាក និងជាតំណាងឱ្យសាលាបឋមសិក្សាទាំងអស់ក្នុងខេត្តស្វាយរៀង។

## ៤.១.ទិន្នន័យទូទៅមុនប្រមូលទិន្នន័យ

### ៤.១.១.ព័ត៌មានទូទៅរបស់សាលាសំណាក

ក្នុងឆ្នាំសិក្សា ២០២២-២០២៣ នេះសាលារៀនកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀងមានចំនួនសរុប ២៦២ សាលា មានគ្រូសរុបចំនួន២,១៣៩ នាក់ សិស្សសរុបចំនួន៧៥,៣៤៧ នាក់ ។ ក្នុងការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវសម្រេចជ្រើសរើសសាលាសំណាកដោយបែងចែកជាពីរក្រុមគឺ៖ (១) សាលានៅទីប្រជុំជន (២)សាលានៅទីជនបទ ដោយហេតុថាពេលវេលាមានកំណត់ អ្នកសិក្សាស្រាវជ្រាវបានសម្រេចជ្រើសរើសយកសំណាកទីប្រជុំជន ១សាលា និងសាលាទីជនបទ ១សាលា ។ ក្នុងខេត្តស្វាយរៀងមាន ៨ស្រុក/ក្រុង ដូចនេះសរុបសាលាសំណាកក្នុងទីប្រជុំជនមានចំនួន ៨សាលា និងទីជនបទមានចំនួន ៨សាលា ។ អ្នកស្រាវជ្រាវបានប្រើទិន្នន័យឆ្នាំសិក្សា២០២២-២០២៣ គឺជាទិន្នន័យដែលបានមកពីការិយាល័យផែនការនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង ក្នុងទម្រង់ Microsoft Excel រួចយកមក Random ដោយប្រើរូបមន្ត=Rand( )យកតម្លៃពិន្ទុណាដែលខ្ពស់ជាងគេនោះជាសាលាសំណាកដែលបានចាប់យក ដំណើរការជ្រើសរើសសំណាកដំបូងអ្នកស្រាវជ្រាវជ្រើសរើសសាលានៅទីប្រជុំជន១សាលាក្នុងទីរួមស្រុកនីមួយៗដោយស្វ័យប្រវត្តិ លើកលែងតែក្រុងស្វាយរៀងមានសាលាទីប្រជុំជនចំនួន១៤សាលា និងក្រុងបាវិតមានចំនួន៣សាលា អ្នកស្រាវជ្រាវប្រើវិធី Random ដើម្បីចាប់យកសាលាសំណាក ដូចគ្នានឹងសាលានៅទីជនបទដែរ ។

## ៤.១.២.ព័ត៌មានទូទៅពីអ្នកចូលរួមផ្តល់ទិន្នន័យសម្ភាសន៍ និងបំពេញកម្រងសំណួរ

តាមតារាង៣ ទិន្នន័យ នាយក-គ្រូ-សិស្ស ការចុះប្រមូលទិន្នន័យអ្នកស្រាវជ្រាវបានធ្វើការសម្ភាសន៍ជាមួយគណៈគ្រប់គ្រងចំនួន ១៨ នាក់ ហើយការបំពេញកម្រងសំណួរដោយគ្រូ និងសិស្ស អ្នកស្រាវជ្រាវជ្រើសសំណាកតាមសមាមាត្រនៃទ្រឹស្តីលោក Carrol Yamane ដែលមានកម្រិតលំអៀង 0.0៥ ក្រោយពីបានធ្វើការគណនារួច ទិន្នន័យដែលត្រូវបានជ្រើសរើសគឺនៅទីប្រជុំជនមានគ្រូចំនួន ៩៥ នាក់ និងសិស្សចំនួន ២៦៤ នាក់ ឯគ្រូនៅទីជនបទចំនួន ៤៧ នាក់ និងសិស្សចំនួន ១១២ នាក់ សរុបនៅទីប្រជុំជន និងទីជនបទមានគ្រូចំនួន ១៤២ ស្មើនឹង ៦៥% និងសិស្សសរុបចំនួន ៣៧២ នាក់ ស្មើនឹង ៦.0៦% នៃទិន្នន័យគ្រូ សិស្សសរុបរបស់សាលាសំណាកដែលបានជ្រើសរើស ។

**តារាង៣ ទិន្នន័យ នាយក-គ្រូ-សិស្ស**

| សាលា | ចំនួន នាយក | ចំនួនគ្រូ សរុប | ចំនួនសិស្ស សរុប | សំណាក គ្រូ | សំណាក សិស្ស |
|---|---|---|---|---|---|
| ក្រុងស្វាយរៀង | | | | | |
| ប្រជុំជន | 1 | 12 | 240 | 8 | 15 |
| ប្រជុំជន | 1 | 6 | 152 | 4 | 9 |
| ក្រុងបាវិត | | | | | |
| ប្រជុំជន | 1 | 17 | 440 | 11 | 27 |
| ជនបទ | 1 | 4 | 221 | 3 | 13 |
| ស្រុករមាសហែក | | | | | |
| ប្រជុំជន | 1 | 22 | 683 | 14 | 41 |
| ជនបទ | 1 | 14 | 331 | 9 | 20 |
| ស្រុកស្វាយជ្រំ | | | | | |
| ប្រជុំជន | 1 | 26 | 998 | 17 | 60 |
| ជនបទ | 1 | 9 | 235 | 6 | 14 |
| ស្រុករំដួល | | | | | |
| ប្រជុំជន | 1 | 20 | 558 | 13 | 34 |
| ជនបទ | 1 | 14 | 368 | 9 | 22 |
| ស្រុកកំពង់រោទិ៍ | | | | | |
| ប្រជុំជន | 1 | 20 | 518 | 13 | 31 |

| | | | | | |
|---|---|---|---|---|---|
| ជនបទ | 1 | 6 | 87 | 4 | 5 |
| ស្រុកស្វាយទាប | | | | | |
| ប្រជុំជន | 1 | 12 | 376 | 8 | 23 |
| ជនបទ | 1 | 9 | 215 | 6 | 13 |
| ស្រុកចន្ទ្រា | | | | | |
| ប្រជុំជន | 1 | 18 | 543 | 12 | 33 |
| ជនបទ | 1 | 10 | 248 | 6 | 15 |
| **សរុប** | **16** | **219** | **6213** | **142** | **376** |

## ៤.២ ឧបករណ៍ប្រមូលទិន្នន័យ

### ៤.២.១ កម្រងសំណួរ

កម្រងសំណួរជាទម្រង់សំខាន់មួយសម្រាប់ប្រមូលព័ត៌មានដែលបានបម្រើឱ្យការវិភាគនៅក្នុងដំណើរការលទ្ធផលស្រាវជ្រាវទាំងមូល ។ ជាតម្រូវការអ្នកស្រាវជ្រាវប្រើប្រាស់កម្រងសំណួរបីប្រភេទគឺៈ កម្រងសំណួរសម្ភាសន៍នាយក កម្រងសំណួរបំពេញដោយគ្រូ និងកម្រងសំណួរបំពេញដោយសិស្ស កម្រងសំណួរទាំងអស់នេះផ្អែកលើសូចនាករស្តង់ដា ស្តីការលើកកម្ពស់សុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សាចំណោះទូទៅ។ ស្តង់ដាទាំងអស់៩ និងសូចនាករ២៦ត្រូវបានប្រើដើម្បីប្រមូលទិន្នន័យពីភាគីទាំងបី ហើយរវាងសំណួរដែលសម្ភាសន៍គណៈគ្រប់គ្រង គ្រូ និងសិស្ស មានចំនួនសំណួរស្មើគ្នា ។

### ៤.២.២ កម្រងសំណួរសម្ភាសន៍នាយក

ដោយផ្អែកលើវិធីសាស្រ្តស្រាវជ្រាវបែបបរិមាណវិស័យ អ្នកស្រាវជ្រាវប្រើកម្រងសំណួរបែបទម្រង់បិទ ហើយការសួររកចម្លើយគឺ "មាន" និង "មិនមាន"។ អ្នកស្រាវជ្រាវក៏ត្រូវស្នើសុំកិច្ចសហការជាមួយនាយកដោយផ្តល់ឯកសារពាក់ព័ន្ធ និងការពិនិត្យ សង្កេតមើលដើម្បីប្រមូលភស្តុតាងឱ្យបានសព្វជ្រុងជ្រោយមុននឹងសម្រេចចិត្តដាក់ពិន្ទុក្នុងកម្រិតណាមួយស្តីពីស្ថានភាពការអនុវត្តសុខភាពសិក្សាពេលចុះទៅស្រាវជ្រាវនេះ ។

### ៤.២.៣ កម្រងសំណួរបំពេញដោយគ្រូ និងសិស្ស

ចំពោះកម្រងសំណួរបំពេញដោយគ្រូ និងសិស្ស អ្នកស្រាវជ្រាវបានកំណត់យកកម្រងសំណួរប្រភេទទម្រង់បិទ ហើយការស្រាវជ្រាវបែបបរិមាណវិស័យ ដែលមានចម្លើយ "បាទ/ចាស" "ទេ" "មិនដឹង"។

## ៤.៣ លទ្ធផលនៃការអនុវត្តតាមស្តង់ដា

### ៤.៣.១ ការអនុវត្តស្តង់ដាទី១៖ ការអភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ

តាមរយៈការស្រាវជ្រាវស្តង់ដាទី១បង្ហាញថា ការអនុវត្តអភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការនៃគោលការប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សា ជារួមអ្នកចូលរួមផ្តល់ចម្លើយ បានឆ្លើយពីនៅទីប្រជុំជនអនុវត្តបានកម្រិតមធ្យមប្រមាណជា៥៦.០៥% និងនៅទីជនបទ៤៩.២៩% ពោលគឺមិនទាន់អនុវត្តបានល្អនៅឡើយទេ ។

តារាង៤៖ ការអភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ (%នៃការអនុវត្ត)

| កូដសំណួរ | %អ្នកផ្តល់ចម្លើយនៅសាលាទីប្រជុំជន | | | | | | %អ្នកផ្តល់ចម្លើយនៅសាលាទីជនបទ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | នាយក | | គ្រូបង្រៀន | | សិស្ស | | នាយក | | គ្រូបង្រៀន | | សិស្ស | |
| | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ |
| Q1.1 | 100 | 0.00 | 97.00 | 3.00 | 92.80 | 6.06 | 100 | 0.00 | 100 | 0.00 | 93.75 | 5.36 |
| Q1.2 | 12.50 | 87.50 | 15.00 | 85.00 | 19.00 | 81.00 | 0.00 | 100 | 0.00 | 100 | 2.00 | 98.00 |
| សរុប | 56.25 | 43.75 | 56.00 | 44.00 | 55.90 | 43.53 | 50.00 | 50.00 | 50.00 | 50.00 | 47.88 | 51.68 |

សម្គាល់៖ *%បាទ/ចាស + %ទេ + %មិនដឹង=១០០%

* *Q1.1: សាលាបានបង្កើតគណៈកម្មការសុខភាពសិក្សា

Q1.2: ក្រមប្រតិបត្តិស្តីពីសុខភាពសិក្សាបានបង្កើត ដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយ

ប៉ុន្តែបើតាមរយៈលទ្ធផលនៃការស្រាវជ្រាវក្នុងតារាង៤ ដែលលម្អិតលើសូចនាករទី១បង្ហាញថាទីប្រជុំជន នាយកឆ្លើយ១០០% គ្រូ៩៧.00% សិស្ស៩២.៨0% និងទីជនបទនាយកឆ្លើយ១០០% គ្រូ១០០% សិស្ស៩៣.៧៥.00% បានឆ្លើយថាសាលាបានបង្កើតគណៈកម្មការសុខភាពសិក្សា ។ ចំណែកសូចនាករទី២៖ ការអនុវត្តក្រមប្រតិបត្តិស្តីពីសុខភាពសិក្សាបានបង្កើត ដាក់ឱ្យអនុវត្ត និង

ផ្សព្វផ្សាយគឺ ស្មើគ្រប់សាលាអនុវត្តក្នុងកម្រិតទាប តាមការស្រាវជ្រាវបង្ហាញឱ្យឃើញថាទីប្រជុំជន នាយកឆ្លើយ១២.៥០% គ្រូ១៥.០០% សិស្ស១៩.០០% ទីជនបទនាយកឆ្លើយ០.០០% គ្រូ០.០០% និងសិស្ស២.០០% ថាបានបង្កើត ដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយ ហើយចំណុចដែលធ្វើឱ្យស្តង់ដាទី១ អនុវត្តមិនទាន់បានល្អទាំងនៅទីប្រជុំជន និងទីជនបទនោះគឺមកពីសូចនាករទី២ដែលធ្វើឱ្យស្តង់ដាទី១ នេះអនុវត្តបានក្នុងកម្រិតមិនទាន់ឆ្លើយតបនិងគោលការណ៍ប្រតិបត្តិស្តង់ដាសុខភាពសិក្សានៅឡើយទេ។




តាមរយៈការបង្ហាញលើក្រាបសរសេរក្នុងស្តង់ដាទី១ ការអភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការរវាង ទីប្រជុំជន និងទីជនបទ ការអនុវត្តនេះបានក្នុងកម្រិតមធ្យមដូចគ្នា តែការអនុវត្តនៅទីប្រជុំជនខ្ពស់ជាង នៅទីជនបទ៦.៦៧% ប្រការដែលស្តង់ដាទី១អនុវត្តមិនបានល្អនោះដោយសារការអនុវត្តសូចនាករទី ២មានបានទាប។

## ៤.៣.២ ការអនុវត្តស្តង់ដាទី២៖ ការលើកកម្ពស់សុខភាពចាំបាច់ដល់គ្រូបង្រៀននិងសិស្ស

តាមរយៈការស្រាវជ្រាវស្តង់ដាទី២បង្ហាញថា ការលើកកម្ពស់សុខភាពចាំបាច់ដល់គ្រូបង្រៀន និងសិស្សគឺទាំងសាលាទីប្រជុំជន និងទីជនបទអនុវត្តបានកម្រិតទាប តាមការស្រាវជ្រាវជារួមបង្ហាញ នៅទីប្រជុំជនអនុវត្តបាន៣៦.៩១% និងទីជនបទអនុវត្តបាន៣០.៩៩% ។

តារាង៥ ការលើកកម្ពស់សុខភាពចាំបាច់ដល់គ្រូបង្រៀននិងសិស្ស(%នៃការអនុវត្ត)

| កូដសំណួរ | %អ្នកផ្តល់ចម្លើយនៅសាលាទីប្រជុំជន | | | | | | %អ្នកផ្តល់ចម្លើយនៅសាលាទីជនបទ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | នាយក | | គ្រូបង្រៀន | | សិស្ស | | នាយក | | គ្រូបង្រៀន | | សិស្ស | |
| | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ |
| Q2.1 | 12.50 | 87.50 | 17.00 | 78.00 | 20.00 | 80.00 | 0.00 | 100 | 0.00 | 100 | 0.00 | 100 |
| Q2.2 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 |
| Q2.3 | 97.00 | 0.00 | 93.68 | 4.21 | 92.05 | 6.44 | 94.00 | 0.00 | 91.00 | 9.00 | 89.00 | 19.00 |
| សរុប | 36.50 | 29.17 | 36.89 | 27.40 | 37.35 | 28.81 | 31.33 | 33.33 | 30.33 | 36.33 | 29.67 | 39.67 |

សម្គាល់៖ *%បាទ/ចាស + %ទេ + %មិនដឹង=១០០%

Q2.1 : សាលាមានបង្កើតបន្ទប់សុខភាពសិក្សា

Q2.2 : សិស្សទទួលបានសេវាពិនិត្យសុខភាព និងកាយសម្បទាតាមកាលវិភាគប្រចាំឆ្នាំ ច្បាស់លាស់ពីមន្ត្រីសុខាភិបាល

Q2.3 : សិស្សទទួលបានថ្នាំបង្ការជំងឺផ្សេងៗតាមកម្មវិធីជាតិនៃការផ្តល់ថ្នាំបង្ការរបស់ក្រសួងសុខាភិបាល

តាមរយៈតារាង៥ដែលលម្អិតលើសូចនាករនីមួយៗ ក្នុងសូចនាករទី៣បង្ហាញថា៖ នៅទីប្រជុំជន នាយកឆ្លើយ១២.៥០% គ្រូបង្រៀន ១៧.០០% និងសិស្ស២០.០០% បានបង្កើតបន្ទប់សុខភាពសិក្សា។ ចំណែកទីជនបទនាយក គ្រូ និងសិស្ស ឆ្លើយដូចគ្នា០.០០% គឺបានបង្កើតបន្ទប់សុខភាព ។ សូចនាករទី៤៖ ទាំងតំបន់ប្រជុំជន និងជនបទ រវាងនាយក គ្រូ និងសិស្សឆ្លើយដូចគ្នា០.០០% គឺសិស្ស ទទួលបានសេវាពិនិត្យសុខភាព និងកាយសម្បទាតាមកាលវិភាគប្រចាំឆ្នាំច្បាស់លាស់ពីមន្ត្រីសុខាភិបាល ។ សូចនាករទី៥៖ នៅទីប្រជុំជន នាយកឆ្លើយ៩៧.០០% គ្រូ៩៣.៦៨% សិស្ស៩២.០៥% រីឯទីជនបទ នាយក៩៤.០០% គ្រូ៩១.០០% សិស្ស៨៩.០០% គឺទទួលបានថ្នាំបង្ការជំងឺផ្សេងៗតាមកម្មវិធីជាតិនៃ ការផ្តល់ថ្នាំបង្ការរបស់ក្រសួងសុខាភិបាល ។




តាមរយៈការបង្ហាញលើក្រាបសរសេរស្តង់ដាទី២ ការលើកកម្ពស់សុខភាពចាំបាច់ដល់គ្រូបង្រៀន និងសិស្ស រវាងទីប្រជុំជន និងទីជនបទ បានអនុវត្តក្នុងកម្រិតទាបដូចគ្នា តែការអនុវត្តនៅទីប្រជុំជនខ្ពស់ជាងនៅទីជនបទ៦.៤៧% ប្រការដែលធ្វើឱ្យស្តង់ដាទី២អនុវត្តមិនបានល្អនោះដោយសារសូចនាករទី៣ និងទី៤អនុវត្តបានទាប។

### ៤.៣.៣ ការអនុវត្តស្តង់ដាទី៣៖ ការលើកកម្ពស់ការផ្តល់អាហារូបត្ថម្ភ

តាមរយៈការស្រាវជ្រាវស្តង់ដាទី៣បង្ហាញថា ការលើកកម្ពស់ការផ្តល់អាហារូបត្ថម្ភ ជារួមការអនុវត្តបានក្នុងកម្រិតទាប ពោលគឺទីប្រជុំជនអនុវត្តបានត្រឹម៤៧.៩៤% និងជនបទត្រឹម៤២.៣៣% ។

តារាង៦ ការលើកកម្ពស់ការផ្តល់អាហារូបត្ថម្ភ(%នៃការអនុវត្ត)

| កូដសំណួរ | %អ្នកផ្តល់ចម្លើយនៅសាលាទីប្រជុំជន | | | | | | %អ្នកផ្តល់ចម្លើយនៅសាលាទីជនបទ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | នាយក | | គ្រូបង្រៀន | | សិស្ស | | នាយក | | គ្រូបង្រៀន | | សិស្ស | |
| | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ |
| Q3.1 | 100 | 0.00 | 100 | 0.00 | 100 | 0.00 | 100 | 0.00 | 100 | 0.00 | 95.00 | 0.00 |
| Q3.2 | 12.50 | 87.50 | 18.00 | 82.00 | 20.00 | 80.00 | 0.00 | 100.00 | 0.00 | 100.00 | 10.00 | 90.00 |
| Q3.3 | 25.00 | 75.00 | 27.00 | 73.00 | 29.00 | 71.00 | 25.00 | 75.00 | 23.00 | 77.00 | 28.00 | 72.00 |

| សរុប | 45.83 | 54.17 | 48.33 | 51.67 | 49.67 | 50.33 | 41.67 | 58.33 | 41.00 | 59.00 | 44.33 | 54.00 |
|---|---|---|---|---|---|---|---|---|---|---|---|---|

សម្គាល់៖ *%បាទ/ចាស + %ទេ + %មិនដឹង=១០០%

Q3.1 : សាលាមានបណ្ដាញទឹកស្អាតសម្រាប់ទទួលទានដូចជាបណ្ដាញទឹកស្អាត ធុងចម្រោះ ឬប្រព័ន្ធបន្សុទ្ធទឹកស្អាត

Q3.2 : សាលាបានរៀបចំអាហារដ្ឋាន កន្លែងផ្ដល់អាហារឬ កន្លែងលក់ដូរចំណីអាហារ ប្រកបដោយសុវត្ថិភាព និងសុខភាព

Q3.3 : សួនបន្លែនិងសួនជីវៈចម្រុះដើម្បីជំរុញការយល់ដឹងពីអាហារូបត្ថម្ភដែលមានលក្ខណៈចម្រុះ

ប៉ុន្តែបើលម្អិតលើសូចនាករនីមួយៗ តាមការស្រាវជ្រាវលើលទ្ធផលក្នុងតារាង៦ សូចនាករទី៦ ទាំងទីប្រជុំជន និងទីជនបទ បង្ហាញថានាយកឆ្លើយ១០០% គ្រូ១០០% សិស្ស១០០% ខណៈសិស្សទីជនបទ៩៥.០០% គឺសាលាមានបណ្ដាញទឹកស្អាតសម្រាប់ទទួលទានដូចជាបណ្ដាញទឹកស្អាត ធុងចម្រោះ ។ សូចនាករទី៧ នាយកទីប្រជុំជនឆ្លើយ១២.៥០ គ្រូ១៨.០០% សិស្ស២០.០០% រីឯទីជនបទទាំងនាយក គ្រូ សិស្សបានឆ្លើយ0.00% សាលាបានរៀបចំអាហារដ្ឋាន កន្លែងផ្ដល់អាហារឬ កន្លែងលក់ដូរចំណីអាហារ ប្រកបដោយសុវត្ថិភាព និងសុខភាព ។ សូចនាករទី៨ នាយកទីប្រជុំជនឆ្លើយ២៥.០០% គ្រូ ២៧.០០% សិស្ស២៩.០០% រីឯទីជនបទនាយកឆ្លើយ២៥% គ្រូ២៣% សិស្ស២៨% សាលាមានសួនបន្លែនិងសួនជីវៈចម្រុះដើម្បីជំរុញការយល់ដឹងពីអាហារូបត្ថម្ភដែលមានលក្ខណៈចម្រុះ ។




តាមការបង្ហាញលើក្រាបសរសេរស្តង់ដាទី៣ ការលើកកម្ពស់ការផ្តល់អាហារូបត្ថម្ភ រវាងទីប្រជុំជន និងទីជនបទ បានអនុវត្តក្នុងកម្រិតទាបដូចគ្នា តែការអនុវត្តនៅទីប្រជុំជនខ្ពស់ជាងនៅទីជនបទ ៥.៦០% ប្រការដែលធ្វើឱ្យស្តង់ដាទី៣អនុវត្តមិនបានល្អនោះដោយសារសូចនាករទី៨ និងទី៩អនុវត្តបានទាប។

### ៤.៣.៤ ការអនុវត្តស្តង់ដាទី៤៖ ការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

តាមរយៈការស្រាវជ្រាវស្តង់ដាទី៤បង្ហាញថាការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជារួមទីប្រជុំជនអនុវត្តបាន៧៥.១៧% ក្នុងកម្រិតបង្គួរ និងទីជនបទ៧៦.៥៨% ក្នុងកម្រិតបង្គួរដែរ ។

តារាង៧ ការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ(%នៃការអនុវត្ត)

| កូដសំណួរ | %អ្នកផ្តល់ចម្លើយនៅសាលាទីប្រជុំជន | | | | | | %អ្នកផ្តល់ចម្លើយនៅសាលាទីជនបទ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | នាយក | | គ្រូបង្រៀន | | សិស្ស | | នាយក | | គ្រូបង្រៀន | | សិស្ស | |
| | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ |
| Q4.1 | 100 | 0.00 | 100 | 0.00 | 100 | 0.00 | 100 | 0.00 | 96.00 | 4.00 | 95.00 | 5.00 |
| Q4.2 | 100 | 0.00 | 99.00 | 1.00 | 100 | 0.00 | 100 | 0.00 | 100 | 0.00 | 91.00 | 9.00 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| Q4.3 | 75.00 | 25.00 | 72.00 | 28.00 | 74.00 | 26.00 | 75.00 | 25.00 | 85.00 | 15.00 | 89.00 | 11.00 |
| Q4.4 | 25.00 | 75.00 | 27.00 | 73.00 | 30.00 | 70.00 | 25.00 | 75.00 | 28.00 | 72.00 | 35.00 | 65.00 |
| សរុប | 75.00 | 25.00 | 74.50 | 25.50 | 76.00 | 24.00 | 75.00 | 25.00 | 77.25 | 22.75 | 77.50 | 22.50 |

សម្គាល់៖ *%បាទ/ចាស + %ទេ + %មិនដឹង=១០០%

Q4.1 : សាលាមានបណ្តាញទឹកស្អាតសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃគ្រប់គ្រាន់

Q4.2 : បរិក្ខារលាងសម្អាតដៃដោយមានទឹកស្អាតនិងសាប៊ូសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ

Q4.3 : បង្គន់អនាម័យ បង្គន់នោមសមស្របតាមតម្រូវការប្រើប្រាស់ប្រកបដោយបរិយាបន្ន ឯកជនភាព សុវត្ថិភាព និងរក្សាភាពស្អាតជាប្រចាំ

Q4.4 : ការទុកដាក់ និងគ្រប់គ្រងកាកសំណល់ ការបែងចែកសំរាមត្រឹមត្រូវស្របតាមលក្ខណៈបច្ចេកទេស

ហើយបើតាមការបង្ហាញក្នុងតារាង៧ ការបរិយាយលម្អិតលើសូចនាករនីមួយៗ នោះគឺក្នុងសូចនាករទី៩ ទីប្រជុំជននាយកឆ្លើយ១០០% គ្រូ៩៩% សិស្ស១០០% ចំណែកទីជនបទនាយកឆ្លើយ១០០% គ្រូ៩៦.០០% សិស្ស៩៥.០០% សាលាមានបណ្តាញទឹកស្អាតសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃគ្រប់គ្រាន់។ សូចនាករទី១០ នៅទីប្រជុំជននាយកឆ្លើយ១០០% គ្រូ៩៩.០០% សិស្ស១០០% និងទីជនបទនាយកឆ្លើយ១០០% គ្រូ១០០% សិស្ស៩១.០០% ថាមានបរិក្ខារលាងសម្អាតដៃដោយមានទឹកស្អាតនិងសាប៊ូសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ ។ សូចនាករ១១ នៅទីប្រជុំជននាយកឆ្លើយ៧៥.០០% គ្រូ៧២.០០% សិស្ស៧៤.០០% រីឯនៅទីជនបទនាយកឆ្លើយ៧៥.០០% គ្រូ៨៥.០០% សិស្ស៨៩.០០% ថាបង្គន់អនាម័យ បង្គន់នោមសមស្របតាមតម្រូវការប្រើប្រាស់ប្រកបដោយបរិយាបន្ន ឯកជនភាព សុវត្ថិភាព និងរក្សាភាពស្អាតជាប្រចាំ។ សូចនាករ១២ នៅទីប្រជុំជននាយកឆ្លើយ២៥.០០% គ្រូ២៧.០០% សិស្ស៣០.០០% រីឯនៅទីជនបទនាយកឆ្លើយ២៥.០០% គ្រូ២៨.០០% និងសិស្ស៣៥.០០% ថាការទុកដាក់ និងគ្រប់គ្រងកាកសំណល់ ការបែងចែកសំរាមត្រឹមត្រូវស្របតាមលក្ខណៈបច្ចេកទេស ។




តាមការបង្ហាញលើក្រាបសរសេរស្តង់ដាទី៤ ការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ រវាងទីប្រជុំជន និងទីជនបទ បានអនុវត្តក្នុងកម្រិតបង្គួរដូចគ្នា តែការអនុវត្តនៅទីជនបទខ្ពស់ជាងនៅទីប្រជុំជន១.៤១% ។

### ៤.៣.៥ ការអនុវត្តស្តង់ដាទី៥៖ ការលើកកម្ពស់បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាបន្ន ផាសុខភាព និងមេត្រីភាព

តាមរយៈការស្រាវជ្រាវស្តង់ដាទី៥ ការលើកកម្ពស់បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាបន្ន ផាសុខភាព និងមេត្រីភាព ជារួមការអនុវត្តក្នុងស្តង់ដានេះបានបង្គួរ ដោយការអនុវត្តទីប្រជុំជនបាន៧៥.៩២% ឯទីជនបទបាន៧៣.៧១% ។

តារាង៨ ការលើកកម្ពស់បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាបន្ន ផាសុខភាព និងមេត្រីភាព (%នៃការអនុវត្ត)

| កូដសំណួរ | %អ្នកផ្តល់ចម្លើយនៅសាលាទីប្រជុំជន | | | | | | %អ្នកផ្តល់ចម្លើយនៅសាលាទីជនបទ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | នាយក | | គ្រូបង្រៀន | | សិស្ស | | នាយក | | គ្រូបង្រៀន | | សិស្ស | |
| | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ |
| Q5.1 | 38 | 62.50 | 41 | 59.00 | 42 | 58.00 | 38 | 62.50 | 43 | 57.00 | 44.00 | 56.00 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| Q5.2 | 75.00 | 25.00 | 74.00 | 26.00 | 78.00 | 22.00 | 75.00 | 25.00 | 77.00 | 23.00 | 75.00 | 25.00 |
| Q5.3 | 87.50 | 12.50 | 89.00 | 11.00 | 92.00 | 8.00 | 87.50 | 12.50 | 91.00 | 9.00 | 90.00 | 10.00 |
| Q5.4 | 100 | 0.00 | 98.00 | 2.00 | 97.00 | 3.00 | 87.50 | 12.50 | 89.00 | 11.00 | 88.00 | 12.00 |
| សរុប | 75.00 | 25.00 | 75.50 | 24.50 | 77.25 | 22.75 | 71.88 | 28.13 | 75.00 | 25.00 | 74.25 | 25.75 |

សម្គាល់៖ *%បាទ/ចាស + %ទេ + %មិនដឹង=១០០%

Q5.1 : សាលាមានអនាម័យបរិស្ថាន មានសោភ័ណ្ឌភាព និងសុវត្ថិភាពជាប្រចាំ

Q5.2 : សាលាបានរៀបចំឱ្យមានដើមឈើយកម្លប់

Q5.3 : សាលាបានរៀបចំទីលានសម្រាប់អនុវត្តអប់រំកាយនិងកីឡាដើម្បីទ្រទ្រង់សុខភាព និង សុខុមាលភាព

Q5.4 : សាលាបានរៀបចំទីធ្លានិងកន្លែងអង្គុយលេងសម្រាប់សិស្សនិងលោកគ្រូ អ្នកគ្រូពេលសម្រាក

តាមតារាង៨ ដោយបរិយាយលម្អិតបន្ថែមលើសូចនាករនីមួយៗបង្ហាញថា ការអនុវត្តក្នុងទីប្រជុំជន ចំពោះសូចនាករទី១៣គឺ នាយកឆ្លើយ៣៧.៥០% គ្រូ៤១.00% សិស្ស៤២.00% រីឯទីជនបទ នាយកឆ្លើយ៣៧.៥០% គ្រូ៤៣.00% និងសិស្ស៤៤.00% ថាសាលាមានអនាម័យបរិស្ថាន មានសោភ័ណ្ឌភាព និងសុវត្ថិភាពជាប្រចាំ ។ សូចនាករទី១៤ សម្រាប់ទីប្រជុំជន នាយកឆ្លើយ៧៥.00% គ្រូ៧៤.00% សិស្ស៧៨.00% រីឯនៅទីជនបទ នាយកឆ្លើយ៧៥.00% គ្រូ៧៧.00% សិស្ស៧៤.00% ថាសាលាបានរៀបចំឱ្យមានដើមឈើយកម្លប់ ។ សូចនាករទី១៥ នៅទីប្រជុំជននាយកឆ្លើយ៨៧.៥០% គ្រូ៨៩.00% សិស្ស៩២.00% រីឯទីជនបទនាយកឆ្លើយ៨៧.៥០% គ្រូ៩១.00% សិស្ស៩0.00% ថាសាលាបានរៀបចំទីលានសម្រាប់អនុវត្តអប់រំកាយនិងកីឡាដើម្បីទ្រទ្រង់សុខភាព និងសុខុមាលភាព ។ សូចនាករទី១៦ នៅទីប្រជុំជននាយកឆ្លើយ១០០% គ្រូ៩៨.00% សិស្ស៩៧.00% រីឯទីជនបទនាយកឆ្លើយ៨៧.៥០% គ្រូ៨៩.00% សិស្ស៨៨.00% ថាសាលាបានរៀបចំទីធ្លានិងកន្លែងអង្គុយលេងសម្រាប់សិស្សនិងលោកគ្រូ អ្នកគ្រូពេលសម្រាក។




តាមការបង្ហាញលើក្រាបសរសេរក្នុងស្តង់ដាទី៥ ការលើកកម្ពស់បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាបន្ន ផាសុខភាព និងមេត្រីភាព រវាងទីប្រជុំជន និងទីជនបទ បានអនុវត្តក្នុងកម្រិតបង្គួរដូចគ្នា តែការអនុវត្តនៅទីប្រជុំជនខ្ពស់ជាងទីជនបទ២.២១% ។

### ៤.៣.៦ ការអនុវត្តស្តង់ទី៦៖ ការលើកកម្ពស់សន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងសាលា

តាមរយៈការស្រាវជ្រាវស្តង់ដាទី៦បង្ហាញថា ការលើកកម្ពស់សន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងសាលា ជារួមការអនុវត្តនេះបានក្នុងកម្រិតទាប ការអនុវត្តនៅទីប្រជុំជនបានប្រមាណជា៩.០៨% និងនៅទីជនបទមាន១.១៧% ។ ដោយឡែកតាមតារាង៩ ដែលលម្អិតលើមុខសូចនាករនីមួយៗបង្ហាញថាការអនុវត្តលើសូចនាករទី១៧ ក្នុងទីប្រជុំជននាយកឆ្លើយ០.០០% គ្រូ៣.០០% សិស្ស២.០០% រីឯទីជនបទ នាយកឆ្លើយ០.០០% គ្រូ៤.០០% សិស្ស៣.០០% ថាសាលាមានរៀបចំក្រុមការងារទទួលបន្ទុកសន្តិសុខសណ្តាប់ធ្នាប់ និងសុវត្ថិភាពដោយមានបែងចែកតួនាទីនិងភារកិច្ចច្បាស់លាស់ ។

តារាង៩ ការលើកកម្ពស់សន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងសាលា (%នៃការអនុវត្ត)

| កូដសំណួរ | %អ្នកផ្តល់ចម្លើយនៅសាលាទីប្រជុំជន | | | %អ្នកផ្តល់ចម្លើយនៅសាលាទីជនបទ | | |
|---|---|---|---|---|---|---|
| | នាយក | គ្រូបង្រៀន | សិស្ស | នាយក | គ្រូបង្រៀន | សិស្ស |

| | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| Q6.1 | 0.00 | 100 | 3.00 | 97.00 | 2.00 | 98.00 | 0.00 | 100.00 | 4.00 | 96.00 | 3.00 | 97.00 |
| Q6.2 | 12.50 | 87.50 | 18.00 | 82.00 | 19.00 | 81.00 | 0.00 | 100 | 0.00 | 100 | 0.00 | 100 |
| សរុប | 6.25 | 93.75 | 10.50 | 89.50 | 10.50 | 89.50 | 0.00 | 100 | 2.00 | 98.00 | 1.50 | 98.50 |

សម្គាល់៖ *%បាទ/ចាស + %ទេ + %មិនដឹង=១០០%

Q6.1 : សាលាមានរៀបចំក្រុមការងារទទួលបន្ទុកសន្តិសុខសណ្តាប់ធ្នាប់ និងសុវត្ថិភាពដោយមានបែងចែកតួនាទីនិងភារកិច្ចច្បាស់លាស់

Q6.2 : សាលាមានបំពង់ពន្លត់អគ្គីភ័យនៅតាមអគារសិក្សា ឬនៅតាមទីតាំងសំខាន់ៗដទៃទៀតសម្រាប់ប្រើប្រាស់បន្ទាន់

សូចនាករ១៨ ការអនុវត្តសាលាទីប្រជុំជននាយកឆ្លើយ១២.៥០% គ្រូ១៨.០០% និងសិស្ស១៩.០០% ខណៈនៅទីជនបទនាយក គ្រូ សិស្សឆ្លើយដូចគ្នាគឺ0.00% សាលាមានបំពង់ពន្លត់អគ្គីភ័យនៅតាមអគារសិក្សា ឬនៅតាមទីតាំងសំខាន់ៗដទៃទៀតសម្រាប់ប្រើប្រាស់បន្ទាន់។




តាមការបង្ហាញលើក្រាបសរសេរក្នុងស្តង់ដាទី៦ ការលើកកម្ពស់សន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងសាលា ដែលការអនុវត្តរវាងទីប្រជុំជន និងទីជនបទ បានអនុវត្តក្នុងកម្រិតទាបដូចគ្នា តែការអនុវត្តនៅទីប្រជុំជនខ្ពស់ជាងនៅទីជនបទ៧.៩១% ។

## ៤.៣.៧ ការអនុវត្តស្តង់ទី៧៖ ការលើកកម្ពស់ការអប់រំសុខភាព

តាមរយៈការស្រាវជ្រាវក្នុងស្តង់ដាទី៧បង្ហាញ ជារួមថាការលើកកម្ពស់ការអប់រំសុខភាព បានក្នុងកម្រិតទាប ប្រមាណជា១៦.៨៣% នៅទីប្រជុំជន និងទីជនបទមាន0.00% ។ តាមរយៈលទ្ធផលការស្រាវជ្រាវក្នុងតារាង១០ លម្អិតលើមុខសូចនាករនីមួយៗបង្ហាញថា ការអនុវត្តលើសូចនាករទី១៩ នៅទីប្រជុំជននាយកឆ្លើយ១២.៥០% គ្រូ១៨.00% សិស្ស២0.00% រីឯទីជនបទ នាយក គ្រូ សិស្សឆ្លើយ0.00% ថាសាលាមានរៀបចំក្រុមការងារទទួលបន្ទុកសន្តិសុខសណ្តាប់ធ្នាប់ និងសុវត្ថិភាពដោយមានបែងចែកតួនាទីនិងភារកិច្ចច្បាស់លាស់ ។

តារាង១០ ការលើកកម្ពស់ការអប់រំសុខភាព (%នៃការអនុវត្ត)

| កូដសំណួរ | %អ្នកផ្តល់ចម្លើយនៅសាលាទីប្រជុំជន | | | | | | %អ្នកផ្តល់ចម្លើយនៅសាលាទីជនបទ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | នាយក | | គ្រូបង្រៀន | | សិស្ស | | នាយក | | គ្រូបង្រៀន | | សិស្ស | |
| | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ |
| Q7.1 | 12.50 | 87.50 | 18.00 | 82.00 | 20.00 | 80.00 | 0.00 | 100 | 0.00 | 100 | 0.00 | 100 |
| Q7.2 | 12.50 | 87.50 | 18.00 | 82.00 | 20.00 | 80.00 | 0.00 | 100 | 0.00 | 100 | 0.00 | 100 |
| Q7.3 | 12.50 | 87.50 | 18.00 | 82.00 | 20.00 | 80.00 | 0.00 | 100 | 0.00 | 100 | 0.00 | 100 |
| សរុប | 12.50 | 87.50 | 18.00 | 82.00 | 20.00 | 80.00 | 0.00 | 100 | 0.00 | 100 | 0.00 | 100 |

សម្គាល់៖ *%បាទ/ចាស + %ទេ + %មិនដឹង=១០០%

Q7.1 : សាលាមានផែនការបង្រៀនប្រចាំឆ្នាំនិងកាលវិភាគ បង្រៀនមុខវិជ្ជាអប់រំសុខភាព១ម៉ោងក្នុងមួយសប្តាហ៍

Q7.2 : គ្រូបង្រៀនមុខវិជ្ជាអប់រំសុខភាពទទួលបានសៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាព

Q7.3 : សាលាបានរៀបចំឱ្យមានគ្រូបង្រៀនមុខវិជ្ជាអប់រំសុខភាពតាមកម្រិតថ្នាក់តាមកាលវិភាគ

សូចនាករទី២០ នាយកឆ្លើយក្នុងទីប្រជុំជននាយកឆ្លើយ១២.៥០% គ្រូ១៨.00% សិស្ស២0.00% រីឯទីជនបទ នាយក គ្រូ សិស្សឆ្លើយ0.00% ថាគ្រូបង្រៀនមុខវិជ្ជាអប់រំសុខភាពទទួលបានសៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាព។ សូចនាករទី២១ នៅទីប្រជុំជននាយកឆ្លើយ១២.៥០% គ្រូ១៨.00% សិស្ស២0.00% រីឯទីជនបទ នាយក គ្រូ សិស្សឆ្លើយ0.00% ថាសាលាបានរៀបចំឱ្យមានគ្រូបង្រៀនមុខវិជ្ជាអប់រំសុខភាពតាមកម្រិតថ្នាក់តាមកាលវិភាគ។




តាមការបង្ហាញលើក្រាបសរសេរក្នុងស្តង់ដាទី៧ ការលើកកម្ពស់ការអប់រំសុខភាព ដែលការអនុវត្តរវាងទីប្រជុំជន និងទីជនបទ បានអនុវត្តក្នុងកម្រិតទាបដូចគ្នា តែការអនុវត្តនៅទីប្រជុំជនខ្ពស់ជាងនៅទីជនបទ១៦.៨៣% ។

## ៤.៣.៨ ការអនុវត្តស្តង់ទី៨៖ ការលើកកម្ពស់ការអនុវត្តបំណិនសុខភាព

តាមរយៈការស្រាវជ្រាវស្តង់ដាទី៨បង្ហាញ ជារួមការលើកកម្ពស់ការអនុវត្តបំណិនសុខភាព នៅទីប្រជុំជនបានអនុវត្តក្នុងកម្រិតមធ្យមប្រមាណជា៦២.៥០% និងទីជនបទបានកម្រិតបង្គួរប្រមាណជា៦៥.៨៣% ។ បើតាមរយៈលទ្ធផលនៃការស្រាវជ្រាវក្នុងតារាង១១ ដែលលម្អិតលើមុខសូចនាករនីមួយៗបង្ហាញថា ការអនុវត្តលើសូចនាករទី២២ ក្នុងទីប្រជុំជននាយកឆ្លើយ៦២.៥០% គ្រូ៦០.០០% សិស្ស៦១.០០% រីឯទីជនបទ នាយកឆ្លើយ៨៧.៥០% គ្រូ៨៥.០០% សិស្សឆ្លើយ៥២.០០% ថាសាលាបានអនុវត្តការត្រួតពិនិត្យអនាម័យខ្លួនជាប្រាណជាប្រចាំមុនចូលរៀន។

តារាង១១ ការលើកកម្ពស់ការអនុវត្តបំណិនសុខភាព(%នៃការអនុវត្ត)

| កូដសំណួរ | %អ្នកផ្តល់ចម្លើយនៅសាលាទីប្រជុំជន | | | | | | %អ្នកផ្តល់ចម្លើយនៅសាលាទីជនបទ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | នាយក | | គ្រូបង្រៀន | | សិស្ស | | នាយក | | គ្រូបង្រៀន | | សិស្ស | |
| | បាទ/ | ទេ | បាទ/ | ទេ | បាទ/ | ទេ | បាទ/ | ទេ | បាទ/ | ទេ | បាទ/ | ទេ |

| | ចាស | | ចាស | | ចាស | | ចាស | | ចាស | | ចាស | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| Q8.1 | 62.50 | 37.50 | 60.00 | 40.00 | 61.00 | 23.00 | 87.50 | 12.50 | 85.00 | 12.00 | 52.00 | 39.00 |
| Q8.2 | 0.00 | 100 | 0.00 | 100 | 0.00 | 100 | 0.00 | 100 | 0.00 | 100 | 0.00 | 100 |
| Q8.3 | 87.50 | 12.50 | 89.00 | 11.00 | 92.00 | 8.00 | 87.50 | 12.50 | 91.00 | 9.00 | 90.00 | 10.00 |
| Q8.4 | 100 | 0.00 | 100 | 0.00 | 98.00 | 0.00 | 100 | 0.00 | 100 | 0.00 | 97.00 | 3.00 |
| សរុប | 62.50 | 37.50 | 62.25 | 37.75 | 62.75 | 32.75 | 68.75 | 31.25 | 69.00 | 30.25 | 59.75 | 38.00 |

សម្គាល់៖ *%បាទ/ចាស + %ទេ + %មិនដឹង=១០០%

Q8.1 : សាលាបានអនុវត្តការត្រួតពិនិត្យអនាម័យខ្លួនជាប្រាណជាប្រចាំមុនចូលរៀន

Q8.2 : សាលាបានសហការជាមួយអ្នកពាក់ព័ន្ធក្នុងការផ្តល់នូវបំណិនសង្គ្រោះបឋមដល់គ្រូទទួលបន្ទុកផ្នែកសុខភាព និងសិស្ស

Q8.3 សាលាមានការផ្សព្វផ្សាយពីវិធានការបង្ការជំងឺផ្សេងៗតាមរយៈការបិទផ្សាយសារអប់រំផ្ទាំងរូបភាព ឬការណែនាំផ្ទាល់

Q8.4 សិស្សបានអនុវត្តសកម្មភាពអប់រំកាយ និងកីឡាតាមកាលវិភាគ

សូចនាករ២៣ ទាំងទីប្រជុំជន និងទីជនបទសាលាអនុវត្តមិនបាននោះទេ គឺនាយក គ្រូ សិស្ស ០.០០% ថាសាលាបានសហការជាមួយអ្នកពាក់ព័ន្ធក្នុងការផ្តល់នូវបំណិនសង្គ្រោះបឋមដល់គ្រូទទួលបន្ទុកផ្នែកសុខភាព និងសិស្ស ។ សូចនាករ២៤ នៅទីប្រជុំជន នាយកឆ្លើយ៨៧.៥០% គ្រូ៨៩.០០% សិស្ស៩២.០០% រីឯជនបទនាយកឆ្លើយ៨៧.៥០% គ្រូ៩១.០០% សិស្ស៩០.០០% ថាសាលាមានការផ្សព្វផ្សាយពីវិធានការបង្ការជំងឺផ្សេងៗតាមរយៈការបិទផ្សាយសារអប់រំផ្ទាំងរូបភាព ឬការណែនាំផ្ទាល់ ។ សូចនារក២៥ នៅទីប្រជុំជន នាយកឆ្លើយ១០០% គ្រូ១០០% សិស្ស៩៨.០០% រីឯជនបទនាយកឆ្លើយ១០០% គ្រូ១០០% សិស្ស៩៧.០០% ថាសិស្សបានអនុវត្តសកម្មភាពអប់រំកាយ និងកីឡាតាមកាលវិភាគ ។




តាមការបង្ហាញលើក្រាបសរសេរក្នុងស្តង់ដាទី៨ ការលើកកម្ពស់ការអនុវត្តបំណិនសុខភាព ដែលការអនុវត្តរវាងទីប្រជុំជនបានកម្រិតមធ្យម និងទីជនបទបានកម្រិតបង្គួរ តែការអនុវត្តនៅទីជនបទខ្ពស់ជាងនៅទីប្រជុំជន៣.៣៣% ។

### ៤.៣.៩ ការអនុវត្តស្តង់ទី៩៖ ការលើកកម្ពស់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍកម្មវិធីសុខភាពសិក្សា

តាមរយៈនៃការស្រាវជ្រាវក្នុងស្តង់ដា៩បង្ហាញ ជារួមការលើកកម្ពស់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងអភិវឌ្ឍកម្មវិធីសុខភាពសិក្សា ជាលទ្ធផលបានអនុវត្តក្នុងកម្រិតទាប ក្នុងនោះទីប្រជុំជនអនុវត្តបាន១៦.៥០% និងទីជនបទ០.០០% ។

តារាង១២ ការលើកកម្ពស់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងការអភិវឌ្ឍកម្មវិធីសុខភាពសិក្សា(%នៃការអនុវត្ត )

| កូដសំណួរ | %អ្នកផ្តល់ចម្លើយនៅសាលាទីប្រជុំជន | | | | | | %អ្នកផ្តល់ចម្លើយនៅសាលាទីជនបទ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | នាយក | | គ្រូបង្រៀន | | សិស្ស | | នាយក | | គ្រូបង្រៀន | | សិស្ស | |
| | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ |
| Q1.9 | 12.50 | 87.50 | 18.00 | 82.00 | 19.00 | 80.00 | 0.00 | 100 | 0.00 | 100 | 0.00 | 100 |
| សរុប | 12.50 | 87.50 | 18.00 | 82.00 | 19.00 | 80.00 | 0.00 | 100 | 0.00 | 100 | 0.00 | 100 |

សម្គាល់៖ *%បាទ/ចាស + %ទេ + %មិនដឹង=១០០%

Q9.1 : សាលាកៀរគរប្រភពធនធាននិងការគាំទ្រពីដៃគូនិងអ្នកពាក់ព័ន្ធក្នុងការលើកកម្ពស់សុខភាពសិក្សា

តាមលទ្ធផលការស្រាវជ្រាវក្នុងតារាង១២ ដែលលម្អិតលើសូចនាករទី២៦ នៅទីប្រជុំជននាយកឆ្លើយ១២.៥០% គ្រូ១៨.00% សិស្ស១៩.00% រីឯទីជនបទនាយក គ្រូ សិស្ស ឆ្លើយ0.00% ថាការលើកកម្ពស់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងអភិវឌ្ឍកម្មវិធីសុខភាពសិក្សា ។




តាមការបង្ហាញលើក្រាបសរសេរក្នុងស្តង់ដាទី៩ សាលាកៀរគរប្រភពធនធាននិងការគាំទ្រពីដៃគូរ និងអ្នកពាក់ព័ន្ធក្នុងការលើកកម្ពស់សុខភាពសិក្សា ដែលការអនុវត្តរវាងទីប្រជុំជននិងទីជនបទបានកម្រិតទាបដូចគ្នា តែការអនុវត្តនៅទីប្រជុំជនខ្ពស់ជាងទីជនបទ១៦.៥០% ។

## ៤.៤ ការពិភាក្សា

-ផ្អែកលើលទ្ធផលស្រាវជ្រាវលើស្តង់ដាទី១៖ ការអភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ បង្ហាញថាសាលានៅទីប្រជុំជនអនុវត្តបាន៥៦.០៥% និងទីជនបទ៤៩.២៩% ជាការអនុវត្តមួយក្នុងកម្រិតមធ្យមប្រការដែលសាលាអនុវត្តបានកម្រិតមធ្យមដោយសារក្នុងសូចនាករទី២៖ សាលាមួយចំនួនមិនបានអនុវត្តប្រការដែលត្រូវហាមឃាត់ និងប្រការដែលត្រូវអនុវត្តសម្រាប់សុខភាពអ្នកសិក្សា និងអ្នកអប់រំនោះទេ

ព្រោះនៅតាមកន្លែងលក់នំចំណីក្នុងសាលាមានលក់អាហារដែលក្រសួងអប់រំហាមឃាត់ បើទោះបីជាសាលាទាំងអស់នេះបានបិទស្លាកសញ្ញាហាមឃាត់ក៏ដោយ តាមរយៈលទ្ធផលនេះជារួមសាលាមិនបានអនុវត្តលើក្រមប្រតិបត្តិសុខភាពសិក្សា តាមសេចក្តីណែនាំលេខ១៨ ចុះថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការពង្រឹងវិធានការសុវត្ថិភាពសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សានោះទេ ។

-ផ្អែកលើលទ្ធផលស្រាវជ្រាវលើស្តង់ដាទី២៖ ការលើកកម្ពស់សុខភាពចាំបាច់ដល់គ្រូបង្រៀន និងសិស្ស បង្ហាញថានៅទីប្រជុំជនអនុវត្តបាន៣៦.៩១% និងជនបទត្រឹម៣០.៤៤% ជាការអនុវត្តក្នុងកម្រិតមួយទាប ហើយការអនុវត្តរវាងទីប្រជុំជន ខ្ពស់ជាងទីជនបទបន្តិច ចំណុចដែលសាលាទាំងពីរតំបន់អនុវត្តស្ទើមិនបានទាំងអស់នោះគឺ ក្នុងសូចនាករទី៣៖ សាលាមិនបានរៀបចំឱ្យមានបន្ទប់សុខភាពសិក្សា លើកលែងតែសាលាទី២ក្នុងទីប្រជុំជនមួយប៉ុណ្ណោះដែលអនុវត្តបានល្អ១០០% ។ សាលាដែលអនុវត្តមិនបាន ក៏ព្រោះតែសាលានោះខ្វះប្រភពធនធានមានដូចជា៖ ថវិកា បន្ទប់សុខភាព គ្រូបង្រៀនផ្នែកសុខភាពជាដើម ពិសេសសាលាមិនបានអនុវត្តតាមសេចក្តីណែនាំលេខ៥០ អយក.សណន ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការគោលការណ៍ប្រតិបត្តិស្តង់ដាសម្រាប់ការលើកកម្ពស់សុខភាពអ្នកសិក្សា ។

-ផ្អែកលើលទ្ធផលស្រាវជ្រាវលើស្តង់ដាទី៣៖ ការលើកកម្ពស់ការផ្តល់អាហារូបត្ថម្ភ បង្ហាញថានៅទីប្រជុំជនអនុវត្តបាន៤៧.៩៤% និងជនបទត្រឹម៤២.៣៣% ជាការអនុវត្តក្នុងកម្រិតទាបមួយ ហើយការអនុវត្តរវាងទីប្រជុំជន និងទីជនបទបានប្រហាក់ប្រហែលគ្នា ចំណុចដែលសាលាទាំងពីរតំបន់អនុវត្តស្ទើមិនបានទាំងអស់នោះគឺសូចនាករទី៧៖ សាលាមិនបានរៀបចំអាហារដ្ឋាន កន្លែងផ្តល់ អាហារ ឬកន្លែងលក់ដូរចំណីអាហារប្រកបដោយសុវត្ថិភាព និងសុខភាពនោះឡើយ លើកលែងតែសាលាទី២ ក្នុងនៅទីប្រជុំជនមួយប៉ុណ្ណោះដែលអនុវត្តបានល្អ១០០% សាលាដែលខ្វះការអនុវត្ត ក៏ព្រោះតែសាលានោះខ្វះការអ្នកដឹកនាំ អប់រំ និងផ្សព្វផ្សាយដល់អ្នកលក់ចំណីក្នុងសាលា ដែលអនុវត្តផ្ទុយពីសេចក្តីណែនាំលេខ៥០ អយក.សណន ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការគោលការណ៍ប្រតិបត្តិស្តង់ដាសម្រាប់ការលើកកម្ពស់សុខភាពអ្នកសិក្សា ។

យោងតាម Journal របស់លោកបណ្ឌិត Chansean Mam, 2021 សុខភាពសិស្ស គឺជាកត្តាចម្បងដែលជះឥទ្ធិពលសមិទ្ធិផលការសិក្សារបស់ពួកគេ និងការចូលរួមនៅសាលា តាមការសិក្សាស្រាវជ្រាវមានសាលាគំរូបបីប្រភេទគឺ សាលារៀននៅក្នុងទីក្រុង សាលានៅទីជនបទដែលមានកម្មវិធី "អាហារនៅសាលា" និងសាលារៀននៅជនបទដែលគ្មានកម្មវិធី "អាហារនៅសាលា" ។ ការស្រាវជ្រាវសាលាបឋមសិក្សាក្នុងប្រទេសកម្ពុជា សិស្សសាលានៅទីក្រុងមានកម្ពស់ខ្ពស់ និងទម្ងន់ធ្ងន់ជាងសិស្សសាលានៅទីជនបទ ទាំងសាលាមានកម្មវិធី "អាហារនៅសាលា" និងសាលាគ្មានកម្មវិធី "អាហារនៅសាលា" សិស្សសាលានៅទីជនបទក្នុងសាលាគ្មានកម្មវិធី "អាហារនៅសាលា" គឺខ្លី និងស្រាលបំផុត តាមការសន្និដ្ឋានកម្មវិធីអាហារនៅសាលារៀនមានឥទ្ធិពលវិជ្ជមានទៅលើការលូតលាស់របស់កុមារ ។ សាលានៅជនបទដែលគ្មានកម្មវិធី "អាហារក្នុងសាលារៀន" គួរតែត្រូវបានពង្រីកដល់សាលាបឋមសិក្សានៅតាមជនបទ ក្នុងការលើកកម្ពស់កំណើនកុមារ និងបញ្ហាសុខភាពកុមារ ដើម្បីជាការលើកទឹកចិត្តឱ្យពួកគេចូលរៀនក្នុងសាលា។

-ផ្អែកលើលទ្ធផលស្រាវជ្រាវលើស្តង់ដាទី៤៖ ការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ បង្ហាញថានៅទីប្រជុំជនអនុវត្តបាន៧៥.១៧% និងជនបទត្រឹម៧៦.៥៨% ជាការអនុវត្តក្នុងកម្រិតបង្គួរ ហើយការអនុវត្តរវាងទីប្រជុំជន និងទីជនបទបានប្រហាក់ប្រហែលគ្នា តែចំណុចដែលសាលាទាំងពីរតំបន់អនុវត្តក្នុងកម្រិតទាបនោះគឺសូចនាករទី១២៖ ការទុកដាក់ និងគ្រប់គ្រងកាកសំណល់ ការបែងចែកសំរាមមិនត្រឹមត្រូវស្របតាមលក្ខណៈបច្ចេកទេស ដែលសាលាទាំងអស់សុទ្ធតែមានឡដុតសំរាម និងទីធ្លាទូលាយអាចជាកន្លែងទុកសំរាម ប៉ុន្តែនៅតែមានសំរាមរាយពាសវាលពាសកាល ។ លើកលែងតែសាលាទីពីរប៉ុណ្ណោះដែលគ្រប់គ្រងសំរាមបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ពេលសាលាអនុវត្តបានល្អនោះបានឈ្វេងយល់ពីសុខភាពសិក្សា ការបន្សាយភាពក្លិនមិនល្អធ្វើឱ្យប៉ះពាល់ដល់សុខភាពសិស្ស ។

-ផ្អែកលើលទ្ធផលស្រាវជ្រាវលើស្តង់ដាទី៥៖ ការលើកកម្ពស់បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាបន្ន ផាសុខភាព និងមេត្រីភាព បង្ហាញថានៅទីប្រជុំជនអនុវត្តបាន៧៥.៩២% និងជនបទ

ត្រឹម៧៣.៧១% ជាការអនុវត្តក្នុងកម្រិតបង្គួរ ហើយការអនុវត្តរវាងទីប្រជុំជន និងទីជនបទបាន ប្រហាក់ប្រហែលគ្នា តែចំណុចដែលសាលាទាំងពីរតំបន់អនុវត្តក្នុងកម្រិតទាបនោះគឺសូចនាករទី១៣៖ សាលាមិនមានអនាម័យបរិស្ថាន គ្មានសោភ័ណ្ឌភាពនិងសុវត្ថិភាពជាប្រចាំទេ សាលាខ្វះការយកចិត្តទុកដាក់លើការសម្អាតបរិវេនទីធ្លា ទាំងទីប្រជុំជន និងជនបទ ក្នុងចំណោម១៧ លើ ១៨សាលា មិនមានអនាម័យបរិស្ថានស្អាតនោះទេ សាលាមានភក់ជ្រាំ និងទឹកដក់ កន្លែងចោលសំរាមមានក្លិនមិនល្អ បន្ទប់ទឹកមិនស្អាត និងកន្លែងលក់ចំណីអាហារគ្មានអនាម័យ ។

-ផ្អែកលើលទ្ធផលស្រាវជ្រាវលើស្តង់ដាទី៦៖ ការលើកកម្ពស់សន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងសាលា បង្ហាញថានៅទីប្រជុំជនអនុវត្តបាន៩.០៨% និងជនបទ១.១៧% ជាការអនុវត្តក្នុងកម្រិតទាបបំផុត ហើយការអនុវត្តទីប្រជុំជនខ្ពស់ជាង ទីជនបទបន្តិច តែចំណុចដែលសាលាទាំងពីរតំបន់អនុវត្តក្នុងកម្រិតទាបនោះគឺសូចនាករទី១៧៖ សាលាមិនមានរៀបចំក្រុមការងារទទួលបន្ទុកសន្តិសុខសណ្តាប់ធ្នាប់ និងសុវត្ថិភាពដោយមានបែងចែកតួនាទីនិងភារកិច្ចច្បាស់លាស់នោះទេ សាលាទាំងអស់មិនមានផែនការរៀបចំក្រុមការងារទទួលបន្ទុកសន្តិសុខសណ្តាប់ធ្នាប់ដោយមានគ្រូ និងក្រុមប្រឹក្សាសិស្សឈរសម្រួលចរាចរតាមក្លោងទ្វារ ឬផ្លូវថ្នល់មុខសាលារៀនពេលចេញ និងចូលរៀននោះឡើយ តាមការស្រាវជ្រាវ និងការវិភាគល្អិតល្អន់របស់អ្នកស្រាវជ្រាវឃើញថាគ្រូនិងសិស្សតំបន់ទាំងពីរមានទិន្នន័យឆ្លើយក្រោមរង្វង់៤.០០% និងមានចំនួនក៏ពិតមែន ប៉ុន្តែនេះជាផែនការរបស់ក្រុមប៉ូលីសចរាចរមូលដ្ឋានដែលជួយសម្រួលចរាចរម្តងម្កាលតែប៉ុណ្ណោះ សម្រាប់សាលា ដែលមាននៅតាមដងផ្លូវថ្នល់ជាតិ ហើយមានអ្នកធ្វើដំណើរឆ្លងកាត់ទៅមកមមាញឹក។ផ្អែកលើសន្និបាតអប់រំ របស់ក្រសួងអប់រំឆ្នាំ២០២៣ ស្តីពីឯកសារទស្សនាទានសុខភាពសិក្សាក្នុងបរិបទថ្មី ក្នុងចំណុច ២.៦ លើកឡើងពីការលើកកម្ពស់សន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងគ្រឹះស្ថានសិក្សា ការផ្តោតទៅលើការរៀបចំវេនយាមទៅតាមច្រកចេញចូលគ្រប់ពេលម៉ោងសិក្សា សូចនាករនេះដែលសាលាមិនបានអនុវត្ត គឺមិនបានគោរពតាមដូចមានចែងក្នុងសន្និបាតអប់រំឆ្នាំ២០២៣នោះទេ ។

-ផ្អែកលើលទ្ធផលស្រាវជ្រាវលើស្តង់ដាទី៧ ការលើកកម្ពស់អប់រំសុខភាព បង្ហាញថានៅទីប្រជុំជនអនុវត្តបាន១៦.៨៣% និងជនបទ០.00% នេះជាការអនុវត្តក្នុងកម្រិតទាបមួយ ហើយការអនុវត្តរវាងទីប្រជុំជនខ្ពស់ជាង ទីជនបទ១៦.៨៣% តែចំណុចដែលសាលាទាំងពីរតំបន់អនុវត្តក្នុងកម្រិតទាបបែបនេះ គឺព្រោះសូចនាករទី១៩៖ សាលាទាំងទីប្រជុំជន និងទីជនបទ១៧ ក្នុងចំណោម១៨ សាលាមានមិនផែនការបង្រៀនប្រចាំឆ្នាំនិងកាលវិភាគ បង្រៀនមុខវិជ្ជាអប់រំសុខភាព១ម៉ោងក្នុងមួយសប្តាហ៍ សូចនាករទី២០៖ មិនមានគ្រូបង្រៀនមុខវិជ្ជាអប់រំសុខភាពទទួលបានសៀវភៅ សិក្សាគោលមុខវិជ្ជាអប់រំសុខភាព និងសូចនាករទី២១៖ សាលាមិនបានរៀបចំឱ្យមានគ្រូបង្រៀនមុខវិជ្ជាអប់រំសុខភាពតាមកម្រិតថ្នាក់តាមកាលវិភាគ។

-ផ្អែកលើលទ្ធផលស្រាវជ្រាវលើស្តង់ដាទី៨ ការលើកកម្ពស់អប់រំសុខភាព បង្ហាញថានៅទីប្រជុំជនអនុវត្តបាន៦២.៥0% និងជនបទ៦៥.៨៣% នេះជាការអនុវត្តក្នុងកម្រិតមធ្យម ហើយការអនុវត្តរវាងទីប្រជុំជនទាបជាងទីជនបទបន្តិច ។ បើងាកមកមើលការវិភាគលើសូចនាករទី២៣វិញឃើញថា៖ សាលាមិនបានសហការជាមួយអ្នកពាក់ព័ន្ធក្នុងការផ្តល់នូវបំណិនសង្គ្រោះបឋមដល់គ្រូទទួលបន្ទុកផ្នែកសុខភាព និងសិស្សទេព្រោះបើតាមសាលាទីពីរ មានការរាយការណ៍មកអ្នកស្រាវជ្រាវថានាយកបានប្រជុំជាមួយក្រុមប្រឹក្សាឃុំរៀងរាល់ខែដែរ ហើយនាយកកបានស្នើដល់អ្នកពាក់ព័ន្ធ ពិសេសមន្ត្រីពេទ្យមណ្ឌលសុខភាព និងប៉ូលីសមូលដ្ឋានតែមិនឃើញមានមន្ត្រីណាមកសហការផ្តល់នូវបំណិនសង្គ្រោះបឋមនោះទេ ក្រៅពីសាលាទីពីរនេះ មិនមានសាលាណាស្នើសុំផ្តល់កិច្ចសហការដើម្បីអនុវត្តលើសូចនាករទី២៣នេះទេ ។

-ផ្អែកលើលទ្ធផលស្រាវជ្រាវលើស្តង់ដាទី៩ ការលើកកម្ពស់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងអភិវឌ្ឍកម្មវិធីសុខភាពសិក្សា បង្ហាញថានៅទីប្រជុំជនអនុវត្តបាន១៦.៥0% និងជនបទ0.00% នេះជាការអនុវត្តក្នុងកម្រិតល្អទាប ពិសេសសាលានៅទីជនបទគឺមិនមានការអនុវត្តលើស្តង់ដានេះទេ ចំពោះលទ្ធផលក្នុងសូចនាករទី២៦វិញបង្ហាញថា ៖ សាលាទីពីរបានអនុវត្តលើសូចនាករនេះដោយតំបូងឡើយសាលាមានការកៀរគធនធានថវិកាមកអភិវឌ្ឍសាលាពីសហគមន៍ គឺមិនបានលទ្ធផលនោះទេ

ដោយនាយកលើកឡើងថា សហគមន៍បានគិតអភិវឌ្ឍមានមកលើសាលា រហូតមកនាយកនៅតែខិតខំ ប្រឹងប្រែងបង្ហាញពីគោលបំណងនៃការកៀរគរលុះទទួលបានជោគជ័យ នេះបញ្ជាក់ថាសាលាទីពីរដឹង និងបានយល់ច្បាស់ពីការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សា។ ចំពោះសាលាក្រៅពីនេះបានផ្តល់ព័ត៌មានដល់អ្នកស្រាវជ្រាវថា ពួកគាត់បានត្រឹមតែកៀរគរថវិកាមកធ្វើ របង ឬជួសជុលហេដ្ឋារចនាសម្ព័ន្ធសាលាតិចតួចប៉ុណ្ណោះ ហើយថវិកាដែលបានមកនោះមិនគ្រប់គ្រាន់ នោះឡើយ។ ចំពោះនៅទីក្រុងសៀងហៃ សាលាត្រូវបានគ្រប់គ្រងដោយការិយាល័យអប់រំ នៃរដ្ឋបាល ក្រុង/ស្រុក គម្រោងបង្ការគ្រោះថ្នាក់ជាច្រើនប្រភេទ បានដាក់ចេញក្នុងសហគមន៍ ហើយសាលារៀនធ្វើ កិច្ចសហប្រតិបត្តិការណ៍ជាមួយសហគមន៍ កម្មវិធីអប់រំសុខភាពតាមសហគមន៍បានបង្ហាញពីឥទ្ធិពល យ៉ាងសំខាន់ក្នុងការធ្វើអោយប្រសើរឡើងនូវជំនឿសុខភាពរបស់សិស្ស គុណសម្បត្តិនៃកិច្ចសហ ប្រតិបត្តិការនេះគឺ៖ (១) សហគមន៍បានសម្របសម្រួលពីគ្រប់សមាសភាព ដូចជា នាយកដ្ឋាន ចរាចរណ៍, នាយកដ្ឋានពន្លត់អគ្គីភ័យ និងមន្ទីរសុខាភិបាល, កិច្ចសហប្រតិបត្តិការជួយសម្រួលសហគម ន៍ដើម្បីបញ្ជាក់ពីប្រភេទជាក់លាក់នៃការគ្រោះថ្នាក់ និងកត្តាហានិភ័យ និងផ្តល់ការគាំទ្រផ្នែកបច្ចេកវិទ្យា ដល់សាលារៀនក្នុងការអនុវត្តកម្មវិធីការពារការគ្រោះថ្នាក់ ២) ជាមួយជំនួយរបស់គណៈកម្មាធិការ លំនៅដ្ឋាន, សហគមន៍អាចទទួលបានការគាំទ្រពីគ្រួសារ ៣) សហគមន៍មានមូលនិធិពិសេស និង អាចផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់គម្រោង ៤) សហគមន៍អាចផ្តល់វេទិកាចាំបាច់សម្រាប់ អន្តរាគមន៍ ៥) សិស្សអាចផ្សព្វផ្សាយចំណេះដឹង និងជំនាញអំពីការការពារការគ្រោះថ្នាក់ដល់គ្រួសារ និងសហគមន៍ (Zhi-Juan Cao1† , Yue Chen2† and Shu-Mei Wang1 *†, 2014)។

## ដ្យាក្រាមរួមបង្ហាញពីកម្រិតការអនុវត្តស្តង់ដានីមួយៗ រវាងទីប្រជុំជន និងទីជនបទ



# ជំពូកទី៥

# សន្និដ្ឋាន និងសំណូមពរ

# ជំពូក៥៖

# សេចក្ដីសន្និដ្ឋាន និងសំណូមពរ

## ៥.១.សេចក្ដីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវនេះបានផ្ដល់ជារបកគំហើញថ្មីមួយ ពីស្ថានភាពនៃការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សានៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀងសម្រាប់សាធារណៈជនទូទៅ មិនត្រឹមតែប៉ុណ្ណោះការស្រាវស្រាវនេះបង្ហាញឱ្យអ្នកដឹកនាំអង្គភាពកម្រិតសាលារៀន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សអ្នកពាក់ព័ន្ធមើលឃើញពីលទ្ធផលរបស់ខ្លួនពីការអនុវត្តលើសូចនាករស្តង់ដាសុខភាពសិក្សានីមួយៗ ឱ្យមានចូលរួមដើម្បីកែលម្អការអនុវត្តនេះឱ្យកាន់តែប្រសើរជាងមុន ។

អ្នកស្រាវជ្រាវសន្និដ្ឋានថាលទ្ធផលដែលអនុវត្តស្តង់ដាសុខភាពសិក្សារវាងទីប្រជុំជន និងទីជនបទបានក្នុងកម្រិតទាបដូចគ្នាលើស្តង់ដាទី២ ស្តង់ដាទី៣ ស្តង់ដាទី៦ ស្តង់ដាទី៧ និងស្តង់ដាទី៩ ចំណែកស្តង់ដាទី១អនុវត្តបានកម្រិតមធ្យម ស្តង់ដាទី៤ ទី៥ និងទី៨ បានអនុវត្តលើមធ្យម តែនៅជាចំណុចមួយដែលតម្រូវឱ្យមានការកែលម្អបន្ទាន់នៅឆ្នាំសិក្សាៗក្រោយទៀត ។ ការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សាកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង លើស្តង់ដានីមួយៗមិនទាន់បានឆ្លើយតបនិងចំណុចដៅនៃគោលការណ៍នេះនៅឡើយទេ ។ ប្រការដែលអនុវត្តមិនបានល្អនោះធ្វើឱ្យមានការប្រឈមលើបញ្ហាសុខភាពសិក្សារបស់សិស្ស ដែលតម្រូវឱ្យគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងអ្នកពាក់ព័ន្ធចូលរួមអនុវត្តតាមសេចក្ដីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡាឱ្យបានមុតមាំ ។

## ៥.២.សំណូមពរ

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវ នៅសាលាបឋមសិក្សាទាំង១៨ក្នុងខេត្តស្វាយរៀងបង្ហាញឱ្យឃើញថា ការអនុវត្តផ្នែកសុខភាពសិក្សានេះ លើសូចនាករនៃស្តង់ដាខ្លះមិនទាន់បានឆ្លើយតបនៃការអនុវត្តនេះបានល្អនៅឡើយទេ ។ កត្តានេះមិនអាចអូសបន្លាយក្នុងស្ថានភាពដដែលៗតទៅទៀត

បានឡើយ បើមិនបានរកដំណោះស្រាយទាន់ពេលវេលានោះ ពិសេសធ្វើឱ្យសុខភាពសិក្សារបស់សិស្ស ធ្លាក់ចុះ ជាហេតុនាំឱ្យគុណភាពអប់រំនឹងធ្លាក់ចុះផងដែរ ។ ក្នុងន័យនេះអ្នកសិក្សាស្រាវជ្រាវបានផ្តួចផ្តើមលើកឡើងនូវសំណូមពរដល់ក្រសួង មន្ទីរ និងអ្នកពាក់ព័ន្ធដូចខាងក្រោមៈ

- **ក្រសួងអប់រំ យុវជន និងកីឡា**
  - គួរជ្រើសរើសគ្រូឯកទេសសុខភាពសិក្សា និងគួរអាចជ្រើសចេញពីគ្រូដែលមានសញ្ញាបត្រគិលានុប្បដ្ឋាក
  - គួរបន្ថែមកញ្ចប់ថវិកាលើការអនុវត្តសុខភាពសិក្សា
  - គួរផលិតឯកសារសុខភាពសិក្សាដើម្បីធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយតាមវិទ្យុ ទូរទស្សន៍ និងបណ្តាញសង្គមនានាឱ្យបានខ្ពស់ជាអតិបរមា
  - គួររកដៃគូរសហការពាក់ព័ន្ធ ដូចជាអង្គការក្រៅរដ្ឋាភិបាល សហគមន៍អន្តរជាតិដើម្បីផ្តល់ជំនួយក្នុងការបណ្តុះបណ្តាល និងការអនុវត្តផ្នែកសុខភាពសិក្សា
  - គួរដាក់បញ្ចូលកម្មវិធីសិក្សាសុខភាពឱ្យបានច្បាស់លាស់យ៉ាងតិចមួយម៉ោងក្នុង១សប្តាហ៍ បន្ថែមលើសេចក្តីណែនាំនៃការចាប់ផ្តើមវិសមកាលនៃឆ្នាំនីមួយៗ
  - គួរអភិវឌ្ឍកម្មវិធីសិក្សាលើមុខវិជ្ជាសុខភាពឱ្យបានគ្រប់កម្រិតថ្នាក់
  - គួរផលិតសៀវភៅសិក្សាគោលមុខវិជ្ជាសុខភាពសម្រាប់គ្រូ និងសិស្ស ហើយបញ្ជូនទៅតាមសាលាឱ្យបានគ្រប់ៗគ្នាទាន់ពេលវេលា និងមានប្រសិទ្ធភាព
- **ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក និងគណៈគ្រប់គ្រងសាលា**
  - គាំទ្រការដាក់ឱ្យអនុវត្តសុខភាពសិក្សារបស់ក្រសួងអប់រំ
  - គួរពិនិត្យតាមដានការអនុវត្តសុខភាពសិក្សាតាមសាលា និងរកដំណោះស្រាយឱ្យទាន់ពេលវេលានៅពេលដែលជួបបញ្ហាប្រឈមកើតឡើង
  - គួររៀបចំបញ្ជីសាលាបញ្ហាប្រឈមលើសុខភាពសិក្សាជូនក្រសួងអប់រំឱ្យជួយដោះស្រាយ

- គួររកដៃគូរសហការឱ្យជួយឧបត្ថម្ភលើការអនុវត្តសុខភាពសិក្សា
- គួរបណ្តុះបណ្តាលសមត្ថភាពដល់លោកគ្រូ អ្នកគ្រូ ពីការអនុវត្តសុខភាពសិក្សា
- គួរបង្កើតគណៈកម្មការសុខភាពសិក្សា ដោយមានបំណែងចែកភារកិច្ចនិងតួនាទីច្បាស់លាស់
- គួរធ្វើផែនការប្រជុំប្រចាំខែក្នុងគណៈកម្មការសុខភាពសិក្សា
- គួរបង្កើតPage Facebook , Telegram ផ្លូវការរបស់សាលារៀនផ្សព្វផ្សាយ អនុក្រឹត្យ សេចក្តីណែនាំ លិខិតបទដ្ឋានគតិយុត្តស្តីពីសុខភាពសិក្សាដល់សហគមន៍
- គួរបង្កើតបន្ទប់សុខភាពសិក្សាចំពោះសាលាដែលមានទីធ្លាក្នុងវត្តអារាម ឬក្នុងសាលាដែលមានបន្ទប់ទំនេរ,
- គួរធ្វើបំណែងចែកកម្មវិធីសិក្សា និងកិច្ចតែងការមុខវិជ្ជាសុខភាពឱ្យបានត្រឹមត្រូវ

- **អាជ្ញាធរមូលដ្ឋាន កងកំលាំងនគរបាល មន្ទីរពេទ្យ ឬមណ្ឌលសុខភាព**
  - គួរលើកការប្រជុំប្រចាំខែ ដោយដាក់របៀបវារៈសុខភាពសិក្សាកម្រិតសាលារៀនជាអាទិភាព
  - គាំទ្រនូវរាល់ឯកសារលិខិតបទដ្ឋានគតិយុត្ត ឬសេចក្តីណែនាំផ្សេងៗរបស់ក្រសួងអប់រំស្តីការអនុវត្តលើការលើកកម្ពស់សុខភាពសិក្សា
  - គួរសហការជាមួយសាលាដើម្បីរក្សាសណ្តាប់ធ្នាប់សាលា និងសណ្តាប់សាធារណៈ
  - គួរបណ្តុះបណ្តាលបំណិនសង្គ្រោះបន្ទាន់ស្តីពីសុខភាពដល់គ្រូបង្រៀន
  - គួរកៀរគរធនធានសម្ភារ និងថវិកាដើម្បីគាំទ្រដល់ការអភិវឌ្ឍសុខភាពសិក្សាក្នុងសាលារៀន
  - គួរអន្តរាគមន៍ និងកិច្ចសហការជាមួយសាលាដើម្បីពិនិត្យសុខភាពសិស្សតាមកាលវិភាគ
  - គួរបង្កើតសួនបន្លែសហគមន៍ក្នុងបរិវេណសាលា
  - គួរជំរុញការអនុវត្តសកម្មភាពសិស្សបង្កើតសួនជីវៈចម្រុះក្នុងសាលា

- **អ្នកស្រាវជ្រាវបន្ត**

